CrossConnect
MINISTRIES

# ផែនការព្រះជាម្ចាស់
# ជម្រើសរបស់យើង

**ជែកឃី អ៊ូស**

## លោកុប្បត្តិ ១-១១

**មេរៀនទី១៖ កំណើតផែនដី - *កំណើតផែនដីតាមការរចនារបស់ព្រះជាម្ចាស់***

**មេរៀនទី២៖ ការធ្លាក់ចុះ - *តើមានបញ្ហាអ្វីកើតឡើង?***

**មេរៀនទី៣៖ កាអ៊ីន និងអេបិល - *តើទូលបង្គំជាអ្នកថែរក្សាប្អូនឬអី?***

**មេរៀនទី៤៖ ទឹកជំនន់ - *អញនឹងមិន...!***

**មេរៀនទី៥៖ ប៉មបាបិល - *ពីលោកណូអេ ដល់លោកអាប់រ៉ាម***

**“...ទូលបង្គំផ្ញើជីវិតលើព្រះបន្ទូលរបស់ព្រះអង្គ”**
**ទំនុកដំកើង ១១៩:៧៤**

គ្រប់បទគម្ពីរ ត្រូវបានដកស្រង់ពីព្រះគម្ពីរបរិសុទ្ធ រក្សាសិទ្ធ © ឆ្នាំ1954 និង © ឆ្នាំ1962
ដោយសមាគមព្រះគម្ពីរកម្ពុជា ប្រើប្រាស់ដោយមានការអនុញ្ញាត និងរក្សាសិទ្ធគ្រប់យ៉ាង

ផលិតដោយ គ្រឹះស្ថានបោះពុម្ព TENTHPOWERPUBLISHING
www.tenthpowerpublishing.com

រក្សាសិទ្ធិ © ឆ្នាំ២០១៨ ដោយព័ន្ធកិច្ច CrossConnect Ministries
www.crosscm.org

រក្សាសិទ្ធិគ្រប់យ៉ាង។ គ្មានចំណែកណាមួយក្នុងសៀវភៅនេះ ត្រូវបានផលិតឡើងវិញ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធឡើយ លើកលែងតែអ្នកត្រួតពិនិត្យដែលស្រង់យកអត្ថបទសង្ខេបខ្លះមកពិនិត្យ។ រាល់ការផលិតឡើងវិញ ការរក្សាទុកក្នុងប្រព័ន្ធកុំព្យូទ័រ ដោយថតចម្លង ឬតាមមធ្យោបាយណាមួយ ដែលគ្មានការអនុញ្ញាតិពីអ្នកនិពន្ធ គឺសុទ្ធតែត្រូវបានហាមឃាត់។

គ្រប់បទគម្ពីរ ត្រូវបានដកស្រង់ពីព្រះគម្ពីរបរិសុទ្ធ រក្សាសិទ្ធ © ឆ្នាំ1954 និង © ឆ្នាំ1962
ដោយសមាគមព្រះគម្ពីរកម្ពុជា ប្រើប្រាស់ដោយមានការអនុញ្ញាត និងរក្សាសិទ្ធគ្រប់យ៉ាង

រចនាទំព័រដោយ Inkwell Creative

# បុរេកថា

អ្នករាល់គ្នាកំពុងចាប់ផ្តើមដំណើរផ្សងព្រេងមួយ ដែលនឹងបំផ្លាស់បំប្រែពេលវេលាដែលនៅសេសសល់ក្នុងជីវិតរបស់អ្នក។ ដំណើរជីវិតនេះ ប្លែកសម្រាប់អ្នក ព្រមទាំងត្រូវរំលេចឡើងម្តងបន្តិចៗ តាមរយៈបំណងចិត្តដ៏រីករាយរបស់អ្នក ក្នុងការសិក្សាស្វែងយល់អំពីសៀវភៅមួយក្បាលដែលគេហៅថា ព្រះគម្ពីរបរិសុទ្ធ។ ការប្តេជ្ញាចិត្តរបស់អ្នកចំពោះការសិក្សានេះ សន្យាថានឹងធ្វើឱ្យជីវិតរបស់អ្នករាល់គ្នាកាន់តែចម្រើនឡើង ពេលព្រះជាម្ចាស់ទ្រង់មានបន្ទូលមកអ្នករាល់គ្នា តាមរយៈព្រះបន្ទូលទ្រង់។

ពេលអ្នករាល់គ្នាសិក្សា អ្នករាល់គ្រូវបានលើកទឹកចិត្តឱ្យមានសម្ភារៈមេរៀនខ្លះនៅនឹងដៃ ដូចជា៖

១. សៀវភៅមេរៀននេះ៖ ផែនការព្រះជាម្ចាស់ ជម្រើសរបស់យើង

២. ព្រះគម្ពីរបរិសុទ្ធ ឬព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន។ ចំណាំ ប្រសិនបើអ្នករាល់គ្នាត្រូវការទិញព្រះគម្ពីរថ្មី ប្រសិនបើអាចចូរស្វែងរកព្រះគម្ពីរណាដែលមាន៖

   ក. តារាងខយោង ភាគច្រើននៅចំកណ្តាលទំព័រ

   ខ. វចនាធិប្បាយ តាមធម្មតា មាននៅខាងក្រោយព្រះគម្ពីរ

   គ. និងមានផែនទីមូលដ្ឋានខ្លះ ដែលមាននៅខាងក្រោយព្រះគម្ពីរនេះដែរ

៣. ប៊ិច ឬខ្មៅដៃ

៤. កាតប្រើសម្រាប់ខណ្ឌចំណាំកណ្ឌគម្ពីរ

សម្ភារៈដែលមានក្នុងចំណុចលេខ2 គឺវាគ្រប់គ្រាន់សម្រាប់ការសិក្សារបស់អ្នក ព្រមទាំងធ្វើឱ្យអ្នកត្រៀមជាស្រេចដើម្បីសិក្សាមេរៀនទាំងអស់ នេះដែរ។ យ៉ាងណាមិញ ប្រសិនបើ អ្នកទើបសិក្សាព្រះគម្ពីរជាលើកដំបូង អ្នកប្រហែលជាចង់ចាប់ផ្តើមសិក្សា ដោយប្រើមេរៀនមួយដែលមានចំណងជើងថា *Navigating the Bible* (ការស្ទង់មើលព្រះគម្ពីរ) អ្នកអាចទាញយកសៀវភៅមេរៀននេះដោយឥតគិតថ្លៃ ពីគេហទំព័រ www.CrossCM.org របស់ CrossConnect Ministries ។ បើទោះជាមេរៀននេះ ត្រូវបានណែនាំឱ្យសិក្សាមែន ប៉ុន្តែ វាក៏មិនអាចជួយឱ្យការសិក្សាមេរៀន *ផែនការព្រះជាម្ចាស់ ជម្រើសរបស់យើង* ទទួលបានជោគជ័យដែរ។

សូមកុំខ្លាចនឹងគូសចំណាំព្រះគម្ពីររបស់អ្នក ដ្បិតព្រះគម្ពីរនេះ ទុកសម្រាប់ឱ្យអ្នករាល់គ្នាសិក្សា។ ចូរធ្វើការកត់ត្រាដោយសរសេរ គូសបន្ទាត់ពីក្រោម គូសចំណាំដោយប្រើហ្វឺតពណ៌ គូររង្វង់លើខគម្ពីរ និងគូរសញ្ញាព្រួញជាដើម! អ្នកក៏អាចប្រើសៀវភៅសរសេរ ឬឧបករណ៍អេឡិចត្រូនិចសម្រាប់កត់ត្រាគំនិត សំណួរ និងតាមដានមើលដំណើរជីវិតរបស់អ្នក តាមរយៈការសិក្សាមេរៀននេះ។

មេរៀននេះត្រូវបានរៀបរៀងឡើង ដើម្បីឱ្យអ្នករាល់គ្នាអាចសិក្សាដោយខ្លួនឯងបាន។ អ្នករាល់គ្នានឹងឃើញ ថាមេរៀននេះមានការលំបាកតិចតួច ឬគ្មានសោះ បើអ្នករាល់គ្នាមានកម្រិតវិន័យសម្រាប់ខ្លួនឯង។ នៅក្នុងពេលជាមួយគ្នានោះ អ្នករាល់គ្នានឹងទទួលបានព័ត៌មានថ្មី ចែករំលែកការចេះដឹងរបស់អ្នក និងសួរសំណួរលំបាកៗដែលទាមទារឱ្យមាននូវចម្លើយ។ ដើម្បីទទួលបានការឆ្លើយតបនេះ អ្នករាល់គ្នាត្រូវបានលើកទឹកចិត្តឱ្យអញ្ជើញមិត្តសម្លាញ់ពីរ ឬបីនាក់ មកចូលរួមជាមួយអ្នកក្នុងការសិក្សា។

សូមឱ្យអ្នករាល់គ្នាមានសេចក្ដីអំណរក្នុងការសិក្សា សូមឱ្យអ្នករាល់គ្នាបើកចិត្តទទួល ពេលព្រះជាម្ចាស់មានបន្ទូលមកកាន់អ្នករាល់គ្នា តាមរយៈព្រះបន្ទូលទ្រង់ សូមឱ្យរឿងរ៉ាវក្នុងព្រះគម្ពីរជួយឱ្យអ្នករាល់គ្នាស្គាល់ច្បាស់អំពីក្ដីស្រឡាញ់ដ៏អស្ចារ្យដែលទ្រង់បានប្រទានមក តាមរយៈព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់ និងជាព្រះអង្គសង្គ្រោះនៃយើងរាល់គ្នា។

# មេរៀនទី១

# កំណើតផែនដី
# តាមការរចនារបស់ព្រះជាម្ចាស់

## លោកុប្បត្តិ ១-២ - ដំណើររឿងកំណើតផែនដី

### មាតិកាសំខាន់ៗក្នុងមេរៀនទី១


និដ្ឋភាពទូទៅ៖ លោកុប្បត្តិ ១-២

សេចក្ដីផ្ដើម

មេរៀនទី១៖ លោកុប្បត្តិ ១-២

- ព្រះដ៏ជាព្រះអាទិករ
- លោកុប្បត្តិ ដំណើររឿងនៃកំណើតផែនដី
- ថ្ងៃសប្ប័ទត្រូវបានបង្កើតឡើង
    - និយមន័យ៖ *ការញែកជាបរិសុទ្ធ*
    - និយមន័យ៖ *ថ្ងៃសប្ប័ទ*
- ការបង្កើតមនុស្សប្រុស និងមនុស្សស្រី
- អាពាហ៍ពិពាហ៍
- ដើមឈើដឹងខុសត្រូវ
- ការអនុវត្ត

# លំនាំដើម

គម្ពីរលោកុប្បត្តិ គឺជាកណ្ឌគម្ពីរដំបូង ដ្បិតលោកុប្បត្តិមានន័យថា ដើមដំបូង។ កណ្ឌគម្ពីរនេះរៀបរាប់ពីកំណើតផែនដី ដោយប្រើពាក្យថា "កាលដើមដំបូងបង្អស់" ។ នៅក្នុង២ជំពូកដំបូង យើងអានឃើញការរៀបរាប់ពីដំណើររឿងកំណើតផែនដី គឺព្រះអង្គហើយដែលបានបង្កើតរបស់សព្វសារពើទាំងនៅលើមេឃ និងលើផែនដីនេះ។ របស់សព្វសារពើដែលទ្រង់បានបង្កើត គឺសុទ្ធល្អ ហើយល្អប្រសើរបំផុត! លោកុប្បត្តិ ជំពូក១ និងជំពូក២ រៀបរាប់អំពីការបង្កើតមនុស្សដំបូង ឈ្មោះ អ័ដាម និងស្ត្រីដំបូង ឈ្មោះ អេវ៉ា។ ព្រះជាម្ចាស់បានបង្កើតគេមក ឱ្យចំនឹងរូបអង្គទ្រង់ ទាំងប្រទានឱ្យគេនូវគោលបំណងច្បាស់លាស់ ទើបទ្រង់ដាក់ឱ្យគេរស់ក្នុងសួនអេដែន ដោយណែនាំឱ្យគេធ្វើការ និងថែរក្សាសួននេះ។

ដើមកណ្ឌគម្ពីរលោកុប្បត្តិ មិនត្រូវបានសន្និដ្ឋានបញ្ចប់នៅក្នុងគម្ពីរលោកុប្បត្តិនោះទេ ផ្ទុយទៅវិញ ការចាប់ផ្ដើមដ៏ស្ទុគ្រស្មាញមួយទៀត ត្រូវបានគេរៀបរាប់នៅក្នុងលោកុប្បត្តិ ២:១០។ ក្នុងករណីនេះ ការចាប់ផ្ដើម គឺពាក្យថា "មានទន្លេ១"។ ខ១០ ចាប់ផ្ដើមដោយរៀបរាប់ថា "មានទន្លេ១ហូរចេញពីស្រុកអេដែន មកស្រោចសួនច្បារនោះ" ទន្លេនេះបែកចេញជា៤មុខ។ ខគម្ពីរនេះគេងាយនឹងមើលរំលងណាស់ ដ្បិតវាមានការទាក់ទងតិចតួចទៅនឹងរឿងកំណើតផែនដី។

យើងដឹងថា ទន្លេនីមួយៗសុទ្ធតែមានប្រភពដើម។ ទន្លេយ៉ាងហ្សី មានប្រភពដើមនៅក្នុងតំបន់វាលទំនាបទឹកកកគីហៃ-ទីបេ ចំណែកទន្លេហាន នៅកូរ៉េខាងត្បូង មានប្រភពដើមនៅត្រង់ចំណុចប្រសព្វទន្លេណាំហាន និងទន្លេប៊ូខាម។ ទន្លេអាម៉ាហ្សូន មានប្រភពមកពីតំបន់ភ្នំអេនដេស ចំណែកទន្លេដែលវែងជាងគេ គឺទន្លេនីល មានប្រភពដើមមកពីទន្លេនីលខៀវ ក្នុងប្រទេសអេធ្យូពី។ ទន្លេទាំងអស់សុទ្ធតែមានប្រភពដើម មិនថាទន្លេនោះតូចយ៉ាងណានោះទេ។

ទន្លេងដែលហូរមកពីសួនអេដែន នៅក្នុងសណ្ឋានដ៏គួរឱ្យចាប់អារម្មណ៍នេះ បានធ្វើការចាប់ផ្ដើមនៅក្នុងជំពូកទី២នៃកណ្ឌទី១ក្នុងព្រះគម្ពីរ ហើយបានតភ្ជាប់សាច់រឿងក្នុងប្រវត្តិព្រះគម្ពីរទាំងមូលរហូតមកទល់សព្វថ្ងៃ រួចបន្តទៅមុខទៀតជានិរន្តរ។ យើងអាចតាមដានអំពីទន្លេនេះ នៅក្នុងបទគម្ពីរទាំងមូលបាន។ ទន្លេដែលមានមុខ៤នេះ ជាទន្លេពិតក្នុងសម័យនោះ ហើយក៏ជាការប្រៀបធៀបន័យថាជាទន្លេមួយ ដែលផ្សារភ្ជាប់មនុស្សក្នុងប្រវត្តិសាស្ត្រតាំងពីដើមដល់ចប់ ទៅនឹងព្រះដែលជាប្រភពដើមនៃជីវិតទាំងអស់។

លោកុប្បត្តិ គឺជាកណ្ឌគម្ពីរដែលប្រៀបដូចជា មុខទន្លេដ៏ធំនេះដែរ។ អ្នករាល់គ្នានឹងរីករាយក្នុងការសិក្សាពីប្រភពដើមដែលរកឃើញក្នុងកណ្ឌគម្ពីរនេះ ដ្បិតវានឹងធ្វើឱ្យអ្នកដឹងរឿងគ្រប់យ៉ាង ពេលអ្នករាល់គ្នាសិក្សាព្រះបន្ទូលព្រះ។ ចូររីករាយនឹងបទពិសោធន៍ដែលអ្នករាល់គ្នាទទួលបានចុះ ហើយសូមឱ្យការសិក្សានេះ ក្លាយជាទន្លេទឹករស់ដែលចម្អែតភាពស្រេកឃ្លាននៃព្រលឹងរបស់អ្នករាល់គ្នាផង (យ៉ូហាន ៤:១០)។

ដល់ពេលដែលត្រូវចាប់ផ្ដើមធ្វើដំណើរផ្សងព្រេងហើយ! ចូរបើកព្រះគម្ពីររបស់អ្នក លោកុប្បត្តិ ១ ចូរយើងរាល់គ្នាចាប់ផ្ដើមពីជំពូក១ ខ១។ ចូរសរសេរពាក្យពាម៉ាត់ដំបូងគេ៖

---


©2013 CrossConnect Ministries

## ផ្នែកទី១

សេចក្តីផ្តើម៖ មេរៀននេះផ្តល់ឱកាសឱ្យអ្នករាល់គ្នាសម្លឹងមើលដំណើររឿងកំណើតផែនដី នៅក្នុងព្រះគម្ពីរ ឱ្យកាន់តែជិត។ គោលបំណងនៃមេរៀននេះ មិនមែនដើម្បីជជែកវែកញែក ឬឈ្លោះប្រកែកគ្នានោះទេ ប៉ុន្តែ គឺដើម្បីចោទសួរនូវសំណួរដែលនាំអ្នករាល់គ្នាឆ្លងកាត់តាមរយៈការរៀនមេរៀននេះ ទាំងផ្តល់ព័ត៌មានឱ្យអ្នករាល់គ្នា ទាក់ទងនឹងអ្វីដែលព្រះទ្រង់មានបន្ទូលអំពីការបង្កើតផ្ទៃមេឃ និងផែនដី។ ហេតុនេះ សូមអ្នករាល់គ្នារៀនសូត្រតាមសប្បាយ!

គេហកិច្ច៖ ចូរអានជំពូក២ដំបូង ក្នុងកណ្ឌគម្ពីរលោកុប្បត្តិ គឺលោកុប្បត្តិ ១-២

លំហាត់៖

១. តើលោកុប្បត្តិ ១:១ ប្រាប់អ្វីខ្លះដល់យើង?

ក. ______________________________

ខ. ______________________________

បទគម្ពីរនេះប្រាប់យើងថា ព្រះជាម្ចាស់ គឺជាព្រះអាទិករ ហើយផ្ទៃមេឃ និងផែនដី គឺទ្រង់បានបង្កើតមក។ ដំបូងចូរយើងយកចិត្តទុកដាក់ចំពោះកត្តាមួយដែលថែងថា ព្រះជាម្ចាស់ ជាព្រះអាទិករ។

២. មានខគម្ពីរយោងចំនួន៣ទៀតខាងក្រោម ដែលសរសេរបញ្ជាក់អំពីរឿងនេះម្តងទៀតថា ព្រះជាម្ចាស់ទ្រង់ជាអ្នកបង្កើត៖

ក. ទំនុកដំកើង ១០២:២៥ រៀបរាប់អំពីព្រះជាម្ចាស់ ដោយសរសេរថា "______________________________
______________________________"

ខ. ទំនុកដំកើង ១១៥:១៥ ក៏បញ្ជាក់ផងដែរថា ព្រះអម្ចាស់គឺជា "______________________________
______________________________"

គ. ទំនុកដំកើង ១៤៨:៥ខ ថែងថា "ដ្បិតទ្រង់ ______________________________
ហើយរបស់ទាំងនោះបាន ______________________________"

ការសញ្ជឹងគិត៖ ចូរចាប់ផ្តើមកត់ត្រាគំនិតរបស់អ្នករាល់គ្នា

១. តើពាក្យដែលថា "ព្រះជាម្ចាស់ ជាព្រះអាទិករ" មានន័យយ៉ាងណាចំពោះខ្ញុំ? ______________________________
______________________________

២. ចូរចំណាយពេលមួយភ្លែត ដើម្បីពិចារណាអំពីរបស់មួយដែលអ្នកបានបង្កើតមក ជាវត្ថុដែលធ្វើពីក្រណាត់ ឬធ្វើពីឈើក៏បាន។ ក្នុងជាអ្នកបង្កើតវត្ថុទាំងនេះ អ្នកចំណាយទាំងគំនិត និងការយកចិត្តទុកដាក់ចំពោះអ្វីដែលអ្នកបានបង្កើតមកនោះ។ ចូរចំណាយពេលគិតពិចារណាពេលដែលព្រះជាម្ចាស់ធ្វើការ ទ្រង់រៀបចំគម្រោងរបស់ព្រះអង្គក្នុងការបង្កើតផ្ទៃមេឃ និងផែនដី។ ពេលអ្នកស្រមៃមើលព្រះជាម្ចាស់ធ្វើផែនការរបស់ទ្រង់យ៉ាងយកចិត្តទុកដាក់ តើអ្នកមានគំនិតយ៉ាងណាខ្លះ? ______________________________
______________________________

 ©2013 CrossConnect Ministries

## ផ្នែកទី២

**គេហកិច្ច៖** ចូរអានលោកុប្បត្តិ ១:១-២ សារជាថ្មី។

**លំហាត់៖**

១. មុនពេលព្រះជាម្ចាស់បានបង្កើតផ្ទៃមេឃ និងផែនដី តើព្រះគម្ពីរចែងថា ផ្ទៃមេឃ និងផែនដីមានរូបរាងបែបណា (លោកុប្បត្តិ ១:២)?

ក. ______________________________

ខ. ______________________________

គ. ______________________________

ឯផែនដីបានខូច ហើយនៅទទេ មានសុទ្ធតែងងឹតគ្របលើ... ពាក្យទាំងនេះស្តាប់ទៅគួរឱ្យខ្លាច មែនទេ? បើនៅទទេ ហើយងងឹត មិនពិបាកយល់ទេ ប៉ុន្តែ "បានខូច" មានន័យដូចម្តេច? ការបកប្រែគម្ពីរខ្លះរៀបរាប់អំពីកាលដើមដំបូងថា វាជាពេលចលាចល ហើយទទេស្អាត គ្មានអ្វីទាំងអស់ អ្នកខ្លះទៀតគិតថា វាច្របូកច្របល់ឥតសណ្តាប់ធ្នាប់។ នេះជាការកត់សម្គាល់ដ៏គួរឱ្យចាប់អារម្មណ៍ណាស់ ដ្បិតពេលមានចលាចល ឥតសណ្តាប់ធ្នាប់ ហើយទទេស្អាត ព្រះជាម្ចាស់ក៏សម្រេចព្រះទ័យធ្វើការរបស់ទ្រង់។

១. តើលោកុប្បត្តិ ១:២ ប្រើពាក្យពេចន៍អ្វីមកពន្យល់ឱ្យអ្នកអានយល់ពីព្រះវត្តមានរបស់ព្រះជាម្ចាស់ នៅក្នុងសម័យកាលដើមដំបូង? ______________________________

ព្រះវិញ្ញាណនៃព្រះបានគង់នៅរួចហើយ។ ខគម្ពីរនេះប្រាប់យើងថា ព្រះវិញ្ញាណនៃព្រះ "រេរានៅពីលើ" ផ្ទៃទឹក។ មានញាណមួយប្រាប់ថា នឹងមានរឿងសំខាន់មួយបម្រុងនឹងកើតឡើង រូបភាពនេះប្រៀបដូចជាវត្តមានឪពុកម្តាយដែលកំពុងរង់ចាំកូនដែលហៀបនឹងកើត។

២. តើអ្នកអាចប្រើរូបភាព ឬពាក្យពេចន៍អ្វីខ្លះទៀតមករៀបរាប់អំពីការរេរារបស់ព្រះវិញ្ញាណនៃព្រះ? គម្ពីរ ចោទិយកថា និងគម្ពីរអេសាយ អាចជួយអ្នករាល់គ្នាបាន។ តោះយើងនាំគ្នាអាន!

ក. ចោទិយកថា ៣២:១១ ______________________________

ខ. អេសាយ ៣១:៥ ______________________________

**ការសញ្ជឹងគិត៖** ព្រះជាម្ចាស់កំពុងរេរាលើវត្ថុដែលបានខូច នៅទទេ មានតែភាពងងឹត។ តើជីវិតខ្ញុំមានអារម្មណ៍ថាបានខូច នៅទទេ មានតែភាពងងឹត ពីពេលណា? ______________________________

______________________________

ក្នុងពេលនោះ តើមានភាពខុសប្លែកអ្វីខ្លះដែលធ្វើឱ្យខ្ញុំទទួលស្គាល់ព្រះវត្តមានដ៏យកចិត្តទុកដាក់របស់ព្រះ ដែលតែងរេរាឃ្លាំមើលជីវិតខ្ញុំ ______________________________

**ការអធិស្ឋាន៖** ឱព្រះអម្ចាស់អើយ ខ្ញុំសូមអរព្រះគុណទ្រង់ចំពោះព្រះវត្តមានរបស់ទ្រង់ ដែលបានគង់តាំងពីមុនកំណើតផែនដី។ ទ្រង់នៅតែរេរាឃ្លាំមើលសព្វសារពើដែលទ្រង់បានបង្កើត។ អរព្រះគុណទ្រង់ចំពោះការយកចិត្តទុកដាក់ចំពោះអ្វីដែលទ្រង់បានបង្កើត គឺស្នាព្រះហស្តរបស់ទ្រង់ និងអរព្រះគុណចំពោះការថែរក្សាទូលបង្គំ និងមនុស្សជាទីស្រឡាញ់របស់ទូលបង្គំ។ ______________________________


©2013 CrossConnect Ministries

## ផ្នែកទី៣

**គោលកិច្ច៖** សូមអាន លោកុប្បត្តិ ជំពូក១ សារឡើងវិញ។

**លំហាត់៖** ក្នុងជំពូកនេះ យើងសម្គាល់ឃើញថា ព្រះដ៏ជាព្រះអាទិករ ទ្រង់គ្រាន់តែមានបន្ទូល នោះគ្រប់ទាំងអស់ក៏កើតមានឡើង លោកុប្បត្តិ ១:៣ គឺជាឧទាហរណ៍ស្រាប់។ នៅក្នុងទំនុកដំកើង ១៤៨:៥ "...ដ្បិតទ្រង់______________ ហើយរបស់ទាំងនោះ ____________________________ ។"

១. ចូររៀបរាប់អំពីរបស់ដែលព្រះជាម្ចាស់បានបង្កើតមក ដោយគ្រាន់តែមានបន្ទូល
   ក. ថ្ងៃទី១៖ លោកុប្បត្តិ ១:៣-៥ ________________________________________
   ________________________________________________________________
   ខ. ថ្ងៃទី២៖ លោកុប្បត្តិ ១:៦-៨ ________________________________________
   ________________________________________________________________
   គ. ថ្ងៃទី៣៖ លោកុប្បត្តិ ១:៩-១៣ _______________________________________
   ________________________________________________________________
   ឃ. ថ្ងៃទី៤៖ លោកុប្បត្តិ ១:១៤-១៩ ______________________________________
   ________________________________________________________________
   ង. ថ្ងៃទី៥៖ លោកុប្បត្តិ ១:២០-២៣ ______________________________________
   ________________________________________________________________
   ច. ថ្ងៃទី៦៖ លោកុប្បត្តិ ១:២៤-២៧ ______________________________________
   ________________________________________________________________

២. ចូរកត់សម្គាល់នូវការបង្គាប់ខ្លះៗ និងព្រះពរដែលទ្រង់បានប្រទានឱ្យទៅរបស់ដែលទ្រង់បានបង្កើត។ ឧទាហរណ៍ នៅក្នុងខ៣ ទ្រង់ "ញែក" ពន្លឺ និងងងឹត។ នៅក្នុងខ៩ ទ្រង់ "ប្រមូល" ទឹកដាក់មួយកន្លែង។ នៅក្នុងខ២០ ទ្រង់ "ប្រទានពរ" សព្វសារពើដែលទ្រង់បង្កើត ទាំងប្រាប់វាឱ្យបង្កើតកូនចៅឱ្យច្រើនឡើង។

៣. មានពាក្យពាឃ្លាដែលបានលេចឡើងច្រើនសារនៅក្នុងជំពូក១។ ចូររកមើលពាក្យទាំងនេះ ហើយសម្គាល់មើលថាតើឃ្លានីមួយៗត្រូវបានគេប្រើប៉ុន្មានដង។
   ក. "នោះព្រះទ្រង់មានបន្ទូលថា..." _____ ដង
   ខ. "ដូច្នេះ... ក៏មានឡើង" _____ ដង
   គ. "ព្រះទ្រង់ឃើញ... ... ក៏យល់ថាជាល្អហើយ" _____ ដង

៤. យោងតាមឃ្លាដដែលៗទាំងនេះ តើយើងបានដឹងអ្វីខ្លះទាក់ទងនឹងព្រះជាម្ចាស់?
   ក. ____________________________________________________________
   ខ. ____________________________________________________________
   គ. ____________________________________________________________

ព្រះជាម្ចាស់ទ្រង់ជាព្រះអាទិករ ទ្រង់គ្រាន់តែមានបន្ទូល នោះសព្វសារពើក៏កើតមានឡើង។ អ្វីៗដែលទ្រង់បង្កើតមកសុទ្ធតែល្អ គឺល្អណាស់តែម្តង (លោកុប្បត្តិ ១:៣១)។


©2013 CrossConnect Ministries

សំណួរពិចារណា៖

១. ពេលខ្ញុំស្រមៃមើលថា ព្រះជាម្ចាស់ជាព្រះអាទិករ តើខ្ញុំអាចមើលទ្រង់ធ្វើការបង្កើត និងថែរក្សាសព្វសារពើដែលទ្រង់បានបង្កើតមកនេះ នៅពេលណា កន្លែងណា?

២. ជួនកាលតើខ្ញុំគិតថា ទ្រង់បាន "ទម្លាក់" បាល់ចោល ហើយបោះបង់ចោលលោកិយដែលទ្រង់បង្កើតឡើងមកដែរឬទេ? ក្នុងនាមជាព្រះដែលថែរក្សារបស់ដែលទ្រង់បានបង្កើតមក តើខ្ញុំដឹងអ្វីខ្លះអំពីព្រះអង្គ?

ក. កូល៉ុស ១:១៦, ១៧ ____________________

ខ. ម៉ាថាយ ៦:២៥-៣៤ ____________________

## ជីកឱ្យកាន់តែជ្រៅ

១. ព្រះជាម្ចាស់ទ្រង់គង់នៅតាំងពីមុនកំណើតលោកិយមកម្ល៉េះ គ្មាននរណាបង្កើតទ្រង់ឡើយ ទ្រង់គង់នៅអស់កល្បជានិច្ច។ ទ្រង់មានព្រះជន្មតាំងពីដើម មកទល់បច្ចុប្បន្ន និងជរាបអស់កល្បជានិច្ច។ នៅក្នុងវិវរណៈ ១:៨ ចែងថាទ្រង់ជា ______ និងជា ______ ។ នៅក្នុងវិវរណៈ ២១:៦ ក៏ចែងថា ទ្រង់ជា ______ និងជា ______ ដែរ។

២. គ្រប់យ៉ាងសុទ្ធតែមានការចាប់ផ្ដើម ដ្បិតមនុស្សជាតិជាប់ក្នុងអន្ទាក់នៃពេលវេលា។ ចូរនឹកគិតអំពីហេតុការណ៍ខ្លះដែលបានកើតឡើងចំពោះអ្នករាល់គ្នា អ្នករាល់គ្នាអាចរកនឹកអំពីថ្ងៃកំណើត ថ្ងៃបើកបរវេសនកាល ឬពេលដែលអ្នកចាប់ផ្ដើមគិតអ្វីមួយជាដើម។ ចំណែកព្រះជាម្ចាស់វិញ ទ្រង់គង់នៅមុនកំណើតលោកិយ គឺទ្រង់បានគង់នៅជាយូរមកហើយ។

សំណួរពិចារណា៖

១. តើគំនិតអ្វីខ្លះដែលធ្វើឱ្យអ្នករាល់គ្នាពិបាកយល់ ពេលអ្នកពិចារណាថា ព្រះជាម្ចាស់ ទ្រង់គង់នៅអស់កល្បជានិច្ច ទ្រង់ជាអាលផា និងអូមេកា ជាដើម ហើយក៏ជាចុង? ____________________

____________________

២. តើគំនិតអ្វីខ្លះដែលធ្វើឱ្យអ្នករាល់គ្នាបានក្សាន្តចិត្ត ពេលអ្នកពិចារណាថា ព្រះជាម្ចាស់គង់នៅអស់កល្បជានិច្ច?

____________________

ការអធិស្ឋាន៖ ឱព្រះអម្ចាស់អើយ! ថ្ងៃនេះ ទូលបង្គំសូមអរព្រះគុណទ្រង់ ដែលទ្រង់បានបង្កើតសព្វសារពើ។ ទ្រង់បានសម្រេចព្រះទ័យបង្កើតផ្ទៃមេឃ និងផែនដី តាំងពីដើមរៀងមក។ គ្រប់យ៉ាងដែលទ្រង់បានបង្កើតមក គឺសុទ្ធតែល្អ។ សូមអរព្រះគុណទ្រង់! ____________________

## ផ្នែកទី៤

គេហកិច្ច៖ លោកុប្បត្តិ ២:១ ចែងថា ផ្ទៃមេឃ និងផែនដីក៏បានរួចជាស្រេច ព្រមទាំងរបស់សព្វសារពើផង។ ហេតុនេះចូរយើងអានខទី២ និងទី៣ រួចសរសេរខគម្ពីរទាំងនេះឡើងវិញ៖ ____________________

____________________

____________________

លំហាត់៖ តើមានអ្វីកើតឡើងនៅថ្ងៃទី៧ (លោកុប្បត្តិ ២:២-៣)? ចូររៀបរាប់ ____________________

____________________


©2013 CrossConnect Ministries

សេចក្តីបង្រៀន៖ ព្រះជាម្ចាស់ប្រទានពរដល់ថ្ងៃទី៧ និងរាប់ថ្ងៃនោះជាបរិសុទ្ធ ដោយសម្រាកពីកិច្ចការដែលទ្រង់ធ្វើ។ ទ្រង់បានញែកថ្ងៃនោះជាបរិសុទ្ធ ទ្រង់បានញែកថ្ងៃនោះទុកសម្រាប់គោលបំណងដ៏ពិសេសមួយ គឺសម្រាក។

- និយមន័យ៖ ញែកបរិសុទ្ធ មានន័យថា រាប់ជាបរិសុទ្ធ ឬរាប់ជាពិសិដ្ឋ
- និយមន័យ៖ ថ្ងៃសប្ប័ទ ជាថ្ងៃថ្វាយបង្គំ ឬថ្ងៃសម្រាក។ ចំណាំ៖ សម្រាប់សហគមន៍ជនជាតិយូដា ថ្ងៃសៅរ៍ ត្រូវបានចាត់ទុកជាថ្ងៃសប្ប័ទ យ៉ាងណាមិញ គ្រីស្ទបរិស័ទជំនាន់ដើម សម្រេចជ្រើសយកថ្ងៃអាទិត្យ ដើម្បីរំឭកដល់ការរស់ឡើងវិញរបស់ព្រះយេស៊ូវ។ អ្វីដែលសំខាន់មិនមែនស្ថិតលើការកំណត់ថាថ្ងៃនោះទេ អ្វីដែលសំខាន់ គឺត្រូវកំណត់យកថ្ងៃណាមួយ ក្នុងអំឡុងមួយសប្តាហ៍ ទុកជាថ្ងៃសប្ប័ទ ថ្ងៃសម្រាក។

ព្រះជាម្ចាស់បានបង្កើតជីវិតឡើងមក តាមលំដាប់លំដោយ។ តើព្រះជាម្ចាស់ត្រូវការសម្រាក១ថ្ងៃដែរមែនទេ? តើព្រះជាម្ចាស់នឿយហត់ អស់កម្លាំងមែនទេ? ក្នុងនាមជាព្រះនៃសម្ពន្ធភាព ទ្រង់បានសម្រេចព្រះទ័យសម្រាក លំហែរជាមួយនឹងជីវិតដែលទ្រង់បានបង្កើតមក មនុស្សខ្លះគិតថា ទ្រង់គ្រាន់តែចង់អបអរសាទរតែប៉ុណ្ណោះ។ លោកុប្បត្តិ ១:៣១ ចែងថា រួចព្រះទ្រង់បានទតគ្រប់ទាំងរបស់ដែលទ្រង់បានធ្វើនោះ ក៏ឃើញថា ទាំងអស់ជាការល្អប្រពៃ។ មានអ្នកខ្លះឆ្ងល់ថា តិចលោទ្រង់ទតមើលមកដើមឈើ សត្វ ឬអ័ដាម និងអេវ៉ា រួចមានបន្ទូលដូច្នេះវិញថា "យើងធ្វើការងាររបស់យើងបានប្រពៃណាស់ ពេលយើងបង្កើតឯងមក!" ទេដឹង។

ក្នុងរយៈពេល៦ថ្ងៃ មនុស្សមានអភ័យឯកសិទ្ធិធ្វើការ ប៉ុន្តែនៅថ្ងៃទី៧ ពួកគេក៏មានអភ័យឯកសិទ្ធិឱ្យសម្រាកពីការងាររបស់គេដែរ។ ថ្ងៃទី៧នេះ ជាថ្ងៃដែលយើងត្រូវសាទរនឹងរបស់ដែលទ្រង់បានបង្កើត ហើយយកចិត្តទុកដាក់ចំពោះសម្ពន្ធភាពដែលយើងជាមួយទ្រង់។ ថ្ងៃនេះជាថ្ងៃដែលត្រូវញែកទុកសម្រាប់ការថ្វាយបង្គំ នៅពេលយើងយកចិត្តទុកដាក់ចំពោះសម្ពន្ធរបស់យើងជាមួយនឹងព្រះ។ ព្រះជាម្ចាស់ជ្រាបថា យើងត្រូវការពេលវេលាថ្វាយបង្គំទ្រង់ ដើម្បីរក្សាសម្ពន្ធភាពរវាងព្រះដែលបង្កើតអ្វីៗទាំងអស់ និងជីវិតដែលទ្រង់បានបង្កើតមក ឱ្យមានការគិតពិចារណាត្រឹមត្រូវ ទ្រង់ក៏ជ្រាបដែរថា យើងត្រូវឱ្យរូបកាយ និងគំនិតរបស់យើងសម្រាក១ថ្ងៃ ដើម្បីឱ្យយើងធ្វើការងារបានល្អ នៅក្នុងរយៈពេល៦ថ្ងៃទៀត ហើយទ្រង់ក៏ជ្រាបទៀតថា យើងត្រូវការពេលវេលាសម្រាកលំហែរជាមួយគ្រួសារ មិត្តភ័ក្តិ ព្រមទាំងអ្នកជិតខាងដែលនៅក្នុងសហគមន៍របស់យើង។ ជាចុងក្រោយ ទ្រង់ចង់ឱ្យយើងរីករាយក្នុងសម្ពន្ធភាពដែលទ្រង់បានប្រទានមកតាមរយៈធម្មជាតិ និងរបស់គ្រប់យ៉ាងដែលទ្រង់បានបង្កើតមក។

លំហាត់៖ ព្រះបន្ទូលព្រះមានចែងអំពីថ្ងៃសប្ប័ទ ដូច្នេះចូរយើងចំណាយពេលសិក្សាព្រះបន្ទូលរបស់ទ្រង់ ដែលមានចែងក្នុងបទគម្ពីរខាងក្រោម ដូចតទៅ៖

ក. និក្ខមនំ ១៦:២៣ ______________________________

ខ. ចោទិយកថា ៥:១២-១៥ ______________________________

គ. អេសាយ ៥៨:១៣-១៤ ______________________________

ការអនុវត្ត

១. ដោយបានដឹងស្រេចថា យើងត្រូវការសម្រាកដើម្បីថ្វាយបង្គំ ដូច្នេះ ក្នុងការរស់នៅរបស់អ្នក តើថ្ងៃសប្ប័ទ ឬថ្ងៃសម្រាក មានសណ្ឋានយ៉ាងដូចម្តេច? ______________________________

______________________________


©2013 CrossConnect Ministries

ពេលអ្នកពិចារណាអំពីសម្ពន្ធភាពរបស់អ្នក ចូរកំណត់រកការប្រែប្រួលមួយ ឬពីរចំណុច ដែលអ្នកចង់បាន ដើម្បីញែកថ្ងៃនោះទុកជាបរិសុទ្ធ។

ក. ពេលខ្ញុំពិចារណាអំពីសម្ពន្ធភាពរបស់ខ្ញុំ ជាមួយព្រះអាទិករ ខ្ញុំចង់ឱ្យមានការប្រែប្រួលដូចតទៅ៖ ______

______

ខ. ពេលខ្ញុំពិចារណាដឹងថា រូបកាយ និងគំនិតរបស់ខ្ញុំ ក៏ទ្រង់ជាអ្នកបង្កើតមកដែរ ខ្ញុំចង់ឱ្យមានការប្រែប្រួលដូចតទៅ៖ ______

គ. ពេលខ្ញុំពិចារណាអំពីសម្ពន្ធភាពរបស់ខ្ញុំជាមួយប្រជាជនក្នុងសហគមន៍ខ្ញុំ ជាពិសេសគឺ គ្រួសារ មិត្តភ័ក្តិ ព្រមទាំងធម្មជាតិទាំងអស់ នោះខ្ញុំចង់ឱ្យមានការប្រែប្រួលដូចតទៅ៖ ______

______

ការអធិស្ឋាន៖ ឱ្យព្រះជាម្ចាស់អើយ! ទ្រង់ជាព្រះអាទិករនៃទូលបង្គំ។ ទូលបង្គំសូមអរព្រះគុណចំពោះគ្រប់យ៉ាងដែលទ្រង់បានប្រទានមក។ ជារឿយៗ ទូលបង្គំឃើញថា ទូលបង្គំរវល់ធ្វើការ ១ថ្ងៃ ២៤ម៉ោង ៧ថ្ងៃ ក្នុង១សប្តាហ៍ ដោយឡែកព្រះបន្ទូលទ្រង់រំឭកទូលបង្គំថា ទូលបង្គំត្រូវការសម្រាក១ថ្ងៃ ដើម្បីឱ្យទូលបង្គំអាចថ្វាយបង្គំ និងរក្សាចំណងសម្ពន្ធភាពដែលទូលបង្គំមានជាមួយអ្នកដទៃ រួមទាំងខ្លួនទូលបង្គំផ្ទាល់។ សូមជួយឱ្យទូលបង្គំទទួលសម្ពន្ធភាពនេះ ទុកជាអំណោយទាននៃសេចក្តីស្រឡាញ់ដែលទ្រង់ប្រទានមក ទាំងជួយឱ្យទូលបង្គំស្វះស្វែងដើម្បីឱ្យបានអំណោយទាននេះ ដោយដួងចិត្តកត្តញ្ញូ។ សូមឱ្យទូលបង្គំបានសម្រាក នៅក្នុងព្រះអង្គផង ______

______

## ផ្នែកទី៥

សេចក្តីបង្រៀន៖ នៅក្នុងលោកុប្បត្តិ ១:២៦ ព្រះជាម្ចាស់មានបន្ទូលថា "ចូរយើងធ្វើមនុស្សឱ្យដូចជារូបយើង..." បទគម្ពីរបានរៀបរាប់អំពីដំណើររឿងនៃការបង្កើតអ័ដាម និងអេវ៉ា យ៉ាងវែងអន្លាយ។ ជំពូកទី១ និងទី២ រៀបរាប់អំពីរឿងនេះខុសគ្នា ពីព្រោះរឿងទាំងពីរនេះត្រូវបានសរសេរក្នុងចេតនា និងបំណងខុសគ្នាដែរ។ ចូរយើងចាប់ផ្តើម ដោយសម្គាល់មើលព័ត៌មានខ្លះៗទាក់ទងទៅនឹងការបង្កើតមនុស្សប្រុស និងមនុស្សស្រី។

លំហាត់៖

១. តើអ្នករាល់គ្នារកឃើញអ្វីខ្លះទាក់ទងនឹងការបង្កើតមនុស្ស តាមរយៈបទគម្ពីរខាងក្រោមនេះ? ចូរព្យាយាមកំណត់រកសេចក្តីពិតដែលត្រូវបានបើកសម្តែង ទាក់ទងនឹងការបង្កើតមនុស្សប្រុស និងមនុស្សស្រី។

**លោកុប្បត្តិ ១៖** ចំណាំ៖ ពាក្យថា "មនុស្ស" សំដៅទាំង ______ និង ______ ("គេ" - ខ២៧)។

ក. ខ២៦ - ______

______

ខ. ខ២៧ - ______

គ. ខ២៨ - ______

______

ឃ. ខ២៩ - ______

______

**លោកុប្បត្តិ ២៖** ចូរព្យាយាមស្វែងរកសេចក្តីពិតដែលត្រូវបានបើកសម្តែងអំពីការបង្កើតមនុស្សប្រុស និងមនុស្សស្រីម្តងទៀត នៅក្នុងជំពូកនេះ។ តើមនុស្សប្រុសឈ្មោះអ្វី? ___________ (លោកុប្បត្តិ ២:២០) តើមនុស្សស្រីឈ្មោះអ្វី? _____________ (លោកុប្បត្តិ ៣:២០)

ក. ខ៥ - ______________________________

ខ. ខ៧ - ______________________________

គ. ខ១៨ - ______________________________

ឃ. ខ២០ - ______________________________

ង. ខ២១ - ______________________________

ច. ខ២២ - ______________________________

ឆ. ខ២៣ - ______________________________

សេចក្តីបង្រៀន៖ លោកុប្បត្តិ ១:២៧ ចែងថា ទាំងមនុស្សប្រុស និងមនុស្សស្រី សុទ្ធតែត្រូវបានបង្កើតមកតាមរូបអង្គព្រះជាម្ចាស់ ន័យនេះជារូបភាពមួយបញ្ជាក់ប្រាប់យើងយ៉ាងច្បាស់ថា យើងជារបស់ដែលព្រះបង្កើត ទ្រង់ប្រទានឱ្យយើងនូវទំនួលខុសត្រូវក្នុងការឆ្លុះបញ្ចាំងពីរូបអង្គរបស់ទ្រង់ ដល់របស់ទាំងអស់ដែលទ្រង់បង្កើត គឺជាកញ្ចក់ឆ្លុះបញ្ចាំងរូបភាពព្រះភ័ក្ត្រព្រះអង្គ។ ផែនការរបស់ទ្រង់ គឺឱ្យមនុស្សធ្វើជាកញ្ចក់ឆ្លុះបញ្ចាំងឱ្យលោកិយទាំងមូល មើលឃើញព្រះអង្គ ដ្បិតមនុស្សលោកកើតមកដោយមានរូបអង្គទ្រង់ ហើយយើងសឱ្យឃើញរូបអង្គនេះ នៅពេលដែលយើងធ្វើការងារ ចូលរួមក្នុងសង្គម ធ្វើការសម្រេចចិត្ត ផ្តល់ក្តីស្រឡាញ់ ថ្វាយបង្គំ ហើយរស់ក្នុងសម្ពន្ធភាពជាមួយនឹងទ្រង់។ ព្រះជាម្ចាស់ទ្រង់បានប្រទានគោលបំណង និងអត្ថន័យជីវិតដល់មនុស្ស ដោយត្រាស់ហៅពួកគេ ហើយប្រទានឱ្យគេនូវទំនួលខុសត្រូវក្នុងការស្តែងឱ្យលោកិយមើលឃើញព្រះអង្គ។

សំណួរ៖ នៅក្នុងលោកុប្បត្តិ ១:២៨ តើព្រះជាម្ចាស់ប្រទានព្រះពរអ្វីខ្លះដល់ពួកគេ?

១. ចូរ ______________________________

២. ត្រូវ ______________________________ ផែនដី

៣. ហើយ ______________ លើត្រីសមុទ្រ សត្វហើរលើអាកាស និងជីវិតផងទាំងឡាយដែលកំរើកនៅផែនដីផង។

សំណួរពិចារណា៖

១. តើអ្វីទៅ ឬតើអ្នកណាដែលផ្តល់នូវគោលបំណង និងអត្ថន័យដល់ជីវិតរបស់អ្នករាល់គ្នា? ______________________________

២. ពេលអ្នករាល់គ្នាសញ្ជឹងគិតអំពី លោកុប្បត្តិ ១:២៧-២៨ តើអ្នករាល់គ្នាជឿថា ព្រះជាម្ចាស់បានប្រទានគុណតម្លៃអ្វីខ្លះ ក្នុងជីវិតអ្នករាល់គ្នា? ______________________________

៣. តើអ្នករាល់គ្នាដឹងខ្លួនឯង (ជាជីវិតដែលព្រះបានបង្កើត) ជាប់នៅក្នុងចំណងទាក់ទងជាមួយនឹងព្រះ ដោយធ្វើការរួមគ្នាជាមួយនឹងទ្រង់ (ជាព្រះអាទិករ) ពីពេលណាមក? ______________________________

៤. តើកត្តានេះនាំឱ្យមានភាពខុសប្លែកអ្វីខ្លះ នៅក្នុងជីវិតរបស់អ្នក បានជាអ្នករាល់គ្នាដឹងថា ព្រះជាម្ចាស់បានប្រទានព្រះពរដល់អ្នករាល់គ្នា ព្រមទាំងបានត្រាស់ហៅអ្នករាល់គ្នាឱ្យសម្តែងអង្គទ្រង់ ដល់លោកិយដែលអ្នកកំពុងរស់


©2013 CROSSCONNECT MINISTRIES

នៅយ៉ាងដូច្នេះ? ______________________________

______________________________

ជីកឱ្យកាន់តែជ្រៅ៖ ចូរសង្កេតមើលការយកចិត្តទុកដាក់ដ៏ជិតស្និទរបស់ព្រះ ដែលបានប្រទានមកមនុស្សដែលទ្រង់បានបង្កើត ទាំងប្រទានព្រះពរឱ្យពួកគេ ហើយត្រាស់ហៅពួកគេឱ្យឆ្លុះបញ្ចាំងពីរូបអង្គទ្រង់ តាមរយៈខគម្ពីរយោងដូចតទៅ៖

- ចូរចំណាយពេលអាន ទំនុកដំកើង ១៣៩។ ចូរយកចិត្តទុកដាក់ជាពិសេសចំពោះ ខ១៣-១៦ តើខគម្ពីរនេះផ្តល់នូវការយល់ដឹងអ្វីខ្លះ ទាក់ទងនឹងសម្ពន្ធភាពដែលព្រះជាម្ចាស់មានជាមួយនឹងជីវិតដែលទ្រង់បង្កើតមក មុនពេលដែលគេកើតមកទៀតនោះ? ______________________________

  ______________________________

- តើបទគម្ពីរ ទំនុកដំកើង ៨:៣-៩ ប្រាប់យើងអ្វីខ្លះអំពីតម្លៃរបស់យើងចំពោះព្រះអង្គ? ______________

  ______________________________

- តើបទគម្ពីរ ១របាក្សត្រ ២៩:១៤ ផ្តល់នូវការយល់ដឹងអ្វីខ្លះ នៅពេលយើងពិចារណាអំពីរបស់គ្រប់យ៉ាង ដែលយើងប្រកាសថាជារបស់ខ្លួន? ______________________________

ការអធិស្ឋាន៖ ឱព្រះជាម្ចាស់អើយ ទ្រង់មិនត្រឹមតែបង្កើតទូលបង្គំមកប៉ុណ្ណោះទេ ទ្រង់ថែមទាំងបានប្រទាននូវគោលបំណង និងអត្ថន័យដល់ជីវិតទូលបង្គំ ទុកជាព្រះពរទៀតផង។ ទ្រង់បានត្រាស់ហៅទូលបង្គំ ឱ្យធ្វើជាដៃគូក្នុងសម្ពន្ធភាពជាមួយនឹងទ្រង់ ហើយប្រទានឱ្យទូលបង្គំមានទំនួលខុសត្រូវក្នុងការឆ្លុះបញ្ចាំងអង្គទ្រង់ ដល់លោកិយដែលទ្រង់បានបង្កើតមក។ ទូលបង្គំសូមអរព្រះគុណទ្រង់ ដែលបានធ្វើការដោយព្រះចេស្តា នៅក្នុងជីវិតរបស់ទូលបង្គំ។

______________________________

______________________________

## ផ្នែកទី៦

សេចក្តីបង្រៀន៖ គម្ពីរលោកុប្បត្តិ ២:២៤ ណែនាំយើងឱ្យស្គាល់អាពាហ៍ពិពាហ៍។ ព្រះជាម្ចាស់ជាអ្នកផ្តួចផ្តើមឱ្យមានអាពាហ៍ពិពាហ៍តាំងតែពីដើមរៀងមក អាពាហ៍ពិពាហ៍ គឺជាហេតុផលដែលធ្វើឱ្យមនុស្សប្រុសចាកចេញពីឪពុកម្តាយខ្លួន ហើយទៅរួមរស់ជាសាច់តែមួយជាមួយនឹងភរិយា។

នៅក្នុងបទគម្ពីរនេះ យើងឃើញមានចែងថា អាពាហ៍ពិពាហ៍គឺជាការដែលមនុស្សពីរនាក់ក្លាយមកជាសាច់តែមួយ។ ពិធីអាពាហ៍ពិពាហ៍ មិនអាចធ្វើឱ្យបុគ្គលពីរនាក់ផ្សេងគ្នា រួមគ្នាមកតែមួយបានភ្លាមនោះទេ ប៉ុន្តែ វាជាដំណើរការនៃការរួមមកតែមួយ ហើយដំណើរការនេះនឹងបន្តរហូតពេញមួយជីវិតដែលគេរួមរស់ជាមួយគ្នា។ ដំណើរការនៃការរួមសាច់រួមឈាមមកតែមួយ ត្រូវបានបញ្ចប់ត្រឹមការរួមសង្វាស។ ខទី២៥ ចែងពីបុរស និងស្ត្រីជាដៃលភរិយា នៅអាក្រាតទាំងពីរនាក់ ហើយពុំមានអារម្មណ៍ខ្មាសអៀនទេ។ ភាពអាក្រាតដែលមនុស្សទាំងប្រុសទាំងស្រីមាន គឺជាចេតនាដ៏ល្អ និងពេញដោយព្រះគុណរបស់ព្រះជាម្ចាស់ ពេលទ្រង់បានបង្កើតស្ត្រីមក ហើយយកនាងទៅឱ្យបុរស ទុកជាភរិយា។

លំហាត់៖

១. បទគម្ពីរ១ទៀត ដែលមានចែងអំពីអាពាហ៍ពិពាហ៍ ដកស្រង់ចេញពីព្រះបន្ទូលរបស់ព្រះយេស៊ូវ នៅក្នុងបទគម្ពីរម៉ាថាយ ១៩:៦។ ចូរបើករកបទគម្ពីរនេះ រួចសរសេរ៖ ______________________________

______________________________


©2013 CrossConnect Ministries

២. យោងតាមបទគម្ពីរនេះ តើព្រះជាម្ចាស់មានចេតនាដូចម្តេចចំពោះអាពាហ៍ពិពាហ៍? ________________

________________________________________

**ជីកឱ្យកាន់តែជ្រៅ៖** ខគម្ពីរជាច្រើនសុទ្ធតែបញ្ជាក់ពីអាពាហ៍ពិពាហ៍ និងចេតនារបស់ព្រះជាម្ចាស់ ឱ្យមនុស្សប្រុស និងមនុស្សស្រីរួមរស់ជាមួយគ្នាក្នុងអាពាហ៍ពិពាហ៍។ ប្រសិនបើអ្នករាល់គ្នាចង់សិក្សាបន្ថែម មានខគម្ពីរយើងមួយចំនួន អាចនឹងមានប្រយោជន៍ដល់ការចាប់ផ្តើមសិក្សារបស់អ្នក។ ការប្រើប្រាស់នូវការបញ្ជាក់បន្ថែមក្នុងខគម្ពីរដោយឡែកពីគ្នា នឹងជួយនាំអ្នករាល់គ្នាឱ្យឈានទៅដល់ចំណែកមេរៀនសម្រាប់ពិចារណា។ ចូរកត់សម្គាល់ទាំងទំនួលខុសត្រូវរបស់ស្វាមី និងភរិយា៖

- អេភេសូ ៥:២១-៣៣
- ១កូរិនថូស ១៣ (គេតែងហៅថា ជំពូកដែលថែងពីក្តីស្រឡាញ់)
- ១ពេត្រុស ៣:១-៧

**រំឭក៖** នៅក្នុងមេរៀននេះ យើងបានសម្លឹងមើលព្រះជាម្ចាស់ក្នុងនាមជាព្រះអាទិករនៃផ្ទៃមេឃ និងផែនដី ហើយដឹងថាទ្រង់គង់នៅអស់កល្បជានិច្ច គ្មាននរណាបង្កើតទ្រង់មកទេ គឺទ្រង់មានព្រះជន្មគង់នៅតាំងតែពីដើមរៀងមក។ យើងថែមទាំងបានសម្គាល់មើលរយៈពេលដែលទ្រង់បង្កើតសព្វសារពើ បញ្ចប់ដោយថ្ងៃដ៏បរិសុទ្ធ ញែកទុកជាថ្ងៃដ៏វិសេសសម្រាប់ឈប់សម្រាក។ យើងបានសិក្សាលម្អិតអំពីការបង្កើតជីវិតមនុស្ស និងគោលបំណងដែលព្រះជាម្ចាស់បានសម្តែងចេញមកសម្រាប់ឱ្យពួកគេស្តែងពីអង្គទ្រង់ឱ្យលោកិយបានឃើញ ហើយយើងក៏បានរៀនអំពីអាពាហ៍ពិពាហ៍ និងចេតនារបស់ព្រះជាម្ចាស់ ដែលចង់ឱ្យមនុស្សប្រុស និងមនុស្សស្រីត្រឡប់ជាសាច់តែមួយ។

ព្រះជាម្ចាស់បានបង្កើតសព្វសារពើមក ព្រមទាំងប្រកាសថា វាជាការប្រពៃណាស់ ហើយគ្រប់យ៉ាងក៏កើតមានឡើងស្រេចហើយ។ គ្រប់ទាំងអស់ គឺទ្រង់ជាអ្នករចនា ដើម្បីថ្វាយសិរីរុងរឿង និងកិត្តិយសដល់ទ្រង់។ ប៉ុន្តែនៅមានរឿងមួយទៀតគឺ...

**លំហាត់៖**

១. លោកុប្បត្តិ ២:៨-៩ ថែងថា ព្រះជាម្ចាស់បានបង្កើតសួនមួយឈ្មោះថា ______________ ។ មានដើមឈើពីរដើម ដាំនៅចំកណ្តាលសួន ដើមនោះឈ្មោះថា៖

   ក. ________________________________________

   ខ. ________________________________________

២. នៅក្នុងខទី១៥ ព្រះជាម្ចាស់បានយកមនុស្សទៅដាក់ក្នុងសួនអេដែន។ តើទ្រង់បានទូន្មានអ្វីខ្លះដល់គេ?

   ________________________________________

៣. ពាក្យបង្គាប់តែមួយ ដែលព្រះជាម្ចាស់មានសម្រាប់មនុស្ស តើជាអ្វី? ចូរសរសេរ ខទី១៦ និង១៧៖ ________

   ________________________________________

   ________________________________________

៤. តើលទ្ធផលនៃការមិនស្តាប់បង្គាប់ដែលព្រះមានបន្ទូល គឺជាអ្វី? ______________________________

**ការសញ្ជឹងគិត៖** ការដែលព្រះជាម្ចាស់ដាក់ "ដើមឈើដឹងខុសត្រូវ" នៅក្នុងសួន ដំបូងហាក់ដូចជាមិនយុត្តិធម៌សោះ។ ដើមឈើជាដើមឈើដែលព្រះបានហាម ហើយដុះមកសម្រាប់ជាការល្បួងដល់អ័ដាម និងអេវ៉ា។ ប៉ុន្តែ ព្រះជាម្ចាស់ទ្រង់

បានបង្កើតមនុស្សមកមានឆន្ទៈ ដែលអាចឱ្យពួកគេសម្រេចចិត្តមិនស្ដាប់តាមព្រះបន្ទូលរបស់ទ្រង់។ ពួកគេបានបង្ហាញនូវសេចក្ដីស្រឡាញ់ចំពោះទ្រង់ ដោយការស្ដាប់បង្គាប់។ ដើមឈើនេះ ដុះនៅចំកណ្ដាលសួន វត្ថុមានជីវិតដទៃទៀត រស់នៅជុំវិញសួន ដោយឡែកព្រះជាម្ចាស់ចង់ឱ្យជីវិតយើងនៅចំកណ្ដាលព្រះបន្ទូលដ៏ល្អ និងពេញដោយសេចក្ដីស្រឡាញ់របស់ទ្រង់។ ដូច្នេះ តើការរស់នៅដោយយកព្រះបន្ទូលធ្វើជាបណ្ដូលជីវិតរបស់អ្នក មានន័យយ៉ាងចំពោះអ្នក?

ជាងនេះទៅទៀត ព្រះជាម្ចាស់មិនបានទាមទារឱ្យពួកគេស្រឡាញ់ទ្រង់នោះទេ សេចក្ដីស្រឡាញ់គ្រាន់តែជាជម្រើសមួយ ហើយដើមឈើគឺជាជម្រើសតែមួយដែលគេជ្រើសយក ដើម្បីឱ្យគេអាចបង្ហាញសេចក្ដីស្រឡាញ់របស់គេចំពោះទ្រង់។ ព្រះជាម្ចាស់បង្កើតរបស់គ្រប់យ៉ាង ទ្រង់ប្រទានគ្រប់យ៉ាងឱ្យគេ ឱ្យគេទទួលទានរបស់គ្រប់យ៉ាងនៅក្នុងសួន ហើយគ្រប់យ៉ាងដែលទ្រង់ប្រទានឱ្យគេដោយព្រះសប្បុរស មានតែដើមឈើនេះប៉ុណ្ណោះ ដែលទ្រង់បានហាម តើវាមិនមែនជារឿងដែលគួរឱ្យចាប់អារម្មណ៍ទេឬអី? ចុះអ្នករាល់គ្នាវិញ មានគំនិតយ៉ាងណាដែរ?

ការអនុវត្ត

១. អ្នករាល់គ្នាបានអានអំពីកំណើតផែនដី នៅក្នុងលោកុប្បត្តិ ជំពូកទី១ និងទី២រួចហើយ តើមានការយល់ដឹងអ្វីខ្លះដែលបានពង្រីកការគិតរបស់អ្នករាល់គ្នា?

២. តើអ្នករាល់គ្នានឹងជ្រើសរើសយកសកម្មភាពថ្មីអ្វីខ្លះ ដើម្បីបង្ហាញពីការយកចិត្តទុកដាក់របស់អ្នករាល់គ្នា ចំពោះវត្ថុដែលព្រះជាម្ចាស់បានបង្កើត?

តើការកែច្នៃសំណល់ ឬការដាំដើមឈើឡើងវិញ បង្ហាញនូវការថ្វាយកិត្តិយសដល់ព្រះដ៏ពេញដោយព្រះចេស្ដាជាព្រះដែលបង្កើតផ្ទៃមេឃ និងផែនដី តាមវិធីណាខ្លះ?

៣. ពេលអ្នករាល់គ្នាដឹងថា អ្នកត្រូវបានបង្កើតមក "យ៉ាងប្រុងប្រយ័ត្ន និងអស្ចារ្យ" (ទំនុកដំកើង ១៣៩) ចំពោះអ្នករាល់គ្នា តើអ្នករាល់គ្នាមានគំនិតថ្មីយ៉ាងណាខ្លះ?

៤. ពេលអ្នកសម្រេចចិត្តផ្ដោតគំនិត និងសកម្មភាពរបស់អ្នកលើព្រះបន្ទូលព្រះ តើជីវិតរបស់អ្នកនឹងចាប់ផ្ដើមស្ដែងឱ្យលោកិយមើលឃើញព្រះជាម្ចាស់ តាមវិធីណាខ្លះ?

ការអធិស្ឋាន៖ ចូរសរសេរនូវសេចក្ដីអធិស្ឋាន ដោយប្រាប់អំពីបំណងចិត្តរបស់អ្នក ក្នុងការស្ដែងឱ្យគេមើលឃើញព្រះជាម្ចាស់នៅក្នុងជីវិតរបស់អ្នក។

រឿងនេះបន្តទៅក្នុងលោកុប្បត្តិ ជំពូកទី៣ រៀបរាប់អំពីការសន្ទនានៅក្រោមដើមឈើ...


©2013 CrossConnect Ministries

# មេរៀនទី២

# តើមានបញ្ហាអ្វីកើតឡើង?

## លោកុប្បត្តិ ៣ - ការធ្លាក់ចុះរបស់មនុស្ស

### មាតិកាសំខាន់ៗក្នុងមេរៀនទី២

**ទិដ្ឋភាពទូទៅ៖ មេរៀនទី២**

**លំនាំដើម**

**មេរៀនទី២៖ លោកុប្បត្តិ ៣**

- សត្វពស់
- ជំនួប (រវាងសត្វពស់ និងមនុស្ស)
- ទង្វើមិនស្តាប់បង្គាប់
- ការប៉ងប្រាថ្នានៃអំពើបាប
- និយមន័យ
    - *ការរាប់ជាសុចរិត*
    - *ព្រះគុណ*
    - *ការប្រោសលោះ*
- លទ្ធផលនៃអំពើបាប
- ការតស៊ូចាប់ផ្តើម
- សេចក្តីសន្យារបស់ព្រះជាម្ចាស់
- ផលវិបាកនៃអំពើបាប
- ការយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ ចំពោះមនុស្សប្រុស និងមនុស្សស្រី
- អនុសាសន៍បញ្ចប់


©2013 CROSSCONNECT MINISTRIES

# លំនាំដើម

កណ្ឌគម្ពីរលោកុប្បត្តិមានការចាប់ផ្ដើមមួយផ្សេងទៀត រៀបរាប់ប្រាប់ដល់យើង នៅក្នុងជំពូកទី៣។ ព្រះជាម្ចាស់បង្គាប់ឱ្យគេបរិភោគផ្លែឈើទាំងអស់នៅក្នុងសួន ប៉ុន្តែ ទ្រង់មានបម្រាមមួយ គឺហាមមិនឱ្យគេបរិភោគផ្លែឈើដែលដុះនៅកណ្ដាលសួននោះឡើយ។ ទ្រង់មានបន្ទូលប្រាប់គេថា ប្រសិនបើគេបរិភោគផ្លែឈើនោះ គឺផ្លែឈើដឹងខុសត្រូវ នោះគេនឹងស្លាប់ជាមិនខានទេ។

ថ្ងៃមួយ ស្ដ្រីបានជួបនឹងការបញ្ឆោតរបស់សត្វពស់ និងការល្បួងឱ្យនាងទាក់ចិត្តនឹងផ្លែឈើដឹងខុសត្រូវនេះ ហើយនាងក៏បានបរិភោគ បន្ទាប់មកនាងក៏ចែកឈើនោះទៅឱ្យប្ដីរបស់ខ្លួនបរិភោគ ហើយគាត់ក៏បានបរិភោគដែរ។ ហេតុនេះ សេចក្ដីស្លាប់ក៏បានក្លាយជាចំណែកមួយនៃជីវិតមនុស្ស ជាលើកដំបូងចាប់ពីពេលនេះទៅ។ សេចក្ដីស្លាប់ក៏បានជ្រាបចូលក្នុងគ្រប់របស់ទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតមក។ សម្ពន្ធភាពដ៏គ្រប់លក្ខណ៍រវាងព្រះជាម្ចាស់ និងមនុស្ស ត្រូវបានបំផ្លាញ ឯសម្ពន្ធភាពរវាងមនុស្សប្រុស និងមនុស្សស្រី ក៏ត្រូវហិនហោចអស់ដែរ។ គ្រប់យ៉ាងដែលព្រះជាម្ចាស់បានបង្កើតត្រូវខូចបង់ដោយសារតែអំពើបាប ហើយហេតុការណ៍ទាំងនេះកើតឡើង ដោយសារតែការមិនស្ដាប់បង្គាប់របស់មនុស្សប្រុស និងមនុស្សស្រី។

ស្ថានការណ៍ដ៏លំបាកនេះ បានបង្កឱ្យយើងសួរសំណួរជាច្រើនថា៖ តើកត្តាអ្វីខ្លះដែលធ្វើឱ្យអ័ដាមមិនស្ដាប់តាមការបង្គាប់របស់ព្រះជាម្ចាស់? ហេតុអ្វីបានជាពួកគាត់ស្ដាប់តាមការបញ្ឆោតរបស់មារសាតាំង មិនស្ដាប់តាមសេចក្ដីពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅវិញ? តើការល្បួងនោះមានអ្វីខ្លះគួរឱ្យចាប់អារម្មណ៍ បានពួកគាត់បោះបង់បំណងព្រះទ័យនៃព្រះយ៉ាងដូច្នេះ? ដំបូង ម្ដេចបានជាទ្រង់បង្កើតដើមឈើនេះ រួចហាមពួកគាត់មិនឱ្យបរិភោគផ្លែវាទៅវិញ? ហេតុអ្វីបានជាទ្រង់ប្រកាសដាក់ទណ្ឌកម្មឱ្យពួកគេស្លាប់ ប្រសិនបើពួកគាត់មិនស្ដាប់បង្គាប់ យ៉ាងដូច្នេះ? តើហេតុផលដែលនាំឱ្យពួកគាត់ប្រព្រឹត្តអំពើបាប ជាកំហុសរបស់ព្រះជាម្ចាស់មែនទេ?

ទោះជាមានបញ្ហាកើតឡើងយ៉ាងនេះក៏ដោយក៏ព្រះជាម្ចាស់នៅតែបន្តស្រឡាញ់របស់ទាំងអស់ដែលទ្រង់បានបង្កើតមកដដែល។ នេះជាការចាប់ផ្ដើមថ្មីមួយ ហើយកណ្ឌគម្ពីរលោកុប្បត្តិចាប់ផ្ដើមរឿងមួយដែលបន្តរហូតដល់ចប់ចុងបញ្ចប់នៃបទគម្ពីរ។ រឿងនេះ ជាសង្គ្រាមដណ្ដើមព្រលឹងមនុស្ស ហើយអ្នកឈ្នះដែលព្រះជាម្ចាស់ចាត់ឱ្យមក គឺជាព្រះរាជបុត្រារបស់ទ្រង់ផ្ទាល់ ជាមនុស្សរស់ក្នុងជីវិតដែលរាស្ត្ររបស់ទ្រង់មិនអាចធ្វើបាន។ ព្រះរាជបុត្រាទ្រង់អង្គនេះ នឹងកាន់តាមគ្រប់ទាំងក្រឹត្យវិន័យយ៉ាងឥតខ្ចោះ។ ព្រះរាជបុត្រារបស់ទ្រង់នេះហើយ ដែលនឹងត្រូវរងទុក្ខវេទនាជាទីបំផុត ព្រមទាំងសុគតដើម្បីឱ្យអស់អ្នកណាដែលជឿដល់ទ្រង់ ថាទ្រង់ជាព្រះអង្គសង្គ្រោះពួកគេឱ្យរួចពីអំពើបាប និងសេចក្ដីស្លាប់ នោះពួកគេនឹងទទួលបានជីវិតអស់កល្បជានិច្ច។ សេចក្ដីស្រឡាញ់របស់ព្រះដ៏ជាព្រះវរបិតា គឺជាសេចក្ដីស្រឡាញ់ដែលបរិយាយមិនបាន និងពេញដោយព្រះចេស្ដា។ ព្រះចេស្ដានៃសេចក្ដីស្រឡាញ់ចំពោះមនុស្សនេះហើយ ដែលបានប្រោសឱ្យព្រះរាជបុត្រាទ្រង់រស់ឡើងវិញពីសុគត។ ការរស់ឡើងវិញនេះ ប្រទានឱ្យយើងនូវសេចក្ដីសង្ឃឹម។ ទាំងមារសាតាំង ទាំងការបញ្ឆោត និងល្បិចកិចកលទាំងប៉ុន្មានរបស់វា មិនអាចប្រៀបស្មើនឹងការស្ដាប់បង្គាប់របស់ព្រះរាជបុត្រាដ៏គ្រប់លក្ខណ៍ របស់ព្រះជាម្ចាស់បានឡើយ។ ឥឡូវនេះ កិច្ចការរបស់ព្រះវិញ្ញាណនៃព្រះ កំពុងតែកើតឡើងក្នុងចិត្ត និងគំនិតរបស់អស់អ្នកណាដែលជឿលើសេចក្ដីសន្យារបស់ព្រះ ដែលបានសន្យាថា ទ្រង់នឹងមិនឱ្យពួកគេវិនាសឡើយ គឺឱ្យមានជីវិតអស់កល្បជានិច្ចវិញ។


©2013 CrossConnect Ministries

## ផ្នែកទី១៖

ទំព្ញក៖ នៅថ្ងៃទី៦ ព្រះជាម្ចាស់បានបង្កើតមនុស្សប្រុស និងមនុស្សស្រី។ ព្រះអង្គបានប្រកាសថា គ្រប់ទាំងអស់ដែលទ្រង់បានបង្កើតមក សុទ្ធតែល្អ។ គ្រប់យ៉ាងដែលទ្រង់បានបង្កើតមក គឺទ្រង់បានត្រៀមសម្រាប់ពួកគេ ប្រទានឱ្យពួកគេ ហើយប្រើសម្រាប់ផ្គត់ផ្គង់ពួកគេ។ ផ្លែឈើទាំងអស់សុទ្ធតែ "គួរពិចពិលរមឹលមើល ហើយសម្រាប់ជាអាហារផង" (លោកុប្បត្តិ ២:៩) រួចទ្រង់ក៏មានបន្ទូលប្រាប់គេថា ផ្លែឈើទាំងអស់នេះ គឺសម្រាប់ឱ្យពួកគេបរិភោគ (លោកុប្បត្តិ ២:១៦)។

យ៉ាងណាមិញ ព្រះជាម្ចាស់ក៏បានដាំដើមឈើដឹងខុសត្រូវ នៅចំកណ្ដាលសួននោះដែរ ហើយទ្រង់បានហាមប្រាប់ទាំងមនុស្សប្រុស និងមនុស្សស្រី មិនឱ្យបរិភោគផ្លែឈើនេះទេ (លោកុប្បត្តិ ២:១៧)។ ព្រះជាម្ចាស់បានប្រាប់ពួកគេថា ប្រសិនបើពួកគេមិនស្តាប់តាមការបង្គាប់នេះទេ នោះពួកគេនឹងត្រូវស្លាប់។ បម្រាមនេះហាក់ដូចជាទំនងដែរ ពួកគេអាចបរិភោគផ្លែឈើទាំងអស់បាន លើកលែងតែផ្លែឈើមួយមុខប៉ុណ្ណោះ ដែលទ្រង់ហាមមិនឱ្យបរិភោគ វាសមរម្យណាស់ទៅហើយ។ ព្រះជាម្ចាស់បានផ្គត់ផ្គង់ដល់ការរស់នៅរបស់គេ ដោយព្រះទ័យសប្បុរស។

គេហកិច្ច៖ ចូរអានលោកុប្បត្តិ ជំពូកទី៣។ តើតួអង្គអ្វី ដែលត្រូវបានគេផ្តើមរៀបរាប់នៅក្នុងខទី១? ___________

លំហាត់៖

- ដើម្បីយល់ឱ្យកាន់តែច្បាស់អំពីសត្វពស់ ចូរអ្នកបើកមើលខគម្ពីរយោងខាងក្រោម រួចសរសេរនូវពាក្យពេចន៍ដែលគេប្រើ ក្នុងការរៀបរាប់អំពីសត្វមួយនេះ។

| ខគម្ពីរយោង | ការរៀបរាប់ |
|---|---|
| លោកុប្បត្តិ ៣:១ | |
| លូកា ៤:២ | |
| យ៉ូហាន ៨:៤៤ | |
| ២កូរិនថូស ១១:៣ | |
| អេភេសូ ៦:១១ | |
| ១ពេត្រុស ៥:៨ | |
| វិវរណៈ ១២:៩ | |

ការទន្ទេញចាំមាត់៖ ចូរកត់ចំណាំភាពផ្ទុយគ្នានៅក្នុង យ៉ូហាន ១០:១០ សាតាំងត្រូវបានរៀបរាប់ថាជា _________ ដែលមកដើម្បីតែនឹង _________________ _________________ និង ___________________ ។ ចំណែកព្រះយេស៊ូវិញ ទ្រង់យាងមកដើម្បី ________________________________________________

________________________________________________

ព្រះបន្ទូលនៅក្នុងគម្ពីរយ៉ូហាន ១០:១០ ជាខគម្ពីរដ៏ល្អ សម្រាប់ការទន្ទេញចាំមាត់។

សំណួរពិចារណា៖ ចូរចំណាយពេលពិចារណាព្រះបន្ទូលទាំងនេះ ពិចារណាពីចំណុចណាដែលអ្នករាល់គ្នាមើលឃើញភ័ស្តុតាងនៃព្រះពរដែលព្រះប្រទានឱ្យអ្នកមានជីវិតបរិបូរ គឺជាជីវិតពោរពេញដោយអត្ថន័យ និងគោលបំណង៖ ______

________________________________________________


©2013 CrossConnect Ministries

ការអធិស្ឋាន៖ សូមអរព្រះគុណព្រះអម្ចាស់ ចំពោះការបើកចិត្តគំនិតអ្នករាល់គ្នាឱ្យមើលឃើញព្រះពរក្នុងជីវិតរបស់អ្នករាល់គ្នា។ អរព្រះគុណដែលទ្រង់បានប្រទានឱ្យអ្នករាល់គ្នាមានជីវិតបរិបូរ ខណៈពេលដែលអ្នករាល់គ្នារស់ក្នុងសម្ពន្ធភាពដែលពោរពេញដោយគោលបំណង ជាមួយនឹងទ្រង់៖ ឱព្រះអម្ចាស់យេស៊ូវអើយ! ______________________

______________________________________________________________

## ផ្នែកទី២

សេចក្តីបង្រៀន៖ ការល្បួងវាយលុក ហើយទាស់នឹងអត្តសញ្ញាណស្នូលនៃវិញ្ញាណយើងដែលព្រះជាម្ចាស់បានបង្កើត។ ការល្បួងទាក់បញ្ឆោតចិត្តនេះ លេចចេញមកជាពាក្យផ្សេង ដើម្បីស្តាប់បង្គាប់ និងប្រើសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងជីវិតរបស់យើង។ វាទាក់ទាញយើងដោយបញ្ឆោតឱ្យយើងគិតអំពីភាពពិតមួយផ្សេងដែលផ្ទុយស្រឡះពីព្រះបន្ទូលដ៏ពិតរបស់ព្រះជាម្ចាស់។ ក្នុងលោកិយនេះ ការល្បួងមាននៅជុំវិញយើងគ្រប់ទីកន្លែងដែលយើងរស់នៅ។ ការល្បួង និងការរងទុក្ខការល្បួង មិនជាខុសឆ្គងអ្វីទេ ប៉ុន្តែ ការបន្ទន់តាមការល្បួង គឺជាកំហុសឆ្គងប្រាកដណាស់។ អ្វីដែលលំបាកនោះ គឺការមើលឱ្យស្គាល់អំពីភាពវាងវៃ និងសណ្ឋានល្បិចកលនៃការល្បួង ព្រមទាំងអំណាចដែលមានសម្រាប់បញ្ឆោតយើងឱ្យគិតពិចារណារកខុសរកត្រូវ។ ការល្បួង គឺជាការភូតកុហក នៅពេលដែលយើងចុះចាញ់ ហើយជាប់ក្នុងអន្ទាក់នៃការភូតកុហក នោះយើងនឹងត្រូវវិនាសដោយសារតែកំហុស និងភពអាម៉ាស់របស់ហើយ។ ផលវិបាកនេះឆក់យកយើងចេញពីការរស់នៅក្នុងជីវិតបរិបូរ និងមានសេរីភាព ដូចនឹងព្រះបន្ទូលដែលព្រះយេស៊ូវថ្លែង ហើយយើងបានអាននៅក្នុងគម្ពីរយ៉ូហាន ១០:១០។

គេហកិច្ច៖ ចាប់ផ្តើមនិទានរឿង។ ចូរអាន លោកុប្បត្តិ ៣:១-៧ សារឡើងវិញ។

លំហាត់៖

១. សត្វពស់ និងស្ត្រី បានជួបគ្នា ហើយសត្វពស់ក៏បានដេញដោលល្បួងល។ តើពាក្យដំបូងដែលសត្វពស់និយាយទៅកាន់ស្ត្រី គឺជាពាក្យអ្វី? ______________________________________________

______________________________________________________

២. តាមការពិត តើព្រះជាម្ចាស់មានបន្ទូលម្តេចខ្លះ នៅក្នុងលោកុប្បត្តិ ២:១៦? ____________________

______________________________________________________

៣. តើនាងឆ្លើយតបវិញយ៉ាងដូចម្តេចនៅក្នុងខ២? ______________________________

______________________________________________________

៤. តាមការពិត តើព្រះជាម្ចាស់មានបន្ទូលម្តេចខ្លះ នៅក្នុងលោកុប្បត្តិ ២:១៧ក? __________________

______________________________________________________

៥. នៅក្នុងខទី៤ មេល្បួងបង្កើនយុទ្ធសាស្ត្ររបស់វា តើវាកុហកយ៉ាងដូចម្តេច? ___________________

______________________________________________________

៦. តាមការពិត តើព្រះជាម្ចាស់មានបន្ទូលម្តេចខ្លះ នៅក្នុងលោកុប្បត្តិ ២:១៧ខ? __________________

______________________________________________________

៧. សត្វពស់បានបំភ្លៃសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយប្រើពាក្យកុហក។ តើវាប្រើសម្តីអ្វីខ្លះនៅក្នុងខទី៥ មកធ្វើជាការបញ្ឆោតចិត្តចុងក្រោយបំផុតនោះ? "... ភ្នែកអ្នកនឹងបាន __________________ ហើយ


©2013 CrossConnect Ministries

អ្នកនឹងបាន ______________________ ព្រមទាំងដឹង ________________________។”

**ការសញ្ជឹងគិត៖** ការជួបជាមួយសត្វពស់ធ្វើឱ្យមានសំណួរចុងក្រោយមួយដែលមនុស្សម្នាក់ៗត្រូវរកចម្លើយឱ្យឃើញ៖ ពេលខ្ញុំកំពុងមានជីវិតរស់ តើខ្ញុំត្រូវដើរតាមសម្តីដឹកនាំរបស់អ្នកណា? តើខ្ញុំត្រូវជឿអ្នកណា ត្រូវជឿលើសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះ ឬសម្តីកុហករបស់សត្វពស់ ជាពាក្យបញ្ឆោតដែលបំប្លែងព្រះបន្ទូលរបស់ព្រះ? សំណួរចុងក្រោយសួរថា៖ តើខ្ញុំត្រូវយកជីវិតខ្ញុំ ទៅផ្តោតលើអ្នកណា?

**ជីកឱ្យកាន់តែជ្រៅ៖** សំណួរនៅក្នុងខគម្ពីរទាំង៥ដំបូង នៃជំពូកទី៣នេះ ល្បងលសេចក្តីពិតនៃព្រះបន្ទូលព្រះជាម្ចាស់។ តើអ្នករាល់គ្នាស្តាប់មិនឮសម្លេងភូតភរនៃការល្បួង នៅក្នុងខួរក្បាលរបស់អ្នករាល់គ្នា កំពុងតែសួរអ្នករាល់គ្នាថា “តើព្រះពិតជាមានបន្ទូលថា... ទេឬអី?” បន្ទាប់មកទៀតសំណួរទី២កាន់តែបញ្ឆោតដេញដោលជាងមុនថា “តើព្រះទ្រង់ចង់មានបន្ទូលដូច្នេះមែនឬ?” ការល្បងលនេះ ល្បួងដោយយកព្រះជាម្ចាស់ មកកុហក!

តើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពិតដែរឬទេ? តើព្រះបន្ទូលនេះជាសេចក្តីពិតតែមួយមែនឬទេ? អ្វីក៏ដោយឱ្យតែមនុស្សរាប់ថា ពិត នោះជាសេចក្តីពិត។ តើព្រះជាម្ចាស់ពិតជាមានបន្ទូលមកកាន់យើងតាមរយៈព្រះបន្ទូលរបស់ទ្រង់មែនដែរឬទេ? ចុះបើទ្រង់មានបន្ទូលមកយើងមែន តើទ្រង់ពិតចង់មានន័យដូច្នោះមែនដែរឬទេ? ចូរយើងទៅមើលអ្វីដែលព្រះទ្រង់មានបន្ទូល តាមរយៈហោរាអេសាយនៅក្នុងគម្ពីរអេសាយ ៤៥:១៨-១៩។

១. តើទ្រង់មានបន្ទូលថា ទ្រង់ជាអ្នកណា (ខ១៨)? ______________________________

______________________________________________

២. តើទ្រង់មានបន្ទូលយ៉ាងណាចំពោះព្រះបន្ទូលដែលទ្រង់បានថ្លែង? ចូរកត់សម្គាល់ ចំណុចចុងក្រោយនៃខទី១៩។

______________________________________________

**អនុវត្ត៖** អ្នករាល់គ្នាប្រហែលជាដឹងថា ខ្លួនឯងមានចម្ងល់អំពីបញ្ហាមួយចំនួន ឧទាហរណ៍ អ្នកប្រហែលជាចង់សួរថា៖ តើព្រះមានតែមួយ ពិតមែនទេ? តើអ្នកដែលបង្កើតផ្ទៃមេឃ និងផែនដី គឺពិតជាព្រះមែនទេ? តើគ្មានព្រះឯណាទៀតទេមែនទេ? ប្រសិនបើទ្រង់មានបន្ទូលនូវសេចក្តីពិត ដូចទ្រង់មានបន្ទូលនៅក្នុងខគម្ពីរអេសាយ ៤៥ តើការនេះបញ្ជាក់យ៉ាងណាចំពោះមនោគមវិជ្ជាផ្សេងៗគ្នា នៅក្នុងវប្បធម៌យើងសព្វថ្ងៃ ដែលស្តែងឱ្យឃើញពីភាពខុសគ្នានៃជំនឿនោះ? តើខ្ញុំអាចទុកចិត្តអ្នកណា សម្រាប់និយាយសេចក្តីពិត បើមនុស្សជាច្រើនហាក់ដូចជាមានគំនិតរៀងខ្លួន ចំពោះសេចក្តីពិតយ៉ាងដូច្នេះ?

ក្នុងគំនិតរបស់យើងមានសំណួរខុសៗគ្នាច្រើនយ៉ាងនេះ តើយើងអាចនឹងដឹងពីអ្វីឱ្យប្រាកដ? ជួនកាលអ្វីដែលព្រះទ្រង់មានបន្ទូល ហាក់សមទំនងជាការពិតទៅហើយ។ ឧទាហរណ៍៖

១. នៅក្នុងគម្ពីរ យេរេមា ៣១:៣ ទ្រង់មានបន្ទូលថា “អញបានស្រឡាញ់ឯង ______________________

______________________________________________”

ខ្ញុំមិនអាចជួយអ្វីបាន ក្រៅតែពីនឹកចាំពីកាលដែលខ្ញុំខកចិត្តជាមួយមិត្តភ័ក្តិ ឬមនុស្សជាទីស្រឡាញ់ ប៉ុន្តែ ព្រះទ្រង់មានបន្ទូលប្រាប់ខ្ញុំថា ទ្រង់ស្រឡាញ់ខ្ញុំ ដោយសេចក្តីស្រឡាញ់ដ៏អស់កល្បជានិច្ច។

២. នៅក្នុងគម្ពីរ យេរេមា ៣១:៣៤ ទ្រង់មានបន្ទូលថា “អញនឹងអត់ទោស ______________________

______________________________________________

______________________________________________”

ព្រះជាម្ចាស់មិនត្រឹមតែអស់ទោសអំពើបាបរបស់ខ្ញុំទេ ទ្រង់ថែមទាំងរំឭកប្រាប់ខ្ញុំថា ទ្រង់ក៏បំភ្លេចអំពើបាបរបស់ខ្ញុំចោលដែរ ទ្រង់លែកនឹកចាំពីអំពើបាបនោះទៀតហើយ។

៣. នៅក្នុងគម្ពីរ រ៉ូម ៨:៣៨-៣៩ ទ្រង់បានប្រាប់ខ្ញុំម្ដងទៀតថា "ទោះស្លាប់ ឬរស់ ____________________

____________________________________________________________

____________________________________________________________"

គ្មានអ្វីអាចកាត់ផ្ដាច់យើងចេញពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់បានឡើយ តើវាជារឿងពិតទេដែលថា គ្មានអ្វីអាចកាត់ផ្ដាច់យើងចេញពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ដ្បិតខ្ញុំគិតថា មានរឿងខ្លះអាចកាត់ផ្ដាច់សម្ពន្ធភាពរបស់ខ្ញុំជាមួយនឹងមនុស្សដទៃទៀត ដូចជា សេចក្ដីស្លាប់ ការលែងលះគ្នា ការយល់ច្រឡំ ព្រមទាំងទំនាស់ និងការឈ្លោះប្រកែកគ្នាជាដើមនោះ?

ការសញ្ជឹងគិត៖ សំណួរដែលសត្វពស់បានសួរនៅក្នុងសួនអេដែន បានបន្តមករហូតមកដល់សម័យបច្ចុប្បន្ននេះ ហើយសំណួរទាំងនេះសួរខ្ញុំថា

១. យោងតាមគម្ពីរ យេរេមា ៣១:៣៤ ចូរសរសេរសំណួរឱ្យបានពីរ៖
   ក. តើព្រះជាម្ចាស់ពិតជាមានបន្ទូលថា ______________________________?
   ខ. តើទ្រង់ពិតជាចង់មានន័យថា ______________________________?

២. យោងតាមគម្ពីរ រ៉ូម ៨:៣៨-៣៩ ចូរសរសេរសំណួរឱ្យបានពីរ៖
   ក. តើព្រះជាម្ចាស់ពិតជាមានបន្ទូលថា ______________________________?
   ខ. តើទ្រង់ពិតជាចង់មានន័យថា ______________________________?

ការអធិស្ឋាន៖ ឱព្រះអម្ចាស់អើយ ទូលបង្គំចង់ស្គាល់សេចក្ដីពិត ទូលបង្គំចង់ដឹងបន្ថែមនូវអ្វីដែលទ្រង់ចង់មានបន្ទូលប្រាប់ទូលបង្គំ។ សូមជួយឱ្យទូលបង្គំបានស្គាល់ បានយល់ និងទទួលស្គាល់ថា ព្រះបន្ទូលទ្រង់គឺជាសេចក្ដីពិត។ សូមបើកដួងចិត្តរបស់ទូលបង្គំជឿថា ទ្រង់មានបន្ទូលជាសេចក្ដីពិត ហើយប្រកាសនូវអ្វីដែលត្រឹមត្រូវ (អេសាយ ៤៥:១៩)។

____________________________________________________________

____________________________________________________________

## ផ្នែកទី៣

សេចក្ដីបង្រៀន៖ ប្រសិនបើអ្នករាល់គ្នាត្រឡប់ទៅអាន លោកុប្បត្តិ ជំពូកទី៣ នៅមានសំណួរមួយទៀតសួរថា៖ ម្ដេចបានជាព្រះជាម្ចាស់បង្កើតដើមឈើដឹងខុសត្រូវ រួចបង្គាប់ថា មិនឱ្យគេបរិភោគផ្លែរបស់វាទៅវិញ? ជាងនេះទៅទៀត គឺទ្រង់យកសេចក្ដីស្លាប់មកដាក់ទោសចំពោះការល្មើសនឹងសេចក្ដីបង្គាប់នេះ។ ដំបូង កត្តានេះហាក់ដូចជាការទាមទារមួយដ៏អយុត្តិធម៌ និងជាទណ្ឌកម្មដ៏ឃោរឃៅណាស់ ដ្បិតព្រះទ្រង់មានបន្ទូលថា ទ្រង់ជាព្រះនៃសេចក្ដីស្រឡាញ់ ប៉ុន្តែទ្រង់បែរជាប្រទាននូវសេចក្ដីបង្គាប់ដែលមានជាប់ទោសធ្ងន់ធ្ងរបែបនេះទៅវិញ ដូចជាមិនយល់សោះ។

ចូរយើងពិចារណាអំពីចំណុចមួយចំនួន ដំបូងយើងត្រូវយល់ថា ព្រះជាម្ចាស់ទ្រង់ជាព្រះនៃសម្ពន្ធភាព ទ្រង់ជាព្រះអាទិករ និងជាព្រះដែលនៅតែមានទំនាក់ទំនងជិតស្និទជាមួយនឹងជីវិតដែលទ្រង់បានបង្កើត។ សម្ពន្ធភាពនេះ ដូចគ្នាទៅនឹងសម្ពន្ធភាពរវាងឪពុកម្ដាយ ហើយនិងកូន ព្រះទ្រង់បានរៀបចំជាស្រេច ឱ្យឪពុកម្ដាយមានទំនាក់ទំនងនៅក្នុងជីវិតកូនដែលពួកគាត់បង្កើត។ ទ្រង់ក៏មានចេតនាឱ្យឪពុកម្ដាយនៅបន្តរក្សាភាពស្និទស្នាលនៅក្នុងជីវិតកូន ហើយទ្រង់ក៏បានរៀប

ចំឱ្យឪពុកម្តាយថែរក្សាកូនផងដែរ។ ព្រះជាម្ចាស់ទ្រង់មានព្រះទ័យទុកដាក់ និងថែរក្សាគ្រប់របស់ទាំងអស់ដែលទ្រង់បានបង្កើតមក ទ្រង់មិនដែលបោះបង់ចោលរបស់ដែលទ្រង់បានបង្កើតមកនោះទេ (អេសាយ ៤៩:១៥-១៦)។

ក្នុងពេលជាមួយគ្នានោះ អ្វីដែលសំខាន់ គឺត្រូវយល់ពីសណ្ឋានពិតនៃសេចក្តីស្រឡាញ់របស់ព្រះ ដូចដែលទ្រង់បានបម្រុងទុកមក។ សេចក្តីស្រឡាញ់គឺជាជម្រើសមួយ វាជាការប្រព្រឹត្តដែលកើតមកពីបំណងចិត្ត មិនមែនជាអារម្មណ៍ទេ។ មនុស្សអាចសម្រេចចិត្តស្រឡាញ់ ហើយគ្មាននរណាម្នាក់អាចធ្វើឱ្យយើងស្រឡាញ់ ឬស្អប់នរណាម្នាក់ទៀតបានឡើយ។ ការស្តាប់បង្គាប់ គឺជាការបង្ហាញឱ្យឃើញពីការសម្រេចចិត្តស្រឡាញ់។ ឪពុកម្តាយស្រឡាញ់កូន រីឯកូនឆ្លើយតបចំពោះសេចក្តីស្រឡាញ់នោះ ដោយសម្រេចចិត្តស្តាប់បង្គាប់។ ព្រំដែនកំណត់ដែលឪពុកម្តាយបង្កើតឡើងនៅក្នុងគ្រួសារ ធ្វើឱ្យគ្រួសារមានបរិយាកាសដែលជួយឱ្យគេមានសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក។ ទាំងកូន ទាំងស្វាមី ភរិយា ព្រមទាំងឪពុកម្តាយ សុទ្ធតែមានឱកាសបង្ហាញនូវសេចក្តីស្រឡាញ់ តាមរយៈការគោរព និងកាន់តាមព្រំដែនកំណត់ទាំងនេះ។

យើងក៏ត្រូវចាំដែរថា ព្រះជាម្ចាស់ទ្រង់ជាព្រះអាទិករ ហើយទ្រង់បានបង្កើតទាំងមនុស្សប្រុស និងមនុស្សស្រីមក។ មនុស្សទាំងប្រុសទាំងស្រីត្រូវយល់ ហើយត្រូវរស់នៅក្នុងសម្ពន្ធភាពដែលព្រះអាទិករបានបង្កើត។ បម្រាមចំពោះផ្លែឈើនេះ មិនមែនដើម្បីឱ្យព្រះមើលឃើញការមិនស្តាប់បង្គាប់របស់គេនោះទេ ដ្បិតទ្រង់ជ្រាបស្រេចហើយថា ពួកគេនឹងមិនស្តាប់បង្គាប់ទ្រង់ទេ ប៉ុន្តែផ្ទុយទៅវិញ បម្រាមចំពោះផ្លែឈើនេះ ធ្វើឡើងដើម្បីឱ្យមនុស្សមានឱកាសស្គាល់ព្រះ ទៅតាមសណ្ឋានពិតរបស់ទ្រង់។ វាជាឱកាសសមរាប់ឱ្យពួកគេស្គាល់តួនាទីរបស់ខ្លួន ក្នុងនាមជាជីវិតដ៏មានតម្លៃ ព្រមទាំងស្តាប់បង្គាប់ទ្រង់ដោយសេចក្តីស្រឡាញ់ចេញពីចិត្ត តាមរយៈការចុះចូលចំពោះសិទ្ធិអំណាចដែលទ្រង់មានមកលើពួកគេ។

ក្នុងលោកុប្បត្តិ ៣:៥ សំណួរចុងក្រោយសត្វពស់ជាសំណួរដែលសួរថា តើអ្នកណាធ្វើជាព្រះ! សំណួរនេះគឺនៅតែដដែល រហូតដល់កូនក្លាយជាមនុស្សធំ៖ តើអ្នកណាធ្វើជាឪពុកម្តាយ? ព្រះជាម្ចាស់ចង់ឱ្យអ្វីៗដែលទ្រង់បង្កើតមក ឈប់សម្រាកយ៉ាងប្រាកដ ដោយស្គាល់ពីសម្ពន្ធភាពដែលគេមានជាមួយនឹងទ្រង់។ ទ្រង់គឺជាព្រះ ជាព្រះដែលបង្កើតពួកគេមក ហើយពួកគេ គឺជាជីវិតដែលទ្រង់បង្កើតមក។ ទ្រង់ចង់ឱ្យគេស្គាល់តែភាពសប្បុរសរបស់ទ្រង់តែប៉ុណ្ណោះ ទ្រង់ថែមទាំងបានបង្ហាញភាពសប្បុរសរបស់ទ្រង់ នៅក្នុងរបស់គ្រប់យ៉ាងដែលទ្រង់បានបង្កើត។ ទ្រង់ចង់ឱ្យពួកគេមានអំណររីករាយនៅក្នុងសម្ពន្ធភាពនៃសេចក្តីស្រឡាញ់ជាមួយទ្រង់ និងជាមួយគ្នាទៅវិញទៅមក។ ទ្រង់ចង់ទទួលបន្ទុកទំនួលខុសត្រូវលើការស្គាល់ល្អអាក្រក់ ហើយចង់ការពារពួកគេពីឥទ្ធិពល និងអំណាចរបស់វា។ សេចក្តីស្រឡាញ់ដែលទ្រង់មានចំពោះរបស់គ្រប់យ៉ាងដែលទ្រង់បានបង្កើត ជាពិសេសចំពោះសម្ពន្ធភាពនៃសេចក្តីស្រឡាញ់ដែលទ្រង់ចង់មានជាមួយមនុស្ស កំពុងប្រឈមនឹងហានិភ័យ។ ប៉ុន្តែ ទ្រង់សុខចិត្តប្រឈមនឹងហានិភ័យហើយប្រទានឱ្យគេមានឱកាសបង្ហាញសេចក្តីស្រឡាញ់របស់ខ្លួនចំពោះទ្រង់ តាមរយៈការទុកចិត្តព្រះបន្ទូល ហើយរស់នៅដោយស្តាប់បង្គាប់ទ្រង់។ ជាលទ្ធផល ជីវិតរបស់ពួកគេនឹងផ្តោតយកទ្រង់ និងព្រះបន្ទូលរបស់ទ្រង់ ជាសំខាន់។

ចូរសរសេរគម្ពីរ លោកុប្បត្តិ ៣:៦ ដោយនឹកចាំការរៀបរាប់ខាងលើទុកក្នុងចិត្ត ហើយស្រមៃមើលសារៈសំខាន់នៃពាក្យនីមួយៗ។ ______________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

"...នាងក៏យកផ្លែមកបរិភោគ ព្រមទាំងចែកឱ្យដល់ប្តីបរិភោគដែរ គាត់ក៏បរិភោគតាម"

 ©2013 CrossConnect Ministries

ការសញ្ជឹងគិត៖

១. ចូរចំណាយពេលពិចារណាយ៉ាងស្ងៀមស្ងាត់។ តើអ្នកមានទស្សនៈយ៉ាងណាចំពោះអ្វីដែលបានកើតឡើង? តើការដែលស្គាល់តែសេចក្តីល្អ និងភាពសប្បុរសរបស់ព្រះ នោះទំនងដូចនឹងអ្វី ចំណែកក្រោយពេលដែលបានជឿលើពាក្យកុហកវិញនោះ តើទំនងដូចជាអ្វីដែរ? លោកុប្បត្តិ ៣:៧ ចែងថា "នោះស្រាប់តែ ____________ របស់អ្នកទាំង២បាន ____________ ..." តើការបន្ទន់ទៅតាមពាក្យកុហក និងការបោកបញ្ឆោត បង្កនូវភាពអន្តរាយអ្វីខ្លះ? ____________

____________

២. តើនាងអេវ៉ាគួរធ្វើយ៉ាងណា ដើម្បីបន្ថយការមិនស្តាប់បង្គាប់ដោយបរិភោគផ្លែឈើដែលទ្រង់ហាម? តើអ្នករាល់គ្នាបានប្រព្រឹត្តទង្វើអ្វីខ្លះ ដែលជាការមិនស្តាប់បង្គាប់ ឬជាអំពើបាបនោះ? តើមានពាក្យកុហកអ្វីខ្លះ ដែលអ្នករាល់គ្នាបាននិយាយប្រាប់ខ្លួនឯង? ____________

____________

ការអនុវត្ត៖ ការពិចារណារបស់អ្នករាល់គ្នា អាចនាំឱ្យអ្នករាល់គ្នាមានឱកាសជឿច្បាស់ដោយខ្លួនឯង។

១. ចូររកនឹងអំពីពេលវេលាមួយដែលអ្នករាល់គ្នាចាញ់សេចក្តីល្បួង បះបោរ ហើយមិនស្តាប់បង្គាប់។ តើកាលៈទេសៈនោះមានលក្ខណៈដូចម្តេច? ____________

____________

*ចំណាំ៖ អំពើបាប គឺជាជម្ងឺមួយដែលជ្រាបចូលក្នុងជីវិតមនុស្សគ្រប់គ្នា រួមទាំងអ្នករាល់គ្នា និងខ្ញុំផងដែរ។ ការអត់ទោសបាប ជារបស់ដែលព្រះជាម្ចាស់ប្រទានឱ្យ។ ការអត់ទោសបាបរបស់យើង ប្រោសការខូចបង់ដែលអំពើបាបបានបង្កឡើង គឺជាការខូចបង់ដែលផ្តាច់យើងចេញពីទ្រង់។ ការអត់ទោសបាប ផ្សះផ្សារសម្ពន្ធភាពរបស់យើងសារជាថ្មី និងនាំមកនូវមេត្រីភាព។ ពេលយើងផ្តល់ការអត់ទោសដល់អ្នកដែលបានធ្វើខុសមកលើយើង នោះដំណើរការនៃការប្រោសឱ្យជា ក៏ចាប់ផ្តើមផ្សះផ្សារសម្ពន្ធភាពនោះសារជាថ្មី។ នៅពេលព្រះជាម្ចាស់អត់ទោសឱ្យយើង យើងក៏ត្រូវអត់ទោសឱ្យគ្នាទៅវិញទៅមកដែរ។ នៅក្នុងសេចក្តីអធិស្ឋានរបស់ព្រះអម្ចាស់ យើងអធិស្ឋានថា "សូមអត់ទោសសេចក្តីកំហុសរបស់យើងខ្ញុំ ដូចជាយើងខ្ញុំបានអត់ទោសដល់អ្នកដែលធ្វើខុសនឹងយើងខ្ញុំដែរ។"*

៣. តើអ្នករាល់គ្នាមានឱកាសនូវផ្តល់សេចក្តីស្រឡាញ់របស់ព្រះ និងការអត់ទោសដល់នរណាម្នាក់ ដោយសារអ្នកបានស្គាល់ព្រះចេស្តានៃសេចក្តីស្រឡាញ់ និងការអត់ទោសបាបក្នុងជីវិតរបស់អ្នករាល់គ្នា នៅពេលណា? តើគេម្នាក់នោះជានរណា តើព្រះជាម្ចាស់ប្រើអ្នករាល់គ្នាឱ្យនាំយកសេចក្តីស្រឡាញ់ និងការអត់ទោសឱ្យគេ ដោយវិធីណា?

____________

ការអធិស្ឋាន៖ ឱព្រះជាម្ចាស់អើយ ទូលបង្គំអាចលន់តួតែការមិនស្តាប់បង្គាប់របស់ទូលបង្គំតែប៉ុណ្ណោះ ទូលបង្គំបានបះបោរទាស់នឹងទ្រង់ច្រើនណាស់ តាមរយៈទង្វើ ពាក្យសម្តី និងការគិត ដែលទូលបង្គំបានសម្រេចចិត្តធ្វើ។ ទូលបង្គំសូមឱ្យទ្រង់អត់ទោសដល់ទូលបង្គំ ហើយរំឭកទូលបង្គំឱ្យដឹងថា ទ្រង់បានបង្កើតទូលបង្គំដោយសេចក្តីស្រឡាញ់ ហើយទ្រង់ចង់ឱ្យទូលបង្គំមានជីវិតបរបូរ និងជីវិតដែលត្រូវបានអត់ទោសបាប តាមរយៈព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់ទូលបង្គំ។

____________

____________


©2013 CrossConnect Ministries

## ផ្នែកទី៤

**សេចក្ដីបង្រៀន៖** ចូរយើងត្រឡប់ទៅមើលហេតុការណ៍ដែលបានកើតឡើងនៅក្នុងលោកុប្បត្តិ ៣:៦។ អ័ដាម និងនាងអេវ៉ា ចាញ់សេចក្ដីល្បួង ហើយភ្នែករបស់គេក៏បានភ្លឺឡើង។ ការចង្អុលទៅគេ ហើយនិយាយថា "ឯងនេះ ធ្វើឱ្យពួកយើងអន្តរាយទាំងអស់! បើយើងវិញ យើងគ្មានផ្លូវធ្វើដូចឯងទេ" គឺជាការងាយទេ។ ការគិតថា យើងគ្មានអ្វីពាក់ព័ន្ធនឹងបញ្ហានេះ គឺជាការងាយទេ ដ្បិតយើងមានពួកគេរង់ចាំឱ្យយើងបន្ទោសស្រេចហើយ ប៉ុន្តែ ចូរយើងមើលឱ្យល្អិតល្អន់ជាងនេះបន្តិចវិញ។

កន្លែងដែលត្រូវចាប់ផ្ដើមមើល គឺការលាតត្រដាងអំពីភាពស្រេកឃ្លាន។ ផ្លែឈើដែលគេរៀបរាប់នៅក្នុងជំពូក៣ ទំនងជាដូច "ផ្លែឈើ" ដែលយើងបរិភោគសព្វថ្ងៃ។ តើមានពាក្យពេចន៍អ្វីខ្លះរៀបរាប់ពីផ្លែឈើ ក្នុងលោកុប្បត្តិ ៣:៦?

- ផ្លែឈើនោះ ________________________________________________
- ផ្លែឈើនោះ ________________________________________________
- ហើយជាដើមដែល ____________________________________________

ផ្លែឈើនោះបរិភោគបាន ក៏ជាទីគាប់ដល់ភ្នែក ហើយជាដើមដែលល្មមគួរចង់បាន ដើម្បីឱ្យបានប្រាជ្ញា។

ភាពស្រេកឃ្លានទី១ គឺចង់ឱ្យសេចក្ដីប្រាថ្នារបស់យើង ធ្វើឱ្យជីវិតរស់ ចង់ធ្វើជាព្រះខ្លួនឯង។ ភាពស្រេកឃ្លាននេះ បង្ហាញចេញយ៉ាងច្បាស់ តាមរយៈសេចក្ដីប្រាថ្នាចង់បានថែមទៀត។ ចិត្តយើងមិនចេះស្កប់ឡើយ ភាពស្រេកឃ្លានរបស់យើង មិនចេះឆ្អែតឆ្អន់នោះទេ។ ពេលយើងមានលុយតិចតួច យើងចង់បានលុយច្រើន ពេលយើងមានលុយច្រើន យើងចង់បានឱ្យកាន់តែច្រើន។ ពេលយើងមិនសូវល្បី យើងចង់ល្បី ពេលយើងបានល្បី យើងចង់ល្បីឱ្យជាងមុន។ យើងកំពុងរស់នៅក្នុងវិញ្ញាណដែលមិនចេះស្កប់ស្កល់ ជីវិតរបស់យើងបរាជ័យក្នុងការឆ្លុះបញ្ចាំងអំពីការដឹងគុណ និងការអរគុណ។ ការផ្ដោតជីវិតរបស់យើងទៅលើសេចក្ដីប្រាថ្នារបស់ខ្លួន ដូចជាចង់បាននេះ ចង់បាននោះមិនចេះគ្រប់នេះហើយ គឺជាការល្បួង!

**ការសញ្ជឹងគិត៖** ចូរនឹកគិតអំពីពេលមួយ ដែលអ្នករាល់គ្នាបានសង្កេតឃើញ ឬប្រហែលជាបានឆ្លងកាត់កាលៈទេសៈដែលត្រូវគ្រប់គ្រងដោយសេចក្ដីប្រាថ្នារបស់អ្នករាល់គ្នា៖

១. តើកាលៈទេសៈនោះ មានសភាពយ៉ាងដូចម្ដេច? ____________________________________
២. តើនោះជាបទពិសោធន៍នៃការស្រេកឃ្លានដែលមិនចេះស្កប់ស្កល់នោះមែនឬទេ? _______________
៣. ចុះលទ្ធផលទៅជាយ៉ាងណា? ______________________________________________

ភាពស្រេកឃ្លានទី២ គឺសេចក្ដីប្រាថ្នាចង់បានភាពរីករាយ។ ប្រសិនបើវាបំពេញសេចក្ដីត្រូវការរបស់ខ្ញុំបាន នោះខ្ញុំចង់បានវា ប្រសិនបើវាមើលទៅល្អ ស្អាត ឆ្ងាញ់ នោះខ្ញុំចង់បានវា។ ការស្រេកឃ្លានភាពរីករាយ ក៏មិនចេះស្កប់ស្កល់ដែរ។ ភាពតែងមានវិធីបង្កើនការទាមទាររបស់វាជានិច្ច វាអាចក្លាយជាទម្លាប់ រួចក្លាយជាការញៀនងប់ងល់។ ភាពរីករាយអាចលុបបំបាត់នូវការគិតរកហេតុផល ការសម្រេចចិត្ត និងគំនិតមានប្រយោជន៍ ដែលធ្វើឱ្យមនុស្សប្រព្រឹត្តហួសពីភាពអត្តានិយមរបស់ខ្លួនទៅទៀត។ ចុងក្រោយ ភាពរីករាយនេះ អាចធ្វើឱ្យសម្ពន្ធភាពប្រឈមនឹងហានិភ័យ។ តើនឹងមានអ្វីកើតឡើងចំពោះសម្ពន្ធភាពរបស់មនុស្ស និងព្រះ ប្រសិនបើគេយកភាពរីករាយមកធ្វើជាត្រីមុខនៃជីវិតរបស់គេ? _______

________________________________________________________________

________________________________________________________________


©2013 CrossConnect Ministries

ការសញ្ជឹងគិត៖ ចូររិះគិតអំពីពេលមួយដែលភាពស្រេកឃ្លានចង់បានភាពរីករាយរបស់អ្នក ធ្វើឱ្យសម្ពន្ធភាពរបស់អ្នកជាមួយមនុស្សដទៃ ឬអាចជាសម្ពន្ធរបស់អ្នកជាមួយនឹងព្រះជាម្ចាស់ផ្ទាល់ ប្រឈមនឹងហានិភ័យ។

១. តើមានអ្វីខ្លះដែលធ្វើឱ្យភាពរីករាយមានតម្លៃស្មើនឹងហានិភ័យនៃការខូចខាត ឬបាត់សម្ពន្ធភាព? ______________________________

២. ពេលអ្នករាល់គ្នាពិចារណាអំពីរឿងនេះ ចូរសួរខ្លួនឯងថា តើខ្ញុំអាចបង្ហាត់ខ្លួនយ៉ាងណាខ្លះ ដើម្បីតស៊ូនឹងលទ្ធផលដែលត្រូវកើតឡើង? ______________________________

ភាពស្រេកឃ្លានទី៣ គឺសេចក្ដីប្រាថ្នាចង់បានប្រាជ្ញា។ ចំណេះវិជ្ជាគឺជាអំណាច កាលណាយើងដឹងថា យើងកាន់តែអាចគ្រប់គ្រងការប្រព្រឹត្តរបស់ខ្លួនឯងចំពោះអ្នកដទៃ នោះយើងនឹងអាចកម្លាអ្នកដទៃ ដើម្បីអួតថាខ្លួនពូកែ។ អំណាចធ្វើឱ្យយើងចេះគ្រប់គ្រង "លោកនេះជារបស់អញ អញនឹងបង្ក្រាបវាឱ្យបាន"។ អំណាច និងការគ្រប់គ្រង នាំឱ្យយើងជឿថា យើងមិនត្រូវការនរណាទៀតឡើយ ហើយយើងអាចរស់នៅដោយសេចក្ដីអំណួត និងភាពឯករាជ្យ មិនត្រូវការពឹងផ្អែកលើព្រះដ៏ជាព្រះអាទិករទៀតទេ។ ជាថ្មីម្ដងទៀត ចូរអ្នករាល់គ្នាពិចារណាអំពីហេតុការណ៍ដែលនឹងកើតឡើង ប្រសិនបើមនុស្សម្នាក់អនុញ្ញាតឱ្យការប្រដេញតាមអំណាចក្លាយទៅជាចំណុចស្នូលនៃជីវិតរបស់គេ។ ______________________________

ការសញ្ជឹងគិត៖ ចូរពិចារណាអំពីកាលៈទេសៈមួយ ពេលដែលតម្រូវការនៃអំណាច និងការគ្រប់គ្រង បានបង្កឱ្យមានការលំបាក...

១. តើអ្វីខ្លះដែលបានបង្កើតឱ្យមានតម្រូវការចំពោះការរស់នៅដោយឯករាជ្យ? ______________________________

២. តើអ្វីខ្លះដែលធ្វើឱ្យចំណេះដឹង អំណាច និងការគ្រប់គ្រង ទាក់ទាញចិត្តយ៉ាងនេះ? ______________________________

៣. តើមានអ្វីកើតឡើង ប្រសិនបើអំណាចក្លាយជាចំណុចស្នូលនៃជីវិត? ______________________________

ក្នុងបទគម្ពីរអេសាយ ១៤:១៣-១៤ ព្រះជាម្ចាស់ទ្រង់បានសម្ដែងព្រះហឫទ័យទ្រង់ចំពោះមនុស្ស តាមរយៈហោរាអេសាយ។ តើមនុស្សដែលព្រះបានបង្កើត និយាយអ្វីខ្លះ? ចូរសរសេរបំពេញឃ្លាទាំងប្រាំ ដែលមានពាក្យថា "អញនឹង..."

១. អញនឹង ______________________________
២. អញនឹង ______________________________
៣. អញនឹង ______________________________
៤. អញនឹង ______________________________
៥. អញនឹង ______________________________

ការលើកតម្កើងខ្លួនឯងឱ្យដូចព្រះ គឺជាដំណាក់កាលចុងក្រោយបង្អស់ នេះហើយជាការល្បួងដែលស្ត្រីបានជ្រើសរើសយក។ ចូរយើងបន្តសាច់រឿងទៅមុខទៀត ក្រែងលោយើងមើលរំលងភស្តុតាងដែលយើងអាចយល់បាន។ ស្ត្រីគឺជាមនុស្សដំបូងដែលបានបរិភោគផ្លែឈើ ប្ដីនាងក៏នៅជាមួយដែរ ហើយគាត់ហាក់ដូចជាចាប់អារម្មណ៍នឹងស្ដាប់តាមពាក្យដែលសត្វពស់និយាយ ជាងព្រះបន្ទូលព្រះ ដ្បិត "នាងក៏បានចែកឱ្យដល់ប្ដីដែលនៅជាមួយ ហើយគាត់ក៏បរិភោគតាម"។

**ការទន្ទេញចាំមាត់៖** យើងអាចសម្លឹងមើលទៅព្រះដែលស្រឡាញ់យើង ហើយថ្វាយសណ្ដានបាបរបស់យើងដល់ទ្រង់ ដោយចំណាយពេលវេលាយ៉ាងស្ងៀមស្ងាត់។ ចូរបើកអានបទគម្ពីររ៉ូម ៣:២៣-២៤។ ឃ្លាចុងក្រោយក្នុងខទី២២ចែងថា "ដ្បិតគ្មានអ្វីខុសអំពីគ្នាទេ"។ ចូរសរសេរ ខទី២៣ និងទី២៤ ដោយចាប់ផ្ដើមថា "គ្មានអ្វីខុសអំពីគ្នាទេ... __________

______________________________________________________________________

______________________________________________________________________

ខ្ញុំសូមលើកទឹកចិត្តអ្នករាល់គ្នា ឱ្យទន្ទេញបទគម្ពីរទាំង២ខនេះឱ្យចាំ។ ចូរចាប់ផ្ដើមបន្ថែមបទគម្ពីរនេះទៅក្នុងការចងចាំរបស់អ្នក។ ខគម្ពីរនេះរំឭកប្រាប់យើងថា មនុស្សទាំងអស់មានចំណុចមួយដូចគ្នា គឺគ្រប់គ្នាបានធ្វើបាប និងខកខានក្នុងការស្ដែងពីរូបអង្គរបស់ព្រះជាម្ចាស់ ទៅកាន់ពិភពលោកដែលព្រះបានបង្កើតមក ដូចដែលទ្រង់ចង់បាន (លោកុប្បត្តិ ១:២៧)។ ប៉ុន្តែ ក្នុងពេលជាមួយគ្នានោះ ខគម្ពីរនេះក៏ប្រាប់យើងដែរថា យើងត្រូវបានរាប់ជាសុចរិតដោយទទេ តាមរយៈព្រះគុណដែលបានមកពីការប្រោសលោះ ដោយសារព្រះយេស៊ូវ។

**និយមន័យ៖**

១. ***ត្រូវបានរាប់ជាសុចរិត*** - ព្រះជាម្ចាស់មិនប្រកាន់ទោសបាបខ្ញុំទៀតទេ ហើយខ្ញុំក៏លែងត្រូវប្រឈមទៅនឹងការចោទប្រកាន់ ដោយសារតែការមិនស្ដាប់បង្គាប់របស់ខ្ញុំទៀតដែរ។ "ជាប់មានទោស" ជាពាក្យផ្ទុយនឹងពាក្យថា "បានរាប់ជាសុចរិត"។ ព្រះជាម្ចាស់បានប្រកាសថា រូបខ្ញុំគ្មានកំហុសទេ ទ្រង់មានបន្ទូលប្រាប់ខ្ញុំទៀតថា សម្ពន្ធភាពរបស់ខ្ញុំ ហើយនិងទ្រង់ ត្រូវបានផ្សះផ្សារឡើងវិញហើយ។ ជីវិតរបស់ព្រះយេស៊ូវ រួមទាំងការរងទុក្ខ និងការសុគតរបស់ទ្រង់ គឺធ្វើឡើងសម្រាប់ខ្ញុំ ទ្រង់ធ្វើឱ្យខ្ញុំបានសុចរិតនៅចំពោះព្រះជាម្ចាស់។

២. ***ព្រះគុណ*** - ព្រះជាម្ចាស់បានប្រទានឱ្យខ្ញុំនូវសេចក្ដីស្រឡាញ់ដែលខ្ញុំមិនអាចរកបាន ហើយក៏មិនសមនឹងទទួលដែរ ដ្បិតខ្ញុំបានធ្វើឱ្យទ្រង់ឈឺចាប់ពេកពន់។ ទោសនៃការមិនស្ដាប់បង្គាប់របស់ខ្ញុំ គឺជាសេចក្ដីស្លាប់ នេះហើយជាផលនៃអំពើបាប ដែលខ្ញុំត្រូវទទួល។ សូមអាន លោកុប្បត្តិ ២:១៧ និង រ៉ូម ៦:២៣។ ប៉ុន្តែ ដោយសារតែការសុគតរបស់ព្រះយេស៊ូវ ខ្ញុំបានទទួលនូវសេចក្ដីស្រឡាញ់ និងព្រះគុណ ដែលខ្ញុំមិនសមនឹងទទួល ហើយសេចក្ដីស្រឡាញ់នេះបានប្រោសខ្ញុំឱ្យរួច ដើម្បីឱ្យខ្ញុំអាចរស់នៅជាមួយនឹងទ្រង់អស់កល្បជានិច្ច។

៣. ***ការប្រោសលោះ*** - ព្រះជាម្ចាស់ទ្រង់ចង់ទិញ ឬលោះយករបស់គ្រប់យ៉ាងដែលបានបាត់បង់ទៅ ដោយសារអំពើតែបាប ត្រឡប់មកវិញ។ ភាពគ្មានទោសរបស់ខ្ញុំបានបាត់បង់ទៅហើយ សម្ពន្ធភាពរបស់ខ្ញុំជាមួយនឹងព្រះអង្គ ក៏បានបាត់បង់ទៅដែរ ហើយខ្ញុំបានក្លាយជាទាសករចំពោះអំពើបាប សេចក្ដីស្លាប់ និងមារសាតាំងផង។ តម្លៃលោះជីវិតខ្ញុំឱ្យរួចពី "ទាសភាព" នេះ មានតែជីវិតព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវប៉ុណ្ណោះ។ ការប្រោសលោះ គឺជាការដែលព្រះទ្រង់យកខ្ញុំត្រឡប់មកវិញ និងសង្គ្រោះខ្ញុំពីការសង្កត់សង្កិន ពីទោសនៃសេចក្ដីស្លាប់ ដែលបានធ្លាក់លើខ្ញុំដោយសារតែអំពើបាប។ ទ្រង់បានធ្វើកិច្ចការនេះ តាមរយៈការរស់នៅក្នុងជីវិតដ៏បរិសុទ្ធ តាមរយៈការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះដ៏ប្រោសលោះរបស់ខ្ញុំ។

ចំណាំ៖ ពាក្យទាំងនេះនឹងត្រូវគេយកមកប្រើជាថ្មីម្ដងទៀត ក្នុងឈុតមេរៀននេះទាំងអស់។ មកដល់ត្រង់ចំណុចនេះ ខ្ញុំសូមលើកទឹកចិត្តអ្នករាល់គ្នាឱ្យស្គាល់ពាក្យដែលមានចែងក្នុងបទគម្ពីរនេះ (រ៉ូម ៣:២៣-២៤)។ ចូរបន្ថែមនិយមន័យពាក្យនេះ ព្រមទាំងពាក្យផ្សេងៗទៀត ទៅក្នុងសៀវភៅសរសេររបស់អ្នកសម្រាប់ជាឯកសារយោងនៅពេលក្រោយ បន្ថែមវាទៅក្នុងបញ្ជីនិយមន័យពាក្យ នៅក្នុងសៀវភៅកំណត់ត្រារបស់អ្នកផង។


©2013 CROSSCONNECT MINISTRIES

ការអធិស្ឋាន៖ សូមពិចារណាអំពីបទគម្ពីររ៉ូម ៣:២៣-២៤ សារជាថ្មី... ឱព្រះអម្ចាស់អើយ ទូលបង្គំបានប្រព្រឹត្តនូវអំពើបាប ហើយទូលបង្គំមិនសមនឹងទទួលបានអ្វីទាំងអស់ ក្រៅតែពីសេចក្តីស្លាប់ដ៏នៅអស់កល្បជានិច្ច។ អរព្រះគុណព្រះអង្គចំពោះព្រះយេស៊ូវដែលបានរាប់ទូលបង្គំជាសុចរិត ទ្រង់បានលោះទូលបង្គំដោយព្រះលោហិតរបស់ទ្រង់ ហើយបានធ្វើឱ្យទូលបង្គំបានក្លាយជាកូនរបស់ព្រះអង្គសារជាថ្មី។ អរព្រះគុណទ្រង់ ដែលមិនប្រកាន់ទោសរបស់ទូលបង្គំ លើកលែងទោសដល់ទូលបង្គំ ហើយប្រកាសថា ទូលបង្គំគ្មានទោស។ អរព្រះគុណទ្រង់ចំពោះព្រះគុណ និងសេចក្តីស្រឡាញ់ដែលទូលបង្គំមិនសមនឹងទទួល។ អរព្រះគុណចំពោះព្រះយេស៊ូវ ជាព្រះដ៏ប្រោសលោះដែលបានប្រោសទូលបង្គំឱ្យរួចមានសេរី ហើយបានធ្វើឱ្យទូលបង្គំក្លាយជាកម្មសិទ្ធរបស់ទ្រង់ តាមរយៈការអត់ទោសបាប។ ______________________

______________________________________________

______________________________________________

## ផ្នែកទី៥

គេហកិច្ច៖ លោកុប្បត្តិ ៣:៧-១៣

សេចក្តីផ្តើម៖ អំពើបាបបានចូលមកក្នុងលោកិយនេះហើយ។ លោកុប្បត្តិ ៣:៧ រៀបរាប់ពីហេតុការណ៍ដែលបានកើតឡើងជាបន្តទៀត "នោះស្រាប់តែ...

- ភ្នែករបស់អ្នកទាំង២ ______________________
- ហើយគេដឹងថាខ្លួន ______________________
- ក៏យក ______________________
- មកធ្វើជា ______________________។"

ការមិនស្តាប់បង្គាប់ មានលទ្ធផលរបស់វា ពេលមាននរណាម្នាក់ល្មើសច្បាប់ចរាចរ លទ្ធផលនៃបទល្មើសនេះគឺសំបុត្រផាកពិន័យដែលគេត្រូវបង់ជាប្រាក់។ ពេលក្មេងម្នាក់មិនស្តាប់បង្គាប់ឪពុកម្តាយ ឬអាណាព្យាបាល ដោយចេតនាក្មេងនោះនឹងត្រូវទទួលពិន័យ។ លទ្ធផលនៃការមិនស្តាប់បង្គាប់របស់អ័ដាម និងអេវ៉ា ក៏កើតឡើងភ្លាមៗដែរ ក្រោយពីគេបានល្មើសនឹងបញ្ញត្តិរបស់ព្រះជាម្ចាស់ ដែលហាមមិនឱ្យគេបរិភោគផ្លែ "ដឹងខុសត្រូវ"។ គេបានភ្លក់នូវទុក្ខទោសដែលព្រះទ្រង់មិនបានបម្រុងទុកសម្រាប់គេទាល់តែសោះ។

ចូរយើងត្រឡប់ទៅអាន ខទី៧-១៣ សារជាថ្មីវិញ នៅពេលនេះ។

### លទ្ធផលទី១៖

លទ្ធផលទាន់ហន់នៃអំពើបាប គឺការខ្មាសអៀន "គេដឹងថាខ្លួននៅជា __________" (លោកុប្បត្តិ ៣:៧)។ ពួកគេបានស្គាល់ការល្អហើយ តែពេលនេះគេថែមទាំងស្គាល់ការអាក្រក់ទៀត ដូច្នេះការគ្របបាំងដ៏ធំក៏ត្រូវបានធ្វើឡើង។ កិច្ចការដំបូងដែលពួកគេធ្វើ គឺក្លាស់ __________ ភ្ជាប់គ្នា ធ្វើជា __________ សម្រាប់ខ្លួនឯង។ ភាពខ្មាសអៀនរបស់គេ ផ្តាច់ពួកគេចេញពីគ្នា ហេតុនេះទើបគេត្រូវធ្វើការគ្របបាំង។ ភាពជិតស្និទដែលពួកគេធ្លាប់មានចំពោះគ្នា បានបញ្ចប់ទៅហើយ ដូច្នេះពេលនេះពួកគេត្រូវដោះស្រាយបញ្ហាដែលស្ថិតចន្លោះសម្ពន្ធភាពរបស់ពួកគេ។

### លទ្ធផលទី២៖

សូមអាន ខទី៨-១០។ លទ្ធផលនៃអំពើបាប ដែលគួរឱ្យកត់សម្គាល់បន្តទៀតនេះ គឺកំហុស។ កំហុសធ្វើឱ្យយើងចង់លាក់ខ្លួនពួនអាត្មា ខទី៨ ចែងថា "... នោះអ័ដាម និងប្រពន្ធគាត់ក៏ __________ នឹង __________

នៅកណ្ដាល __________ នៅក្នុងសួនច្បារ”។ ពេលនេះ ពួកគេបានយករបស់ដែលព្រះជាម្ចាស់បង្កើត មកគ្របបាំង និងបំពួនអាត្មា ពីព្រះដែលបានបង្កើតពួកគេមក ហើយរស់នៅជាមួយគេក្នុងនាមជាមិត្តសម្លាញ់។ ពួកគេគ្មានអ្វីដែលត្រូវខ្លាចទ្រង់នោះទេ ប៉ុន្តែពេលនេះ ពួកគេកំពុងតែលាក់ខ្លួនពួនគេចពីព្រះអង្គ។

- ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់ហៅរកអ័ដាមដោយបន្ទូលថា “________________________________?”
- គាត់ទូលឆ្លើយថា “________________________________________”។

ពេលព្រះជាម្ចាស់បង្កើតគេមក គេមិនដឹងថាខ្លួនគេនៅជាអាក្រាតនោះទេ។ ការនៅជាអាក្រាត គឺជាសញ្ញា ឬជានិមិត្តរូបបញ្ជាក់ថា នៅលើផែនដីនេះ គ្មានអ្វីអាចកាត់ផ្ដាច់ពួកគេចេញពីព្រះជាម្ចាស់ ឬពីគ្នាទៅវិញទៅមកបានឡើយ នេះហើយជាមធ្យោបាយដែលព្រះជាម្ចាស់បានបម្រុងទុកឱ្យពួកគេរស់នៅជាស្វាមីភរិយា ហើយរស់នៅជាមួយទ្រង់។ តើអ្នកណាប្រាប់ឯង? ភាពខ្មាសអៀន និងកំហុស លាតត្រដាងនូវអំពើបាបរបស់គេ ដោយសារភាពខ្មាសអៀន ពួកគេបានដឹងថា ខ្លួននៅជាអាក្រាត។ ដោយសារកំហុសរបស់គេ ពួកគេភ័យខ្លាច ហើយលាក់ខ្លួនពួនអាត្មា ភាពគ្មានទោសរលាយបាត់អស់ហើយ។

សំណួរ៖ យើងរាល់គ្នាក៏ប្រហែលជាមិនខុសពីគេដែរទេ ពេលមាននរណាម្នាក់រកឃើញកំហុសយើង តើយើងឆ្លើយតបទៅគេវិញយ៉ាងដូចម្ដេច? តើមិនមែនសួរគេវិញថា “តើអ្នកណាប្រាប់អ្នក?” ទេឬអី? បែកការណ៍ហើយ! ភ្លាមៗនោះគឺយើងចង់រត់ទៅរកកន្លែងលាក់ខ្លួន យើងប្រហែលជាយកដើមឈើមកធ្វើជាកន្លែងលាក់ខ្លួនទេ ប៉ុន្តែ យើងចង់ពិតជាចង់លាក់ខ្លួនខ្លាំងណាស់។

១. តើអ្នករាល់គ្នាយល់ថា ការទទួលស្គាល់ភាពខ្មាសអៀន និងកំហុសដែលអ្នករាល់គ្នាបានប្រព្រឹត្តពីអតីតកាល គឺជាការលំបាកណាស់មែនទេ? ________________________________

២. តើអ្នករាល់គ្នាយកអ្វីខ្លះធ្វើជា “ការគ្របបាំង” ដើម្បីព្យាយាមលាក់ខ្លួនពួកគេចពីព្រះ និងពីអ្នកដទៃ? ________

________________________________________________

៣. តើអ្នកទៅពួននៅឯណា ឬដោះស្រាយយ៉ាងណា ពេលអ្នកខ្លាចគេដឹងរឿងពិតរបស់អ្នក និងខ្លាចគេដឹងអំពីកំហុសដែលអ្នកបានប្រព្រឹត្ត? ________________________________

________________________________________________

លទ្ធផលទី៣៖

លទ្ធផលទី៣នៃអំពើបាប ដែលគួរឱ្យកត់សម្គាល់នេះ គឺតម្រូវការនៃការបន្ទោសលើអ្នកដទៃ ឬក៏អ្វីផ្សេងទៀត។ នៅក្នុង ខទី១១ ព្រះជាម្ចាស់សួរថា “________________________________?”

- តើអ័ដាមឆ្លើយទៅវិញ យ៉ាងដូចម្ដេច? ________________________
________________________ ទូលបង្គំក៏ទទួលទានទៅ។ អ័ដាមមិនត្រឹមតែព្យាយាមបន្ទោសអេវ៉ាប៉ុណ្ណោះទេ គាត់ថែមទាំងព្យាយាមបន្ទោសទៅលើព្រះជាម្ចាស់ទៀតផង! “ស្ត្រី ដែល ________ បានប្រទានឱ្យនៅជាមួយទូលបង្គំ...” រួចព្រះយេហូវ៉ាដ៏ជាព្រះ ទ្រង់មានបន្ទូលសួរទៅស្ត្រីថា “__________
________________________________________?”
- ស្ត្រីក៏ព្យាយាមរកកន្លែងផ្សេងដើម្បីបន្ទោស បានជានាងឆ្លើយឡើងថា “________________
________________________________________________
________________________________________________”


©2013 CrossConnect Ministries

ការបន្ទោស ត្រូវការកន្លែងសម្រាក់ដាក់វា ប៉ុន្តែ តើការបន្ទោសបង្កអ្វីខ្លះដល់សម្ពន្ធភាព? ដូចដែលយើងបានដឹងពីខទី៧រួចហើយថា ការបន្ទោសមិនត្រឹមតែកាត់ផ្តាច់មនុស្សប្រុស ពីភរិយារបស់ខ្លួនប៉ុណ្ណោះទេ វាថែមទាំងកាត់ផ្តាច់គេពីព្រះជាម្ចាស់ដែលស្រឡាញ់របស់ដែលទ្រង់បានបង្កើត និងជាព្រះដែលចង់ឱ្យគ្រប់របស់ដែលទ្រង់បានបង្កើត ទទួលនូវអ្វីដែលប្រសើរថ្លៃថ្លាបំផុត។

**ការសញ្ជឹងគិត៖**

១. ចូរចំណាយពេលយ៉ាងខ្លី ដើម្បីពិចារណាអំពីបញ្ហាដែលធ្វើឱ្យអ័ដាមបន្ទោសព្រះជាម្ចាស់។ ______________

______________

២. ចូរនឹកចាំអំពីពេលមួយដែលអ្នកធ្លាប់ក្លាយខ្លួនជាអ្នកទទួលការស្តីបន្ទោស។ ______________

______________

៣. អំពើបាបធ្វើឱ្យបដិសេធមិនទទួលខុសត្រូវចំពោះការគិត និងការប្រព្រឹត្តរបស់ខ្លួន គឺតែងមានមនុស្សណាម្នាក់ ឬរបស់អ្វីផ្សេងទៀតដែលយើងចង់បន្ទោស ប៉ុន្តែ មិនមែនខ្លួនយើងទេ។ ប្រសិនបើមនុស្សហ៊ានទទួលខុសត្រូវ និងលែងសម្លឹងរកអ្នកណាផ្សេងមកបន្ទោស រួមទាំងព្រះជាម្ចាស់ផងនោះ តើវានឹងមានអ្វីខ្លះខុសប្លែក? ______________

______________

៤. តើអ្នកគិតទេថា ខ្លួនអ្នកផ្ទាល់ត្រូវទទួលខុសត្រូវ ហើយឈប់ទម្លាក់កំហុសលើអ្វីផ្សេង? ប្រសិនបើដូច្នោះមែន តើអ្នកត្រូវសម្រេចចិត្តធ្វើការផ្លាស់ប្តូរអ្វីខ្លះ? ______________

______________

**ការអធិស្ឋាន៖** ឱព្រះដ៏ជាព្រះអម្ចាស់អើយ! ទូលបង្គំជាប់មានទោសដោយសារតែ ភាពខ្មាសអៀន សេចក្តីកំហុស និងការបោះបង់ទំនួលខុសត្រូវចំពោះការសម្រេចចិត្តដែលទូលបង្គំបានធ្វើ នៅក្នុងជីវិតទូលបង្គំផ្ទាល់។ សូមអត់ទោសចំពោះពាក្យសម្តី និងទង្វើប្រព្រឹត្តរបស់ទូលបង្គំ ដែលបានធ្វើឱ្យទូលបង្គំដាច់ចេញពីមនុស្សដែលខ្លួនស្រឡាញ់។ សូមអត់ទោសចំពោះការប្រព្រឹត្តរបស់ទូលបង្គំ ដែលបានធ្វើឱ្យទូលបង្គំដាច់ចេញពីទ្រង់។ ទូលបង្គំទុកចិត្ត និងជឿជាក់ដោយជំនឿពិតថា ទូលបង្គំជាកូនរបស់ទ្រង់ ដ្បិតទ្រង់បានរាប់ទូលបង្គំជាសុចរិតហើយ ទូលបង្គំក៏បានទទួលនូវព្រះគុណឥតគិតថ្លៃពីព្រះអង្គ ហើយត្រូវបានប្រោសលោះដោយព្រះលោហិតរបស់ព្រះយេស៊ូវ។ ទូលបង្គំសូមថ្វាយនូវអំណរព្រះគុណ និងការសរសើរដល់ទ្រង់ ដ្បិតទ្រង់បានធ្វើនូវកិច្ចការទាំងអស់នេះ។ ______________

______________

## ផ្នែកទី៦

**សេចក្តីផ្តើម៖** ក្នុងដំណើររឿងកំណើតផែនដី យើងមិនហ៊ានឈប់ត្រឹមចំណុចនេះទេ ដ្បិតយើងទើបមានការបណ្តាលចិត្តឱ្យស្គាល់ភាពខ្មាសអៀន សេចក្តីកំហុស និងបរាជ័យក្នុងការទទួលខុសត្រូវចំពោះគំនិត និងការប្រព្រឹត្តរបស់យើងតែប៉ុណ្ណោះ។ ចូរចងចាំព្រះដែលចែងក្នុងគម្ពីរ យេរេមា ៣១:៣ ថា "អញបានស្រឡាញ់ឯង ដោយសេចក្តីស្រឡាញ់ដ៏ស្ថិតស្ថេរនៅអស់កល្ប..." ក្នុងសាច់រឿង លោកុប្បត្តិជំពូកទី៣នេះ មានការយល់ច្រឡំមួយចំនួនត្រង់ចំណុចនេះថា ព្រះទ្រង់ផ្អែតចិត្ត ទ្រង់ក៏បង្វែព្រះទ័យដាក់បណ្តាសាលើរបស់ដែលទ្រង់បានបង្កើត ទ្រង់ក៏បានដោះដៃដោយការខ្ពើមរអើម ហើយដកយកសួនច្បារនោះចេញ មិនឱ្យគេបានឃើញ ឬបានឮពីសួនច្បារនេះតទៅទៀត។ គេគិតថា ព្រះជាម្ចាស់មានព្រះទ័យ

ក្រោធ ទ្រង់ទប់ព្រះទ័យមិនបាន ទ្រង់ក៏បង្ហាញនូវការខ្ពើមរអើម ហើយប្រព្រឹត្តចំពោះអ័ដាម និងអេវ៉ា ព្រមទាំងរបស់សព្វសារពើដែលទ្រង់បានបង្កើតមក ដោយសេចក្តីស្អប់ខ្ពើម។

ចូរយើងនាំគ្នាក្រឡេកមើលសាច់រឿងនេះសារជាថ្មី នៅត្រង់ខទី១៤។ ដំបូង ព្រះជាម្ចាស់មានបន្ទូលទៅសត្វពស់ថា "ដោយព្រោះ ______________________________________________..."

ការប្រយុទ្ធចាប់ផ្តើមហើយ! សង្គ្រាមចាប់ផ្តើមហើយ! ភាគីទាំងសងខាងបានសម្រេចស្រេចហើយ ថែមទាំងបានកំណត់នូវអត្តសញ្ញាណរួចហើយដែរ។ នេះជាសង្គ្រាមរវាងការល្អ និងអាក្រក់ ភាគីនីមួយៗសុទ្ធតែមានអ្នកឈ្នះរៀងខ្លួន តើអ្នកឈ្នះនោះជាអ្នកណា?

១. តើបទគម្ពីរទំនុកដំកើង ១០៦:១ ប្រាប់យើងថា អ្នកខ្លាំងខាងការល្អជាអ្នកណា? ______________
១កូរិនថូស ១៥:៥៧ ប្រាប់ឈ្មោះអ្នកខ្លាំងរបស់ព្រះជាម្ចាស់យ៉ាងច្បាស់ "ទ្រង់ប្រទានឱ្យយើងមាន __________ __________ ដោយសារ ______________________________________________។"

២. អេភេសូ ៦:១១-១៣ ប្រើរូបភាពការស្លៀកសម្លៀកបំពាក់ធ្វើសង្គ្រាម និងការប្រដាប់កាយដោយគ្រឿងសឹក។ តើអ្នកជាជើងខ្លាំងរបស់ការអាក្រក់? ________________________ ចូរគូសបន្ទាត់ពីក្រោមពាក្យដែលនៅក្នុងព្រះគម្ពីររបស់អ្នក ក្នុងខដែលរៀបរាប់អំពី "សេចក្តីងងឹតនៃលោកិយ" (ខទី១២)។

សេចក្តីបង្រៀន៖ បទគម្ពីរទាំងអស់សុទ្ធរៀបរាប់អំពីសង្គ្រាមនេះ ហើយវារាលដាលរហូតមកដល់សព្វថ្ងៃ។ ព្រះគម្ពីរគឺជាសៀវភៅដែលរៀបរាប់អំពីសង្គ្រាម និងសេចក្តីស្រឡាញ់ ដែលជម្រុញឱ្យមានការតយុទ្ធ។ កណ្ឌទាំងអស់ក្នុងព្រះគម្ពីរសុទ្ធតែផ្អែកលើខ្លឹមសារស្នូលមួយនេះ ព្រមទាំងរៀបរាប់ពីតួអង្គទៀតផង។ យុទ្ធសាស្ត្រនានាត្រូវបានបើកសម្តែង ផែនការសម្ងាត់ ក៏ត្រូវលាតត្រដាង ហើយអ្នកខ្លាំង និងអ្នកខ្លាំងក៏ប្រយុទ្ធគ្នាដែរ។ សាច់រឿងនេះចាប់ផ្តើមក្នុងគម្ពីរលោកុប្បត្តិជំពូក៣ តាមរយៈព្រះបន្ទូលដែលព្រះទ្រង់មានបន្ទូលទៅសត្វពស់ថា "ដោយសារឯងបានធ្វើដូច្នេះ"។ ទីបំផុត បណ្តាសាដែលទ្រង់បានដាក់ នៅក្នុងខទី១៤ និងទី១៥ បានប្រកាសយ៉ាងច្បាស់នូវហេតុការណ៍ដែលនឹងកើតឡើងដល់អ្នកខ្លាំងខាងការអាក្រក់។ តាមពិត គម្ពីរវិវរណៈ ១៣:៩ ប្រាប់យើងអំពីសេចក្តីបញ្ចប់នៃសាច់រឿងរបស់វា ព្រមទាំងពួកបរិវារ គឺក្រុម "សេចក្តីងងឹតនៃលោកិយ"។ ចូរសរសេរខគម្ពីរនេះ៖ ________________________________

______________________________________________

______________________________________________

តើសង្គ្រាមនេះធ្វើឡើងដើម្បីអ្វី? ព្រះជាម្ចាស់ទ្រង់ល្អ ហើយគ្រប់យ៉ាងដែលទ្រង់បានបង្កើតមក ទ្រង់បានប្រកាសថាសុទ្ធតែល្អដែរ (លោកុប្បត្តិ ១:៣១)។ ទ្រង់មានចេតនាចង់ឱ្យមនុស្សដែលទ្រង់បានបង្កើត ស្គាល់តែសេចក្តីល្អ ហើយរស់ក្នុងសម្ពន្ធភាពជាមួយនឹងទ្រង់តែមួយ ឆ្លើយតបនឹងព្រះបន្ទូលទ្រង់ ជាព្រះបន្ទូលរបស់ព្រះដែលល្អគ្រប់លក្ខណ៍។ ប៉ុន្តែចូរចាំថា ការល្បួងដែលសត្វពស់បានលើកឡើង គឺដើម្បីឱ្យពួកគេស្គាល់ល្អអាក្រក់។ សាតាំងចង់ឱ្យពួកគេស្គាល់វា ដែលជាវិញ្ញាណអាក្រក់។ វាចង់យកពួកគេទៅនៅខាងវា វាចង់ឱ្យពួកគេស្តាប់តាមសម្តីវា។ ការល្បួងរបស់វាក្លាយជាក្តីកង្វល់ដល់ជីវិតរបស់ពួកគេ ពួកគេត្រូវឆ្លើយនឹងសំណួរថា៖ តើអ្នកណាគ្រប់គ្រងលើចិត្ត និងជីវិតរបស់ពួកគេ? ការប្រយុទ្ធគ្នានេះបានរាលដាលដល់ព្រលឹងមនុស្សគ្រប់រូប។ តើព្រះជាម្ចាស់ជាអ្នកឈ្នះ ឬមារសាតាំងជាអ្នកឈ្នះ? ព្រះជាម្ចាស់ទ្រង់ពុំមានចេតនាឆ្លើយនឹងសំណួរនេះទេ ទ្រង់គ្រាន់តែចង់ឱ្យពួកគេស្រឡាញ់ទ្រង់ ហើយអនុញ្ញាតឱ្យទ្រង់គ្រងរាជ្យនៅក្នុងចិត្តរបស់ពួកគេ ក្នុងនាមជាព្រះអាទិករដែលមានពេញដោយក្តីស្រឡាញ់ ជាព្រះដែលគង់ជាម្ចាស់ជីវិតគេ។ សេចក្តីក្រោធនៃ


©2013 CrossConnect Ministries

ព្រះ បានធ្លាក់ទៅលើសត្វពស់ និងការអាក្រក់។ ឈ្មោះទាំងអស់របស់មារសាតាំង ជួនកាលគេហៅវាថា ទេវតាដែលបានធ្លាក់ចុះពីស្ថានសួគ៌ ខទី១៤ និងទី១៥ មាននិយាយអំពីការធ្លាក់ចុះរបស់វា។

- វាត្រូវព្រះជាម្ចាស់ ______________________ (ខទី១៤)។
- វានឹងត្រូវ ____________________ នឹងពោះរបស់វាអស់មួយជីវិត (ខទី១៤)។
- ក្បាលវានឹងត្រូវ ____________________ (ខទី១៥)។

ជីកឱ្យកាន់តែជ្រៅ៖ ខទី១៤ និងទី១៥ ជាខគម្ពីរដែលពិបាកយល់ ប៉ុន្តែ អ្វីដែលសំខាន់គឺត្រូវដឹងថា ខទី១៥ ជាខគម្ពីរដំបូងបង្អស់ដែលចែងអំពីសេចក្តីសន្យារបស់ព្រះ ក្នុងការប្រោសលោះមនុស្សជាតិ។ (ចំណាំ៖ កុំភ្លេចរំឭកនិយមន័យនៅក្នុងមេរៀននេះ។) ខគម្ពីរនេះសន្យាថា ព្រះនឹងផ្សះផ្សារសម្ពន្ធភាពបាក់បែក ដែលបានកើតឡើង ហើយផ្តាច់មនុស្សចេញពីទ្រង់ ព្រមទាំងរបស់ទាំងអស់ដែលទ្រង់បានបង្កើតមកទាំងអស់ផង។ ដូច្នេះ តើលទ្ធផលនៃសេចក្តីខ្លាំងដែលកើតឡើងរវាងសត្វពស់ និងពូជពង្សរបស់ស្ត្រី នឹងទៅជាយ៉ាងណា?

១. "ពូជនាងនឹងកិនក្បាលឯង" និយាយអំពីជ័យជម្នះរបស់យើង តាមរយៈការរងទុក្ខ ការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ ដែលយើងនឹងសិក្សាលម្អិតបន្ថែមទៀតនៅពេលក្រោយ ស្តីអំពីកណ្ឌគម្ពីរសញ្ញាថ្មី។ ប៉ុន្តែចំពោះអ្នកណាដែលចាប់អារម្មណ៍ចង់អានអំពីការតយុទ្ធគ្នានេះ ដើម្បីឱ្យដឹងសាច់រឿងមុន សូមអានបទគម្ពីរ ១កូរិនថូស ១៥:២០-២៨, ៥៤-៥៧។

២. "...ហើយឯងនឹងចឹកកែងជើងគេ" សំដៅលើការសុគតរបស់ព្រះយេស៊ូវ។ ពាក្យ "ចឹក" គឺជាការសុគតរបស់ទ្រង់ប្រាកដណាស់ ប៉ុន្តែ ការរស់ឡើងវិញ គឺជាជ័យជម្នះលើមារកំណាច នោះហើយជាន័យនៃពាក្យថា "កិន" ក្បាលរបស់វា។

ការទន្ទេញចាំមាត់៖ ខ្ញុំដឹងថា បទគម្ពីរលោកុប្បត្តិ ៣:១៥ គឺជាបទគម្ពីរដែលពិបាក ប៉ុន្តែ ខ្ញុំសូមលើកទឹកចិត្តអ្នករាល់គ្នាត្រូវបានលើកទឹកចិត្តឱ្យចាប់ផ្តើមទន្ទេញខគម្ពីរនេះឱ្យចាំ។ ខគម្ពីរនេះព្រមជាមួយនឹងខគម្ពីរជាច្រើនទៀតដែលអ្នកនឹងឃើញក្នុងមេរៀននេះ នឹងផ្តល់ឱ្យអ្នករាល់គ្នានូវចំណេះដឹង ពេលព្រះជាម្ចាស់បើកសម្តែងអំពីរឿងរ៉ាវនៃការប្រោសលោះដល់អ្នករាល់គ្នា តាមរយៈព្រះបន្ទូលរបស់ទ្រង់។ ចូរសរសេរ គម្ពីរលោកុប្បត្តិ ៣:១៥ ដាក់លើក្រដាសតូចមួយ រួចទន្ទេញខគម្ពីរនេះឱ្យចាំល្អ។ អ្នកក៏អាចសរសេរពាក្យថា "សេចក្តីសន្យារបស់ព្រះ" ដាក់លើក្រដាសតូចនោះដែរ ទុករំឭកអ្នករាល់គ្នា អំពីសេចក្តីសន្យាដំបូងក្នុងការប្រោសលោះអ្នករាល់គ្នា និងខ្ញុំ ហើយធ្វើឱ្យយើងក្លាយជាកូនដ៏មានតម្លៃរបស់ទ្រង់សារជាថ្មីម្តងទៀត។

លំហាត់៖ ផលនៃអំពើបាបជ្រាបចូលគ្រប់របស់ទាំងអស់ដែលព្រះបានបង្កើត។

១. ជាដំបូង លទ្ធផលនេះឃើញមានក្នុងព្រះបន្ទូលដែលទ្រង់មានបន្ទូលទៅកាន់នាងអេវ៉ា នៅក្នុងខទី១៦។ លទ្ធផលទាំង២នៃអំពើបាប ជាភ័ស្តុតាងសម្រាប់មនុស្សស្រី។ ព្រះជាម្ចាស់មានបន្ទូលថា លទ្ធផលគឺជាអ្វី?
   ក. អញនឹងចម្រើនឱ្យឯង ____________________________________________
   ខ. ចិត្តឯងនឹងប្រាថ្នា ____________________________________________

២. មនុស្សប្រុសក៏មិនស្តាប់បង្គាប់ដែរ ជីវិតរបស់អ័ដាមក៏រងលទ្ធផលពីបណ្តាសានៃអំពើបាបដែរ។ តើព្រះមានបន្ទូលថា នឹងមានអ្វីកើតឡើង ដោយសារតែអំពើបាប?
   ក. ______________ នឹងត្រូវបណ្តាសា ______________________________


©2013 CROSSCONNECT MINISTRIES

ខ. ____________________________________________ ដោយនឿយហត់...

គ. ដីនឹងដុះជា ____________________________________________

ឃ. ឯងត្រូវ ____________________________________________

ង. ដរាបដល់ឯង ____________________________________________

ផ្នែកទី៧

សេចក្តីបង្រៀន៖ ពួកគេបានប្រព្រឹត្តអំពើបាបហើយ មារសាតាំងក៏បានបង្ហាញថា វាជាអ្នកណាដែរ។ ទាំងមនុស្សប្រុស និងមនុស្សស្រី បានបើកភ្នែកមើលឃើញការពិត នៅក្នុងជីវិតដែលគេកំពុងរស់នៅនេះដែរ។ អំពើបាបមិនមែនកើតឡើងតែម្តងហើយចប់នោះទេ ប៉ុន្តែវាបានជ្រាបទៅក្នុងជីវិតទាំងអស់ និងបានក្លាយជាចំណែកមួយនៃជីវិតរស់នៅរបស់មនុស្សគ្រប់ពេលវេលា។ តើជីវិតនេះមានសណ្ឋានយ៉ាងណា? ចំណុចងាយបំផុតដែលយើងអាចយល់អំពីភាពពិតដ៏ថ្មីស្រឡាងនេះបាន គឺការពិចារណាពីពេលមួយដែលយើងនិយាយថា "ខ្ញុំនឹងមិនធ្វើ..." ក្រោយមកក៏ឃើញថា ខ្លួនឯងកំពុងប្រកាសនូវការមិនស្តាប់បង្គាប់របស់ខ្លួនដោយចេតនា ទាំងមិនសប្បាយចិត្ត។

រូបភាពដែលខ្ញុំនឹកឃើញ គឺជារូបភាពឪពុកម្តាយកំពុងសង្កេតមើលកូនរបស់ខ្លួន ដែលកំពុងទទួលរងលទ្ធផលនៃការមិនស្តាប់បង្គាប់ ទាំងឈឺចាប់។ ការដាក់វិន័យ គឺជាដកយកសិទ្ធិ បដិសេធសំណើ ឬជាការដាក់ទណ្ឌកម្មផ្សេងទៀតទុកជាលទ្ធផលនៃសកម្មភាពបះបោរ ឬការមិនស្តាប់បង្គាប់។ យើងតែងឮគេនិយាយថា "ទណ្ឌកម្មនេះ ធ្វើឱ្យប៉ាម៉ាក់ឈឺចាប់ជាងកូនឯងទៅទៀត" នេះមានន័យថា ឪពុកម្តាយទទួលរងទម្ងន់លទ្ធផលដែលដាក់ទៅលើកូនដែរ។

លំហាត់៖ ប៉ុន្តែ ទោះជាស្ថិតក្នុងកាលៈទេសៈបែបនេះក៏ដោយ ព្រះជាម្ចាស់ក៏មិនបានបោះបង់ចោលអ័ដាម និងអេវ៉ាដែរ។ ផ្ទុយទៅវិញ ទ្រង់បានលើកគេឡើង ថែរក្សាគេដោយក្តីស្រឡាញ់ ហើយឃ្លាំមើលគេទទួលលទ្ធផលនៃអំពើបាប។ មានរឿងពាកើតឡើងភ្លាមៗ ហើយរឿងនីមួយៗ សុទ្ធតែព្រះជាអ្នកចាប់ផ្តើម។

១. សូមមើលខទី៧សារជាថ្មី ពួកគេបានយកស្លឹកល្វាមកក្លាស់ ដើម្បីគ្របបាំងភាពអាក្រាតរបស់គេ។ នៅក្នុងខទី២១ តើអ្វីជាកិច្ចការដំបូងអស់ដែលព្រះជាម្ចាស់ធ្វើ? ____________________________________________

____________________________________________

ដើម្បីឱ្យសម្លៀកបំពាក់ដែលធ្វើមកនោះ នៅជាប់បានយូរ គឺទាល់តែមានការបង្ហូរឈាមសត្វ។ យកល្អ គួរតែកត់សម្គាល់សារជាថ្មីម្តងទៀតថា ព្រះជាម្ចាស់បានឱ្យយើងដឹងថា ការគ្របបាំងនៃអំពើបាប ទាមទារឱ្យមានយញ្ញបូជាជាការបង្ហូរឈាម កំណត់សម្គាល់នេះត្រូវទុកជាការបញ្ជាក់សម្រាប់ការសិក្សាលើកក្រោយ។ ដូច្នេះ គម្ពីរហេព្រើរ ៩:២២ រំឭកប្រាប់យើងថា "បើគ្មានខ្ចាយឈាមទេ____________________________________________

____________________________________________"

២. តើអ្វីទៅជាបញ្ហា (លោកុប្បត្តិ ៣:២២)? ____________________________________________

ម្តេចក៏ព្រះមិនឱ្យពួកគេចូលទៅរកដើមឈើជីវិត? ____________________________________________

តើទ្រង់ត្រូវធ្វើយ៉ាងណា? ____________________________________________

៣. តើព្រះបានដាក់អ្វីនៅខាងកើតសួន? ____________________________________________

ម្តេចក៏ចាំបាច់ដាក់ទេវតា ឬចេរូប៊ីន នៅទីនោះ? ____________________________________________


©2013 CrossConnect Ministries

**ជីកឱ្យកាន់តែជ្រៅ៖** ចូរចំណាយពេលពិចារណាមើលពីវិធីដែលព្រះបង្ហាញសេចក្តីស្រឡាញ់ដល់មនុស្ស តាមរយៈការចាប់ផ្តើមកិច្ចការ៣យ៉ាងនេះ។ ចូរសរសេរអំពីគំនិតរបស់អ្នករាល់គ្នា។

១. តាមការដែលមនុស្សប្រុស និងមនុស្សព្យាយាមគ្របបាំងខ្លួនគេពីការខ្មាសអៀន តើមានចំណុចល្អអ្វីខ្លះ?

២. ប្រសិនបើពួកគេបានបរិភោគផ្លែឈើជីវិត ហើយរស់អស់កល្បជានិច្ចក្នុងសណ្ឋានបាបរបស់គេ ដោយគ្មានសេចក្តីសង្ឃឹមថានឹងបានផ្សះផ្សារសម្ពន្ធភាពជាមួយនឹងព្រះ តើនឹងមានរឿងអ្វីកើតឡើង?

៣. ចូរពិចារណាពីសេចក្តីស្រឡាញ់របស់ព្រះ ដែលបង្ហាញមកតាមរយៈមធ្យោបាយការពារច្រកចូលទៅក្នុងសួនច្បារ ដោយដឹងច្បាស់អំពីទំនោរចិត្តរបស់គេចំពោះអំពើបាប។

**ការអធិស្ឋាន៖** ឱព្រះដ៏ជាព្រះអម្ចាស់អើយ! ទោះជាយើងខ្ញុំមានអំពើបាប ក៏ទ្រង់នៅតែស្រឡាញ់យើងខ្ញុំដែរ។ ទោះជាយើងខ្ញុំមិនស្តាប់បង្គាប់ ហើយបះបោរនឹងព្រះហឫទ័យទ្រង់យ៉ាងណា ក៏ទ្រង់នៅតែបង្ហាញសេចក្តីស្រឡាញ់ដល់យើងខ្ញុំ ថែរក្សាយើងខ្ញុំ និងរបស់ទាំងអស់ដែលទ្រង់បានបង្កើតមកដដែល។ ទ្រង់មានបន្ទូលនៅក្នុងគម្ពីរ រ៉ូម ៨:៣៩ ថា "ពុំមានអ្វីអាចនឹងពង្រាត់យើង ចេញពីសេចក្តីស្រឡាញ់របស់ព្រះ ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នាទៅបានឡើយ"។ សូមអរព្រះគុណចំពោះដំណឹងល្អអំពីព្រះគុណរបស់ទ្រង់។ ____________________

____________________________________________

**អនុសាសន៍បញ្ចប់៖** ត្រង់ចំណុចដែលអ្នករាល់គ្នាបានសិក្សាព្រះគម្ពីរលោកុប្បត្តិ ជំពូកទី៣ គឺយើងបានសិក្សានូវមេរៀនដែលអាចនឹងនាំមកនូវសំណួរជាច្រើនដល់គំនិតអ្នករាល់គ្នាហើយ។ យើងដឹងហើយថា ខគម្ពីរប៉ុន្មានខនេះ មិនអាចគ្របដណ្តប់នូវព័ត៌មានលម្អិតទាំងអស់ បាននោះទេ។ យ៉ាងណាមិញ សេចក្តីពិតដ៏សំខាន់សម្រាប់អ្នករាល់គ្នា គឺអ្នករាល់គ្នាត្រូវចាប់ផ្តើមស្គាល់ព្រះ ក្នុងនាមជាព្រះនៃសេចក្តីស្រឡាញ់ ដែលស្រឡាញ់អ្នករាល់គ្នាដោយ "សេចក្តីស្រឡាញ់ដ៏អស់កល្ប" (យេរេមា ៣១:៣) និងក្នុងនាមជាព្រះដ៏បរិសុទ្ធ ដែលមានបន្ទូលថា "ចូរឱ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ដូចព្រះវរបិតានៃអ្នក ដែលគង់នៅស្ថានសួគ៌ ទ្រង់គ្រប់លក្ខណ៍ដែរ" (ម៉ាថាយ ៥:៤៨)។ ក្នុងនាមជាព្រះដ៏បរិសុទ្ធ ទ្រង់មិនអាចគង់ជាមួយនឹងអំពើបាបបានឡើយ ហើយទ្រង់ក៏មិនអាចលើកលែងឱ្យអំពើបាប ដោយធ្វើមិនដឹងមិនឮនោះដែរ។ ជាលទ្ធផល ទ្រង់បានរៀបផែនការសង្គ្រោះមនុស្សលោកដោយសេចក្តីស្រឡាញ់ តាមរយៈ ១- ការបំផ្លាញអំពើបាប ដែលផ្តាច់ទ្រង់ចេញពីមនុស្សដែលទ្រង់ស្រឡាញ់ ២- លោះយើងពីសេចក្តីស្លាប់ដែលនឹងផ្តាច់យើងចេញពីទ្រង់អស់កល្បជានិច្ច និង ៣- លោះយើងពីមារកំណាច ជាជើងខ្លាំង និងជាអ្នកប្រព្រឹត្តអំពើបាប។ ព្រះគម្ពីរ ជារឿងរៀបរាប់ពីការដែលព្រះជាម្ចាស់សម្រេចព្រះទ័យប្រោសលោះប្រជារាស្ត្ររបស់ទ្រង់ ហើយនាំពួកគេមកក្នុងសម្ពន្ធភាពនៃសេចក្តីស្រឡាញ់ជាមួយនឹងទ្រង់សារជាថ្មីម្តងទៀត។ យ៉ាងណាមិញ ទ្រង់មិនបានធ្វើការនេះតែអង្គឯងទេ គឺទ្រង់បានសម្រេចព្រះទ័យប្រើមនុស្ស ព្រឹត្តិការណ៍នៃប្រវត្តិសាស្ត្រ និងកាលៈទេសៈនានា មកបំពេញសេចក្តីសន្យាដែលទ្រង់បានធ្វើចំពោះអ័ដាម និងអេវ៉ា ក្នុងសួនអេដែន គឺកិនក្បាលសត្រូវ ហើយនាំយករបស់ទាំងអស់ដែលទ្រង់បានបង្កើត ទៅក្នុងសម្ពន្ធភាពដែលត្រូវបានផ្សះផ្សារសារជាឡើងវិញ ជាមួយនឹងទ្រង់។ ក្តីប្រាថ្នារបស់ទ្រង់ គឺចង់ឱ្យយើងស្គាល់ទ្រង់យ៉ាងជិតស្និទថា ទ្រង់ជាព្រះដែលស្រឡាញ់ និងចង់ឱ្យយើងមានសម្ពន្ធភាពផ្ទាល់ខ្លួនជាមួយនឹងទ្រង់ តាមរយៈព្រះរាជបុត្រាទ្រង់ ព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់ និងជាព្រះអង្គសង្គ្រោះនៃយើងរាល់គ្នា។


©2013 CrossConnect Ministries

# មេរៀនទី៣

# តើខ្ញុំជាអ្នកថែរក្សាប្អូនឬអី?

## លោកុប្បត្តិ ៤-៥ - ដំណើររឿងកាអ៊ីន និងអេបិល

### និដ្ឋភាពទូទៅនៃមេរៀនទី៣

**មាតិកា**

**លំនាំដើម**

**មេរៀនទី៣៖ លោកុប្បត្តិ ៤-៥**

- តួអង្គថ្មី ត្រូវបានណែនាំឱ្យស្គាល់
- ដង្វាយដែលគេបានថ្វាយ
- កាអ៊ីនសម្លាប់អេបិល
- ផលវិបាកនៃទង្វើរបស់កាអ៊ីន
- ពូជពង្សរបស់កាអ៊ីន
- អេបិល មនុស្សដែលមានជំនឿពិត
- ការអនុវត្ត
- បញ្ជីពង្សាវតា

# លំនាំដើម

ពេលនេះអំពើបាបបានជ្រាបចូលគ្រប់របស់ដែលព្រះបានបង្កើត ឯការចុះសម្រុង នៅក្នុងចំណោមរបស់ទាំងអស់នេះ ក៏រលាយបាត់អស់ទៅដែរ។ ការស្តាប់បង្គាប់បាននាំមកនូវកំហឹង និងសេចក្តីស្លាប់មកក្នុងពិភពលោកដែលព្រះទ្រង់បានបង្កើតឡើងមក យ៉ាងល្អឥតខ្ចោះ។ ជីវិត និងសេចក្តីស្លាប់! ផ្ទុយគ្នាស្រឡះតែម្តង! នៅក្នុងគម្ពីរលោកុប្បត្តិ ជំពូកទី៤ ព្រះជាម្ចាស់បង្ហាញឱ្យយើងឃើញធាតុពិតដ៏សាហាវបំផុត នៅពេលដែលជីវិតរបស់អ័ដាម និងអេវ៉ា ត្រូវរង្គោះរង្គើដោយសារតែអំពើបាប។ ព្រះជាម្ចាស់បានប្រទានពរដល់គេ ដោយប្រទានឱ្យពួកគេមានកូន២នាក់ កាអ៊ីន ជាកូនបង និងអេបិលជាកូនប្អូន។ ការងាររបស់គេទាំងពីរនាក់នេះខុសគ្នាស្រឡះ ម្នាក់ជាអ្នកធ្វើចម្ការ ឯម្នាក់ទៀតជាអ្នកឃ្វាលហ្វូងចៀម។ គេម្នាក់ៗបានយកតង្វាយមកថ្វាយព្រះអម្ចាស់ ហើយព្រះជាម្ចាស់ទ្រង់សព្វព្រះទ័យនឹងតង្វាយរបស់អេបិល ប៉ុន្តែទ្រង់មិនសព្វព្រះទ័យនឹងតង្វាយរបស់កាអ៊ីនទេ ហេតុនេះ កាអ៊ីន ក៏មានចិត្តខឹងដោយសារព្រះជាម្ចាស់សព្វព្រះទ័យនឹងអេបិល។

ពេលនោះព្រះជាម្ចាស់ក៏យាងមករកកាអ៊ីន រួចសួរកាអ៊ីនថា "ឯងខឹងធ្វើអី ហេតុអ្វីបានជាឯងធ្វើមុខក្រញូវដូច្នេះ?" ព្រះជាម្ចាស់ត្រាស់ហៅកាអ៊ីនឱ្យស្តាប់បង្គាប់ ទ្រង់មានព្រះបន្ទូលថា "បើឯងធ្វើល្អ តើមិនបានទឹកមុខរីករាយវិញទេឬអី?" ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ចំពោះទឹកចិត្តរបស់កាអ៊ីន និងអេបិល ពេលដែលពួកគេថ្វាយតង្វាយដល់ព្រះអង្គ។ ទ្រង់បានបន្តយកព្រះទ័យទុកដាក់ចំពោះគេដោយព្រះគុណករុណា តាមរយៈការដាស់តឿនកាអ៊ីនថា អំពើបាបកំពុងតែលួននៅក្បែរគាត់ រង់ចាំមើលចន្លោះណាដែលអាចឱ្យវាចូលក្នុងចិត្តរបស់គាត់បាន ហើយគ្រប់គ្រងលើគាត់។

កាអ៊ីនបានសម្រេចចិត្តមិនយកព្រះបន្ទូលដាស់តឿនរបស់ព្រះ ធ្វើជាបណ្តូលជីវិតរបស់គាត់ឡើយ ប៉ុន្តែ គាត់បែរជាសម្រេចចិត្តឱ្យអំពើបាបចូលមកក្នុងចិត្តគាត់ទៅវិញ។ ព្រះជាម្ចាស់ចង់ឱ្យកាអ៊ីនមានរបស់ដែលប្រសើរបំផុត ប៉ុន្តែ គាត់បែរជាបណ្តោយឱ្យការអាក្រក់យកឈ្នះជីវិតគាត់ទៅវិញ។ ក្រោយមក ព្រះជាម្ចាស់ក៏បានមករកកាអ៊ីនជាលើកទី២ រួចសួរគាត់ថា "ប្អូនឯងនៅឯណា?" កាអ៊ីនក៏ឆ្លើយវិញទាំងកុហកថា "ទូលបង្គំមិនដឹងទេ"។ សំណួរដែលកាអ៊ីនសួរថា "តើទូលបង្គំជាអ្នកថែរក្សាប្អូនឬអី?" គឺជាសំណួរដូចគ្នា ដែលគេធ្លាប់បានសួរ នៅក្នុងប្រវត្តិសាស្ត្រទាំងមូល។

នៅក្នុងគម្ពីរលោកុប្បត្តិ ជំពូកទី៤ ព្រះជាម្ចាស់បង្ហាញពីតម្លៃដែលទ្រង់បានដាក់ក្នុងជីវិតមនុស្ស និងទំនួលខុសត្រូវដែលទ្រង់ប្រទានដល់យើងម្នាក់ៗ ឱ្យធ្វើជាអ្នកថែរក្សាបងប្អូនរបស់យើង។ ដោយសារអំណាចដ៏អន្តរាយនៃទំនោរដែលយើងមានចំពោះការប្រព្រឹត្តទង្វើអាក្រក់ ពេលនេះព្រះជាម្ចាស់ត្រូវទាញឱ្យយើងចូលក្នុងសម្ពន្ធភាពនៃសេចក្តីស្រឡាញ់ជាមួយមនុស្សដទៃ ពេលយើងធ្វើការរួមគ្នាជាមួយទ្រង់ដើម្បីថែរក្សាអ្នកដទៃ។ ក្នុងការសិក្សាមេរៀននេះ ចូរអ្នករាល់គ្នាសួរខ្លួនឯងថា ១- តើអ្នកណាជាបងប្អូនប្រុសស្រីរបស់ខ្ញុំ? ២- តើខ្ញុំថែរក្សាពួកគេដោយវិធីណា? ៣- តើព្រះជាម្ចាស់ហៅខ្ញុំឱ្យធ្វើជាព្រះពរដោយសេចក្តីស្រឡាញ់ និងសេចក្តីសប្បុរសរបស់ទ្រង់ ដល់អ្នកណាខ្លះ?

"តើខ្ញុំជាអ្នកថែរក្សាប្អូនឬអី?" ចម្លើយមានច្បាស់ណាស់ គឺ "មែន" ហើយវាគឺជាឯកសិទ្ធិដ៏វិសេសវិសាលបំផុត! ចូររីករាយសប្បាយនឹងចំណេះដឹង និងការរកឃើញទាំងអស់នេះ ដ្បិតព្រះវិញ្ញាណដ៏បរិសុទ្ធនៃព្រះ បើកភ្នែកដួងចិត្តអ្នករាល់គ្នា ឱ្យដឹងថា ជីវិតរបស់អ្នកផ្ទាល់ និងជីវិតរបស់បងប្អូនរស់នៅតាមសហគមន៍ មានតម្លៃណាស់ចំពោះព្រះអង្គ។


©2013 CrossConnect Ministries

## ផ្នែកទី១

សេចក្ដីផ្ដើម៖ អ័ដាម និងអេវ៉ា ត្រូវព្រះជាម្ចាស់បណ្ដេញចេញ លែងឱ្យរស់នៅក្នុងសួនអេដែនទៀតហើយ យើងអាចមើលឃើញពួកគាត់កំពុងតែដើរចេញទៅឆ្ងាយ ហើយដឹងថា នៅពីក្រោយពួកគាត់ មានចេរូប៊ីនកាន់ដាវភ្លើង "ឆេះរវើបរវៃគ្រប់ទិស ដើម្បីនឹងរក្សាផ្លូវទៅឯដើមជីវិត" នេះរូបភាពមួយដ៏ឈឺចាប់បំផុត។ គ្មានមនុស្សណាអាចជួយបានទេ ក្រៅតែពីគិតឆ្ងល់ក្នុងចិត្ត ចំពោះរឿងរ៉ាវដែលកើតឡើង។ ពួកគាត់មិនធ្លាប់រស់នៅក្រៅសួនអេដែនទេ ពួកគាត់ក៏មិនធ្លាប់រស់នៅដោយឯកឯងដែរ ពួកគាត់ធ្លាប់តែមានព្រះផ្គត់ផ្គង់អ្វីៗគ្រប់យ៉ាង ហើយកិច្ចការដែលគេធ្វើ គឺទទួលយកនូវការផ្គត់ផ្គង់ពីទ្រង់តែប៉ុណ្ណោះ។ ភាពចុះសម្រុងដែលធ្លាប់មាន រវាងពួកគាត់ និងរបស់សព្វសារពើ រលាយអស់ហើយ ហើយជីវិតរបស់ពួកគាត់ពេលនេះ នឹងទៅជាយ៉ាងណា ដ្បិតអ័ដាមត្រូវធ្វើស្រែចម្ការនៅលើដីដែលនឹងដុះជាបន្លា និងអញ្ចាញ ដោយការនឿយហត់។ នាងអេវ៉ាប្រាកដជាមិនដឹងទេថា ការបង្កើតកូនមានការឈឺចាប់យ៉ាងណា ហើយក៏មិនដឹងដែរថា ការដែលប្ដីត្រួតត្រា នោះមានសណ្ឋានយ៉ាងណាដែរ។ ហើយពេលនេះ ព្រះជាម្ចាស់នៅឯណា?

នេះជាលើកដំបូងដែលពួកគេស្គាល់ពីភាពឯកា ទោះជាពួកគេនៅជាមួយគ្នាក្នុងជីវិតអាពាហ៍ពិពាហ៍ក៏ដោយ អំពើបាបបានធ្វើឱ្យសម្ពន្ធភាពរបស់បាក់បែក នេះជាកត្តាថ្មីមួយទៀតដែលពួកគេពុំធ្លាប់ជួបប្រទះពីមុន។ យើងអាចត្រឡប់ទៅមើលព្រះបន្ទូលក្នុង លោកុប្បត្តិ ២:២៤ "នោះអ្នកទាំង២ ត្រឡប់ជាសាច់តែមួយសុទ្ធ"។ ក្រៅពីនេះ សម្ពន្ធភាពរបស់ពួកគេជាមួយព្រះជាម្ចាស់ ក៏បានផ្លាស់ប្ដូរដែរ។ អំពើបាប បាននាំមកនូវភាពខ្មាសអៀន និងទោសកំហុស ដែលកាត់ផ្ដាច់ពួកគេចេញពីព្រះជាម្ចាស់ ពួកគេបានលាក់ខ្លួនបំពួនកាយពីព្រះជាម្ចាស់ និងពីគ្នាទៅវិញទៅមក។ រឿងនេះកាន់តែអាក្រក់ទៅនៅពេលដែលយើងដឹងថា អំពើបាបបំផ្លាញសម្ពន្ធភាពគ្រួសាររបស់គេ យ៉ាងធ្ងន់ធ្ងរ។

គេហកិច្ច៖ សូមអាន លោកុប្បត្តិ ជំពូក៤

ចំណាំ៖ មានចំណុចពិសេស និងព័ត៌មានលម្អិតជាច្រើន មិនបានកត់ត្រាទុកក្នុងជំពូកនេះ។ តាមការពិត ពេលអ្នករាល់គ្នាសិក្សាកណ្ឌគម្ពីរលោកុប្បត្តិជំពូក៤នេះចប់ អ្នករាល់គ្នាប្រហែលជាមានសំណួរច្រើនជាចម្លើយ។ គោលបំណងនៃជំពូកដំបូងៗក្នុងកណ្ឌគម្ពីរលោកុប្បត្តិ គឺបង្ហាញឱ្យឃើញអំពីការបំផ្លិចបំផ្លាញរបស់មារសាតាំង និងមហន្តរាយដែលបង្កឡើងដោយអំពើបាប ពេលដែលមនុស្សទាក់ទងនឹងព្រះជាម្ចាស់ ទាក់ទងនឹងគ្នាទៅវិញទៅមក ហើយទាក់ទងនឹងអ្វីៗទាំងអស់ដែលទ្រង់បានបង្កើត។ ខ្មាំងសត្រូវបានបង្ហាញអំពីសព្វាវុធ និងអំណាចរបស់វាក្នុងការបង្កការឈឺចាប់ ការបាក់បែក និងការបំផ្លិចបំផ្លាញ សារជាថ្មីនៅក្នុងជំពូកនេះ។ ព្រះគម្ពីរយ៉ូហាន ១០:១០ រំឭកប្រាប់យើងថា សត្រូវវាមកប្រយោជន៍តែនឹងលួច សម្លាប់ ហើយបំផ្លាញប៉ុណ្ណោះ ដូច្នេះ ចូរយើងបន្តការសិក្សារបស់យើង ដោយចងចាំចំណុចនេះទុកក្នុងចិត្ត។ ជំពូកទី៤ លាតត្រដាងអំពីភាពវេទនានៃអំពើបាប ពេលដែលវាជ្រាបចូលក្នុងជីវិតគ្រួសារ។ ពេលដែលការនេះត្រូវបានលាតត្រដាងមកដូច្នេះ យើងត្រូវសម្លឹងរកព្រះវត្តមាន និងជំនួយមកពីព្រះ ដ្បិតទ្រង់ជាព្រះដែលថែរក្សារបស់សព្វសារពើដែលទ្រង់បានបង្កើតមក ដោយសេចក្ដីស្រឡាញ់។

លំហាត់៖

១. តួអង្គសំខាន់ៗនៅក្នុងគម្ពីរលោកុប្បត្តិជំពូក៤ ផ្លាស់ប្ដូរយ៉ាងរហ័សដោយរៀបរាប់ថា "អ័ដាមក៏អេវ៉ាជាប្រពន្ធ..." តើកូនទាំង២របស់ពួកគាត់ ឈ្មោះអ្វីខ្លះ? ____________________ និង ________________________

២. តើយើងដឹងអ្វីខ្លះអំពីកិច្ចការកូនទាំងពីររបស់ពួកគាត់ (ខទី២)?

ក. កិច្ចការរបស់អេបិល? ________________________________________________

ខ. កិច្ចការរបស់កាអ៊ីន? ____________________________________________

៣. "កន្លងក្រោយមក" កាអ៊ីន និងអេបិលក៏បាននាំយកផលពីកិច្ចការរបស់ខ្លួន មកថ្វាយព្រះអម្ចាស់។ តើគេម្នាក់ៗនាំយកអ្វីខ្លះមកថ្វាយ (ខទី៣ និងទី៤)?

ក. កាអ៊ីនបានយក ____________________________________________

ខ. អេបិលបានយក ____________________________________________

៤. តើព្រះជាម្ចាស់ឆ្លើយតបយ៉ាងណាចំពោះដង្វាយរបស់ពួកគេម្នាក់ (ខទី៤-៥)?

ក. ចំពោះដង្វាយរបស់អេបិល ____________________________________________

ខ. ចំពោះដង្វាយរបស់កាអ៊ីន ____________________________________________

៥. តើកាអ៊ីនមានប្រតិកម្មយ៉ាងណា ចំពោះការដែលព្រះមិនសព្វព្រះទ័យ (ខទី៥)? ____________________

____________________________________________________________

## ផ្នែកទី២

សេចក្ដីបង្រៀន៖ បើមើលមួយភ្លែត ព្រះជាម្ចាស់ហាក់ដូចជាប្រព្រឹត្តចំពោះបងប្អូនទាំងពីរនាក់នេះ មិនស្មើភាពសោះ ហើយជាលទ្ធផល ទ្រង់ហាក់ដូចជាបង្កើតឱ្យមានការបែកបាក់រវាងបងប្អូនទាំង២នាក់នេះ។ យើងមិនដឹងទេថា ព្រះទ្រង់បានណែនាំពួកគេអំពីកិច្ចការដែលនាំឱ្យមានការថ្វាយដង្វាយដែលត្រឹមត្រូវ នឹងគាប់ដល់ព្រះហឫទ័យទ្រង់ ឬយ៉ាងណា។ យើងគ្រាន់តែដឹងនូវអ្វីដែលខទី៤ប្រាប់យើងថា "ព្រះយេហូវ៉ាទ្រង់សព្វព្រះទ័យចំពោះអេបិល និងដង្វាយរបស់គាត់"។ តើដង្វាយរបស់អេបិលមានអ្វីខ្លះ បានជាព្រះទ្រង់សព្វព្រះទ័យនឹងគាត់ដូច្នេះ? យើងដឹងរឿងមួយគឺ អេបិលបាននាំយកខ្លាញ់សត្វ នេះមានន័យថា ត្រូវតែមានការបង្ហូរឈាមសត្វ ដើម្បីឱ្យបានខ្លាញ់នោះ។

ចូរនឹកចាំពីការសិក្សារបស់យើង ក្នុងគម្ពីរលោកុប្បត្តិ ៣:២១ ថា ព្រះជាម្ចាស់បានបិទបាំងកាយអ័ដាម និងភរិយារបស់គាត់ដោយអាវពីស្បែកសត្វ ហើយដើម្បីឱ្យបានស្បែកសត្វ ដាច់ខាតត្រូវតែមានការខ្ចាយឈាម។ បើទោះជាខគម្ពីរនេះពុំមានអ្វីបញ្ជាក់ប្រាប់យើងពីសារៈប្រយោជន៍នៃការខ្ចាយឈាមក៏ពិតមែន ប៉ុន្តែ ខគម្ពីរផ្សេងទៀតបង្រៀនប្រាប់យើងថា ការខ្ចាយឈាម គឺជាកិច្ចការដ៏ចាំបាច់សម្រាប់ការប្រោសលោះមនុស្សលោក។ គឺឈាមនេះហើយដែលគ្របបាំងអំពើបាប នេះជាចំណុចសំខាន់ដែលយើងត្រូវយល់ ពេលយើងត្រឡប់ទៅមើលព្រឹត្តិការណ៍ជាច្រើនឆ្នាំក្រោយមក នោះយើងនឹងឃើញព្រះលោហិតរបស់ព្រះយេស៊ូវ ត្រូវបង្ហូរនៅលើឈើឆ្កាង។ ការខ្ចាយលោហិតរបស់ព្រះយេស៊ូវ គឺយញ្ញបូជាចុងក្រោយបង្អស់ សម្រាប់គ្របបាំងអំពើបាបរបស់លោកិយទាំងមូល។ យើងនឹងសិក្សាពីចំណុចនេះឱ្យកាន់តែលម្អិត ជាបន្តទៀតនៅពេលក្រោយ។

លំហាត់៖

១. ហេតុនេះ "កាអ៊ីនក៏ ____________ ហើយទឹកមុខរបស់គាត់ ____________________។"
ដ្បិតព្រះមិនសព្វព្រះទ័យនឹងទទួលយកកាអ៊ីន និងដង្វាយរបស់គាត់ ហើយគាត់ក៏គិតថា គ្មានអ្នកណារាប់រក។ ព្រះជាម្ចាស់ក៏យាងមកឯកាអ៊ីន រួចសួរគាត់ថា ហេតុអ្វីបានជាគាត់ខឹង ហើយមានទឹកមុខក្រញូវដូច្នេះ។

២. តើព្រះជាម្ចាស់សួរគាត់យ៉ាងម៉េចទៀត នៅក្នុងខទី៧? "ប្រសិនបើឯងធ្វើ ____________________
____________________________________________________________?"

៣. បន្ទាប់មកក៏សួរថា "ប៉ុន្តែ បើ ____________________________________________។"


©2013 CROSSCONNECT MINISTRIES

សេចក្ដីបង្រៀន៖ តើខគម្ពីរនេះស្ដាប់ទៅស្រដៀងនឹងពាក្យ "តែ (ប៉ុន្តែ)" ដែលព្រះជាម្ចាស់ទ្រង់មានបន្ទូលនៅក្នុងគម្ពីរលោកុប្បត្តិ ២:១៧ ទេឬអី? ព្រះជាម្ចាសសួរទៅកាអ៊ីនថា "តើឯងនឹងបម្រើអ្នកណា?" អំពើបាបមិនរំលងមនុស្សជំនាន់ណាមួយទេ វាបន្តពីឪពុកទៅដល់កូន។ ព្រះជាម្ចាស់ប្រព្រឹត្តចំពោះកាអ៊ីនដោយសេចក្ដីស្រឡាញ់ ទាំងមករកគាត់ហើយបន្ទូលថា "ចូរកុំបណ្ដោយឱ្យអំពើបាបគ្រប់គ្រងឯងឱ្យសោះ!" តាមពិត ព្រះជាម្ចាស់កំពុងប្រាប់កាអ៊ីនថា ទ្រង់ស្រឡាញ់គាត់ ហើយចង់ធ្វើជាម្ចាស់ជីវិតរបស់គាត់ ប៉ុន្តែ ឯខ្មាំងសត្រូវវិញ វាគ្មានក្ដីមេត្តានោះទេ។

សំណួរ៖

១. "អំពើបាបកំពុងក្រាបនៅមាត់ទ្វារឯងស្រាប់ហើយ" តើពាក្យនេះបង្ហាញឱ្យអ្នករាល់គ្នាឃើញរូបភាពអ្វី? អ្នករាល់គ្នាក៏ប្រហែលជាចង់ពិចារណាអំពីបទគម្ពីរ ១ពេត្រុស ៥:៨ ផងដែរ។ ____________________________

_______________________________________________

២. វិវរណៈ ៣:២០ បង្ហាញអំពីរូបភាពព្រះយេស៊ូវដែលកំពុងឈរនៅមាត់ទ្វារចិត្តយើង។ ចូរសរសេរខគម្ពីរនេះ៖

_______________________________________________

_______________________________________________

៣. ចូរសម្គាល់ភាពខុសគ្នាក្នុងកាយវិការ

ក. បាបកំពុង ________________________ នៅមាត់ទ្វារ (លោកុប្បត្តិ ៤:៧ - ព្រះគម្ពីរជីវិតសុទ្ធ)។

ខ. ព្រះយេស៊ូវកំពុង ______________________________ នៅមាត់ទ្វារ (វិវរណៈ ៣:២០)។

ព្រះយេស៊ូវរង់ចាំឱ្យគេអញ្ជើញឱ្យចូល ចំណែកឯអំពើបាបវិញ វាដេក ឬក្រាបនៅមាត់ទ្វារ រង់ចាំឱកាសឆ្មក់ចូលទៅបំផ្លាញ។

ផ្នែកទី៣

គេហកិច្ច៖ សូមអានខទី៨ ម្ដងទៀត។ កាអ៊ីន ពេញដោយកំហឹង ហើយគាត់ក៏បបួលអេបលជាប្អូន ទៅឯចម្ការ ហើយគាត់ក៏វាយសម្លាប់ប្អូន នៅក្នុងចម្ការនោះទៅ។ អំពើមនុស្សឃាតត្រូវបានរៀបរាប់យ៉ាងសាមញ្ញ គ្មានបច្ចេកវិទ្យាហ្វូលីវូដ គ្មានល្បិចបន្លំ ឬបំភ័ន្តអ្វីទាំងអស់ គឺគ្មានទេ។ កាអ៊ីន គ្រាន់តែវាយសម្លាប់ប្អូនរបស់គាត់ចោលតែម្ដង។

តើមានអ្វីកើតឡើងជាបន្តទៀត? តើអ្នកណាដែលបានត្រឡប់ទៅឱ្យកាអ៊ីនទទួលខុសត្រូវលើជីវិតប្អូនប្រុសគាត់? តើអ្នករាល់គ្នាឃើញពីភាពដូចគ្នានឹងកាលដែលព្រះមានបន្ទូលសួរ អ័ដាម និងអេវ៉ាថា "ឯងនៅឯណា?" ក្នុងលោកុប្បត្តិ ៣:៩ ពេលដែលពួកគេទើបបរិភោគផ្លែឈើដែលព្រះជាម្ចាស់បានហាម ដែរឬទេ? ពេលនេះព្រះជាម្ចាស់ និងកាអ៊ីន ធ្វើការសន្ទនាជាមួយគ្នា...

សំណួរ៖

១. តើព្រះជាម្ចាស់សួរកាអ៊ីន យ៉ាងដូចម្ដេច? ______________________________

២. តើកាអ៊ីនឆ្លើយតបវិញ យ៉ាងដូចម្ដេច? ______________________________

៣. តើព្រះជាម្ចាស់សួរកាអ៊ីន យ៉ាងដូចម្ដេចទៀត? ______________________________

៤. ចូរចំណាយពេលត្រឡប់ទៅអាន លោកុប្បត្តិ ជំពូក៣វិញ។ តើព្រះជាម្ចាស់សួរពួកគេម្ដេចខ្លះ ក្នុងខទី១៣? ____

_______________________________________________

_______________________________________________


©2013 CROSSCONNECT MINISTRIES

អំពើបាប នៅតែបន្តមាតិនៃការសេចក្ដីអន្ដរាយរបស់វាដដែល។ ប្អូនរបស់កាអ៊ីនបានស្លាប់បាត់ទៅហើយ ប៉ុន្តែពីមុនមក ការស្លាប់របស់មនុស្សពុំធ្លាប់កើតមានឡើយ។ តើនេះជាអ្វី? ព្រះជាម្ចាស់ឱ្យកាអ៊ីនទទួលខុសត្រូវចំពោះសម្រែកឈាមប្អូនរបស់គាត់។ ពេលដែលមនុស្សណាម្នាក់ មិនធ្លាប់អានព័ត៌មាន ឬមើលទូរទស្សន៍ឃើញអំពើហិង្សាដែលឈានទៅដល់សេចក្ដីស្លាប់ នោះយើងប្រាកដជាមិនដឹងអំពីតម្លៃដែលព្រះជាម្ចាស់បានដាក់នៅក្នុងជីវិតរបស់មនុស្សទេ។

លំហាត់៖

១. ព្រះបន្ទូលដែលទ្រង់បានថ្លែងបន្ទាប់មកទៀត (ក្នុងខទី១០) សម្ដែងឱ្យឃើញយ៉ាងច្បាស់៖ "ឯងបានធ្វើអ្វីដូច្នេះ! ______________ របស់ប្អូនឯង ______________
______________________________។"
គ្រប់របស់ទាំងអស់ដែលទ្រង់បានបង្កើតមក សុទ្ធតែមានតម្លៃចំពោះទ្រង់ ហើយទ្រង់បានឮសម្រែកឈាមមនុស្សដែលទ្រង់ស្រឡាញ់ ពីដីមក (លោកុប្បត្តិ ៣:១០)។

២. សូមបញ្ជាក់ម្ដងទៀតថា អំពើបាប មានលទ្ធផលរបស់វា។ តើលទ្ធផលនៃអំពើបាបដែលព្រះជាម្ចាស់បានប្រកាសថានឹងកើតចំពោះកាអ៊ីន ដោយសារតែគាត់សម្លាប់ប្អូនប្រុសរបស់ខ្លួន គឺជាអ្វី (លោកុប្បត្តិ ៤:១១-១២)?
ក. "ឯងត្រូវ ______________________________"
ខ. "កាលណាឯងធ្វើស្រែចម្ការ ______________________________"
គ. "ឯងត្រូវ ______________________________"

៣. ចុះកាអ៊ីនមានប្រតិកម្មយ៉ាងដូចម្ដេច? ______________________________
ដីដែលគាត់ធ្វើជារបរចិញ្ចឹមជីវិត ត្រូវបណ្ដាសា ហើយ "លែងបង្កើតផល" សម្រាប់គាត់ទៀតហើយ។ តើកាអ៊ីននិយាយអ្វីខ្លះទៀត ទាក់ទងនឹងទណ្ឌកម្មរបស់គាត់ (ខទី១៤)?
ក. "ទ្រង់បានបណ្ដេញ ______________________________"
ខ. "ទូលបង្គំនឹងត្រូវ ______________________________"
គ. "ហើយត្រូវ ______________________________"
ឃ. "រួចអស់អ្នកណា ______________________________"

៤. ចូរកត់សម្គាល់ថា តើព្រះជាម្ចាស់ធ្វើអ្វីបន្ទាប់ទៀតនៅក្នុងខទី១៥?
ក. តើទ្រង់មានបន្ទូលអ្វីខ្លះ? ______________________________
ខ. តើព្រះជាម្ចាស់ទ្រង់ធ្វើអ្វីខ្លះ? ______________________________
*ចំណាំ៖* យើងរាល់គ្នាមិនដឹងទេថា ស្នាមដៅនោះមានសណ្ឋានយ៉ាងណា ប៉ុន្តែ ចំពោះកាអ៊ីនវិញ ស្នាមដៅនោះជាសញ្ញាសម្គាល់នៃសេចក្ដីសប្បុរសរបស់ព្រះជាម្ចាស់ ដ្បិតគាត់មិនសងនឹងទទួលបានអ្វីទាំងអស់ ក្រៅតែពីសេចក្ដីក្រោធរបស់ព្រះជាម្ចាស់។

៥. លោកុប្បត្តិ ៤:១៦ រៀបរាប់ថា កាអ៊ីន ______________________________
______________________________
យើងអាចត្រឡប់ទៅរំឭកចុងជំពូកទី៣ម្ដងទៀត ហើយយើងឃើញថា កាអ៊ីនកំពុងចាកចេញពីព្រះវត្តមានរបស់ព្រះ ទៅរស់ក្នុងស្រុកផ្សេងមួយទៀត ដូចដែលយើងឃើញអ័ដាម និងអេវ៉ា ចាកចេញពីសួនអេដែនដូច្នេះដែរ។


©2013 CrossConnect Ministries

ផ្នែកទី៤

សេចក្តីបង្រៀន៖ ចូរយើងក្រឡេកមើលពីពូជពង្សរបស់កាអ៊ីន ដោយសង្ខេប និងមើលពីដំណើររីកចម្រើនដែលពូជពង្សរបស់គាត់បានធ្វើដល់ផែនដី នៅសម័យនោះ។

១. ខទី១៧ ប្រាប់យើងថា គាត់កើតបានកូនប្រុសម្នាក់ ហើយគាត់ដាក់ឈ្មោះថា ____________________។

២. ក្នុងខដដែលនោះ យើងដឹងថា កាអ៊ីន ក៏ __________________________ ហើយគាត់ដាក់ឈ្មោះក្រុងនោះថា ______________________ តាមឈ្មោះកូនរបស់គាត់។

៣. បន្ទាប់មកក៏មានការកត់ត្រាអំពីពូជពង្សរបស់កាអ៊ីន៖

ក. ខទី២០៖ យ៉ាបាល ជាឪពុកនៃអស់ពួកអ្នកដែល __________________________________

ខ. ខទី២១៖ យូបាល ជាឪពុកនៃអស់ពួកអ្នកដែល ___________________________________

គ. ខទី២២៖ ទូបាល-កាអ៊ីន ជា _______________________________________________

*ចំណាំ៖* នេះគឺជាកំណត់សម្គាល់ដែលគួរឱ្យចាប់អារម្មណ៍ ដ្បិតការសាងសង់ ការចិញ្ចឹមសត្វ និងការលេងតន្ត្រីដែលលើកឡើងមកនេះ លេចចេញមកស្រេចទៅហើយ នៅក្នុងវប្បធម៌សម័យនោះ។

៤. យើងឃើញអំពីពូជពង្សរបស់អ័ដាម និងអេវ៉ា នៅក្នុងខទី២៥-២៦។ នាងអេវ៉ា បង្កើតបានកូនប្រុសមួយឈ្មោះ _____________ ហើយសេត ក៏បង្កើតបានកូនប្រុសមួយឈ្មោះ _________________ ។

៥. ជាងនេះទៅទៀត នៅក្នុងខទី២៦ យើងឃើញថា ព្រះជាម្ចាស់បានទាក់ទងជាមួយនឹងប្រជារាស្ត្ររបស់ទ្រង់ ពេលដែលពួកគេចាប់ផ្តើម _________________________________________________

ចំណុចនេះប្រាប់ឱ្យយើងដឹងអំពីជីវិតក្នុងការថ្វាយបង្គំ និងការអធិស្ឋាន របស់ប្រជារាស្ត្រទ្រង់ ពេលដែលគេចាប់ផ្តើមអំពាវនាវរកទ្រង់។

ជីកឱ្យកាន់តែជ្រៅ៖ ចូររកមើលផ្នែកផ្សេងក្នុងព្រះគម្ពីរ ដែលផ្តល់ព័ត៌មានបន្ថែមទាក់ទងនឹងអេបិល ដោយប្រើខគម្ពីរយោង។ ប្រសិនបើអ្នករាល់គ្នាមើលនៅក្នុងគម្ពីរ លោកុប្បត្តិ ៤:២ ព្រះគម្ពីរអាចនឹងផ្តល់នូវខយោង ដោយស្វែងរកពាក្យ "អេបិល"។ ពុំនោះទេ អ្នកអាចស្វែងរកមើលខយោង ដោយស្វែងរកតាមពាក្យថា "ដង្វាយ" ក្នុងខទី៤។ នៅក្នុងតារាងខយោង ចូរស្វែងរកខគម្ពីរឆ្លើយឆ្លង ឬពាក្យឆ្លើយឆ្លង ដោយប្រើពាក្យទាំងពីរនេះ។ គម្ពីរហេព្រើរ ១១:៤ អាចជាខគម្ពីរយោងមួយក្នុងចំណោមនោះ។

កណ្ឌគម្ពីរហេព្រើរ ស្ថិតនៅចុងនៃព្រះគម្ពីរសញ្ញាថ្មី។ គម្ពីរហេព្រើរជំពូក១១ គេហៅថា "ជំពូកនៃសេចក្តីជំនឿ"។ ប្រសិនបើអានជំពូកនេះត្រួសៗ អ្នកនឹងសម្គាល់ឃើញថា ខគម្ពីរមួយចំនួនចាប់ផ្តើមដោយពាក្យថា "ដោយសារសេចក្តីជំនឿ"។ អ្នករាល់គ្នានឹងសម្គាល់ឃើញផងដែរថា មានឈ្មោះតួអង្គជាច្រើននៅក្នុងព្រះគម្ពីរ មានសរសេរក្នុងជំពូកនេះ។ ឧទាហរណ៍ ឈ្មោះរបស់លោកណូអេ មានសរសេរនៅក្នុងខទី៧ ឈ្មោះរបស់លោកអ័ប្រាហាំ មានសរសេរនៅក្នុងខទី៨ លោកយ៉ាកុប លោកយ៉ូសែប លោកម៉ូសេ និងតួអង្គដទៃទៀត គឺជាមនុស្សដែលស្ថិតនៅក្នុងចំណោមបុព្វបុរសដែលព្រះជាម្ចាស់ទ្រង់សរសើរពីសេចក្តីជំនឿរបស់គេ។

និយមន័យ៖

- ***សេចក្តីជំនឿ*** - នៅក្នុងគម្ពីរហេព្រើរ ១១:១ សេចក្តីជំនឿត្រូវគេជានិយមន័យថា _______________

_________________________________________________________________


©2013 CROSSCONNECT MINISTRIES

ប្រសិនបើយើងក្រឡេកទៅមើលនៅខទី៤ ឈ្មោះរបស់អេបិល ក៏ត្រូវបានរៀបរាប់ថាជាមនុស្សដែលគេសរសើរពីសេចក្តីជំនឿរបស់គាត់ដែរ។ មានកិច្ចការ៣យ៉ាង ដែលគេបានរៀបរាប់អំពីអេបិល៖

១. ដោយសារសេចក្តីជំនឿ ______________________________

២. ដោយសារសេចក្តីជំនឿ ______________________________

៣. ដោយសារសេចក្តីជំនឿ ______________________________

តើខគម្ពីរនេះ ផ្តល់នូវចំណេះដឹងអ្វីខ្លះដល់ការសិក្សារបស់អ្នករាល់គ្នា ទាក់ទងទៅនឹងដំណើររឿងរបស់កាអ៊ីន និង អេបិល នៅក្នុងលោកុប្បត្តិ ជំពូក៤? ______________________________

______________________________

សំណួរអនុវត្ត៖ នៅក្នុងគម្ពីរ លោកុប្បត្តិ ៤:៩ ព្រះជាម្ចាស់សួរកាអ៊ីន នូវសំណួរមួយថា "ប្អូនឯងនៅឯណា?"

១. ក្នុងជីវិតខ្ញុំ តើមាននរណាខ្លះដែលខ្ញុំចាត់ទុកជា "បងប្អូន" របស់ខ្ញុំ? ______________________________

២. តើកាអ៊ីន ឆ្លើយតបវិញភ្លាម យ៉ាងដូចម្តេច? ______________________________

៣. តើខ្ញុំអាចបង្ហាញនូវការយកចិត្តទុកដាក់ចំពោះអស់អ្នកដែលខ្ញុំចាត់ទុកជាបងប្អូនរបស់ខ្ញុំ ដោយរបៀបណាខ្លះ?

______________________________

៤. ជួនកាល ពេលមានគេសួរខ្ញុំអំពីបងប្អូនរបស់ខ្ញុំ ខ្ញុំក៏ទទួលស្គាល់ដែរថា ខ្ញុំមិនដឹងថាទេថាគេនៅឯណា ហេតុអ្វី?

______________________________

៥. តើគម្ពីរម៉ាថាយ ២៥:៣៧-៤០ ផ្តល់នូវគំនិតអ្វីខ្លះ? ហេតុអ្វីបានជាព្រះយេស៊ូវខ្វល់ខ្វាយអំពីរឿងប្អូនប្រុសរបស់កាអ៊ីនយ៉ាងនេះ? ចុះបងប្អូនខ្ញុំ? ______________________________

ការអធិស្ឋាន៖ ឱព្រះអម្ចាស់អើយ ការបន្ទោសកាអ៊ីន ហើយនិយាយថា "ខ្ញុំមិនធ្វើដូចជាគាត់" គឺជារឿងងាយណាស់។ ប៉ុន្តែ ទូលបង្គំដឹងថា ទូលបង្គំតែងធ្វើឱ្យបងប្អូនដទៃទៀតឈឺចាប់ និងជំពប់ចិត្តជារឿយៗដោយសារសម្តី និងការប្រព្រឹត្តរបស់ទូលបង្គំ។ សូមអត់ទោសដល់ទូលបង្គំ ហើយផ្សះផ្សារសម្ពន្ធភាពរបស់ទូលបង្គំ និងអ្នកដទៃផង។ សូមជួយឱ្យទូលបង្គំអាចប្រព្រឹត្តចំពោះអ្នកដទៃ ដោយទំនួលខុសត្រូវ ការគោរព និងសេចក្តីស្រឡាញ់ ដូចជាទ្រង់បានប្រព្រឹត្តចំពោះទូលបង្គំដោយសេចក្តីសប្បុរស និងសេចក្តីស្រឡាញ់ដែរ។ ______________________________

______________________________

______________________________

## ផ្នែកទី៥

ការណែនាំឱ្យស្គាល់បញ្ជីពង្សាវតារ៖ គម្ពីរលោកុប្បត្តិ ជំពូក៥ ចាប់ផ្តើមដោយរំឭកពីការបង្កើតមនុស្សពីលោកុប្បត្តិ ជំពូក១ ហើយក្នុងខទី៣ ក៏បន្តប្រាប់នូវព័ត៌មានថ្មី មុនពេលរៀបរាប់លម្អិត អំពីបញ្ជីពង្សាវតាដែលចាប់ផ្តើមពីអ័ដាម និងគ្រួសាររបស់គាត់។ នៅក្នុងជំពូកនេះ អ្នករាល់គ្នានឹងសម្គាល់ឃើញថា មនុស្សទាំងអស់នេះ មានអាយុច្រើនឆ្នាំណាស់។ ទិន្នន័យនេះអាចនឹងលើកជាសំណួរដ៏គួរឱ្យចាប់អារម្មណ៍ខ្លាំងណាស់ សម្រាប់អ្នករាល់គ្នា។ ចូរកត់ត្រាសំណួរទាំងអស់ទុកក្នុងសៀវភៅសរសេរអ្នករាល់គ្នា រួចបន្តការសិក្សារបស់អ្នករាល់គ្នាបន្តទៀត។ យើងនឹងមិនចំណាយពេលច្រើន នៅក្នុងជំពូកនេះទេ ប៉ុន្តែ យើងសូមឱ្យអ្នករាល់គ្នាយកចិត្តទុកដាក់ចំពោះព័ត៌មានលម្អិតមួយចំនួន ដែលគួរឱ្យចាប់អារម្មណ៍។


©2013 CrossConnect Ministries

លំហាត់៖

១. លោកុប្បត្តិ ៥:១ រំឭកប្រាប់យើងថា៖ ...

ក. ព្រះជាម្ចាស់បានបង្កើតមនុស្សឱ្យចំ ______________________________________________។
សូមអាន លោកុប្បត្តិ ១:២៧ សារជាថ្មី។

ខ. ព្រះជាម្ចាស់បង្កើតគេមកជា ___________________ ជា ________________________។

គ. ហើយទ្រង់ _______________________________________________ (លោកុប្បត្តិ ១:២៨)។

ឃ. ពេលទ្រង់បង្កើតពួកគេមក ទ្រង់ហៅគេថា "____________________________________"។

២. លោកុប្បត្តិ ៥:៣ បង្ហាញអំពីរឿងមួយដែលខុសពីអ្វីដែល ខទី១ បានប្រាប់ដល់យើង។

ក. តើខគម្ពីរនេះនិយាយអំពីកូនរបស់អ័ដាម ថាដូចម្ដេចខ្លះ? ________________________________

ខ. តើភាពដូចគ្នា ឬរូបភាព កូនចៅរបស់អ័ដាម ខុសគ្នាពីលក្ខណៈដែលព្រះជាម្ចាស់បានបង្កើតអ័ដាមមក និង លក្ខណៈដែលទ្រង់ចង់កំណត់ឱ្យមនុស្ស យ៉ាងដូចម្ដេច? ________________________________

____________________________________________________________________

សូមអាន លោកុប្បត្តិ ១:២៦-២៧ ផង។

គ. រូបភាពរបស់មនុស្ស លែងស្ដែងឱ្យឃើញពីរូបអង្គដ៏គ្រប់លក្ខណ៍របស់ព្រះជាម្ចាស់ទៀតហើយ។ អំពើបាបបានបង្ខូចរូបអង្គរបស់ព្រះ ដែលនឹងមានក្នុងតំណមនុស្សជំនាន់ក្រោយ អស់ទៅហើយ។

៣. ចូរចំណាយពេលសរសេរឈ្មោះ ដែលមានចែងក្នុងជំពូកនេះ ចាប់តាំងពីអ័ដាម រហូតដល់លោកណូអេ ទៅតាមលំដាប់កំណើតរបស់ពួកគាត់ ព្រមទាំងចំនួនឆ្នាំនៃអាយុដែលពួកលោកបានរស់នៅ ដូចដែលបានកត់ត្រាទុកផង។

| ឈ្មោះ | អាយុកាល | ឈ្មោះ | អាយុកាល |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

៤. តើអ្វីទៅជាសេចក្ដីពិតដ៏គួរឱ្យចាប់អារម្មណ៍ ដែលអ្នកបានដឹងអំពីហេណុក ក្នុងខទី២១-២៤? ____________

____________________________________________________________________

*ចំណាំ៖* សម្រាប់ព័ត៌មានបន្ថែមអំពីហេណុក សូមអាន ហេព្រើរ ១១:៥-៦។ លោកក៏ត្រូវបានគេរាប់ថាជាមនុស្សដែលព្រះជាម្ចាស់សព្វព្រះទ័យដែរ។ តើខទី៦ប្រាប់ថា យើងត្រូវការអ្វីខ្លះ ដើម្បីផ្គាប់ព្រះទ័យទ្រង់? ________

____________________________________________________________________

សេចក្ដីជំនឿជឿថា ព្រះជាម្ចាស់មានព្រះជន្មគង់នៅ ហើយអស់អ្នកណា "ដែលស្វែងរកទ្រង់អស់ពីចិត្ត" នោះទ្រង់នឹងប្រទានរង្វាន់ដល់គេ ដោយសម្ដែងអង្គទ្រង់ដល់គេ!

៥. តើអ្នកណាដែលរស់បានអាយុវែងជាងគេ? ______________________ តើអ្នកធ្លាប់ឮអំពីឈ្មោះនេះទេ?

៦. តើឡាមេកបាននិយាយអ្វីខ្លះអំពីកូនប្រុសគាត់ឈ្មោះណូអេ ក្នុងលោកុប្បត្តិ ៥:២៩? ________________

____________________________________________________________________


©2013 CrossConnect Ministries

៧. តើព្រះជាម្ចាស់ជាអ្នកដាក់បណ្តាសាដី ឬដីត្រូវបណ្តាសាដោយសារតែអំពើបាប? សូមរំឮក ព្រះគម្ពីរលោកុប្បត្តិ ៣:១៧-១៩ ____________________

៨. តើកូនប្រុសទាំង៣របស់លោកណូអេ ដែលមានចែងក្នុង លោកុប្បត្តិ ៥:៣២ មានឈ្មោះអ្វីខ្លះ?

ក. ____________________

ខ. ____________________

គ. ____________________

ការអនុវត្ត៖ ចូរនឹកគិតអំពីពង្សាវតារបស់អ្នករាល់គ្នាផ្ទាល់។ ចូរគូរតារាងពង្សាវតានៃគ្រួសាររបស់អ្នក ដោយប្រមូលព័ត៌មានពីឪពុកម្តាយ ជីដូនជីតា មិត្តភ័ក្តិ និងញាតិសណ្តានដទៃទៀត។ តារាងពង្សាវតានៃគ្រួសាររបស់អ្នក អាចនឹងពិបាកគូរ ដោយសារតែស្ថានភាពជីវិត មរណភាព និងការទទួលជាកូនចិញ្ចឹមជាដើម។ ចូរគូរតារាងនេះ និងបន្ថែមឈ្មោះអស់អ្នកណាដែលសំខាន់សម្រាប់ជីវិតអ្នក អ្នកណាដែលអ្នកស្រឡាញ់ពេញចិត្ត អ្នកណាដែលបានជួយគាំទ្រ និងលើកទឹកចិត្តអ្នក អ្នកណាដែលបានបង្រៀន ហើយផ្គត់ផ្គង់ការរស់នៅ និងការសិក្សារបស់អ្នក និងសម្ពន្ធភាពនានាដែលបានធ្វើឱ្យអ្នកបានក្លាយជាមនុស្ស ក្នុងជីវិតបច្ចុប្បន្ននេះ។

ការអធិស្ឋាន៖ ឱព្រះដ៏ជាព្រះអម្ចាស់អើយ! ទូលបង្គំសូមអរព្រះគុណចំពោះជីវិតអស់អ្នកដែលបានកើតមកមុនទូលបង្គំ អស់អ្នកដែលទូលបង្គំបានអានពីឈ្មោះរបស់គេ នៅក្នុងលោកុប្បត្តិ ជំពូក៥ ព្រមទាំងបុព្វបុរសរបស់ទូលបង្គំផ្ទាល់ដែរ។ អរព្រះគុណដែលទ្រង់បានប្រទានពរដល់ពួកគាត់ ដូចដែលទ្រង់ប្រទានពរដល់ទូលបង្គំ អរព្រះគុណដែលទ្រង់បានបង្កើតពួកគាត់ម្នាក់ៗ ដោយសេចក្តីស្រឡាញ់។ ទូលបង្គំក៏ដូចជាពួកគាត់ដែរ ទូលបង្គំនឹងមានកូនចៅដែលកើតមកក្រោយទូលបង្គំ។ សូមប្រទានឱ្យទូលបង្គំអាចធ្វើជាគំរូដល់ពួកគេ គឺជាស្នូរបន្ទាល់អំពីសេចក្តីស្រឡាញ់របស់ទ្រង់ នៅក្នុងជីវិតរបស់ទូលបង្គំ តាមរយៈព្រះគ្រីស្ទយេស៊ូវ។ ____________________

____________________

# មេរៀនទី៨

# អញនឹងមិន...!

## លោកុប្បត្តិ ៦-៩:១៧ ដំណើររឿងលោកណូអេ និងទឹកជំនន់

## និដ្ឋភាពទូទៅនៃមេរៀនទី៨

### មាតិកា

### លំនាំដើម

### មេរៀនទី៨៖ លោកុប្បត្តិ ៦-៩:១៧

- សណ្ឋាននៃរបស់សព្វសារពើ និងការសម្រេចព្រះទ័យរបស់ព្រះ
- លោកណូអេ និងទូកធំ
- ទឹកភ្លៀងបានបង្អុរចុះ
- ព្រះជាម្ចាស់នឹកចាំអំពីលោកណូអេ
- ការបញ្ចេញសត្វដែលនៅក្នុងទូកធំ
- និយមន័យ៖ *សេចក្ដីសប្បុរស*
- ព្រះពរមកពីព្រះជាម្ចាស់
- និយមន័យ៖ *ធ្ងន (លោះ)* និង *រាប់ជាសុចរិត*
- តម្លៃនៃឈាម
- បង្កើតមកតាមរូបអង្គទ្រង់
- និយមន័យ៖ *សេចក្ដីសញ្ញា (សម្ពន្ធមេត្រី)*


©2013 CROSSCONNECT MINISTRIES

# លំនាំដើម

ដំណើររឿងរបស់លោកណូអេ និងទឹកជំនន់ បានចាប់ផ្តើមដោយរៀបរាប់ថា "ព្រះយេហូវ៉ាទ្រង់ស្តាយ ...... ទ្រង់មានព្រះហឫទ័យព្រួយ"។ គ្រប់យ៉ាងទាំងអស់ដែលទ្រង់បានបង្កើត ពេលនេះពោរពេញដោយសេចក្តីអាក្រក់ ភាពជួរជាតិ សេចក្តីពុករលួយ និងអំពើហិង្សា។ ការសម្រេចព្រះទ័យរបស់ទ្រង់នៅក្នុងពេលនោះ គឺបំផ្លាញអ្វីៗដែលទ្រង់បានបង្កើតមក គឺទាំងមនុស្ស ទាំងសត្វ និងជីវិតទាំងអស់ដែលមាននៅលើផែនដីចោលទាំងអស់ រួចចាប់ផ្តើមសារជាថ្មីវិញ។ ដំណើររឿងអំពីមហន្តរាយ និងមរណភាពនេះ ត្រូវបានកត់ទុកក្នុងគម្ពីរ លោកុប្បត្តិ ៦-៩ ប៉ុន្តែ រឿងនេះនៅតែផ្តល់នូវសេចក្តីសង្ឃឹម ដោយសារតែបុរសម្នាក់ឈ្មោះ ណូអេ ។ គម្ពីរបានប្រាប់យើងថា លោកណូអេ "គ្រប់លក្ខណ៍នៅចំពោះព្រះនេត្រព្រះជាម្ចាស់" គាត់ជាមនុស្សសុចរិត ហើយ "ដើរជាមួយនឹងព្រះ"។

ទឹកជំនន់បានគ្របដណ្តប់ផែនដីទាំងមូល ហើយបានញែកព្រះជាម្ចាស់ចេញពីការអាក្រក់គ្រប់យ៉ាងទាំងអស់ ប៉ុន្តែព្រះជាម្ចាស់បានទុកជីវិតលោកណូអេ និងក្រុមគ្រួសាររបស់គាត់នៅក្នុងទូកធំជាជម្រក ជាមួយសត្វគ្រប់ប្រភេទមួយគូៗ។ ព្រះនឹងប្រទានសេចក្តីបង្គាប់ដល់ជីវិតទាំងអស់ដែលទ្រង់បានរក្សាទុក ឱ្យបង្កើតកូនចៅពាសពេញផែនដីជាថ្មីម្តងទៀត។ ព្រះជាម្ចាស់បានសន្យាជាមួយលោកណូអេ និងគ្រួសាររបស់លោកថា ទ្រង់នឹងទុកជីវិតពួកគេ ចំណែកឯលោកណូអេវិញ គាត់ក៏ស្តាប់តាមគ្រប់ការទាំងអស់ដែលព្រះជាម្ចាស់បានបង្គាប់ដល់លោក។

ទឹកភ្លៀងដែលជន់ពន្លិចផែនដីនេះហើយដែលបានធ្វើឱ្យទូកធំអណ្តែតឡើងខ្ពស់ជាងកំពូលភ្នំទាំងអស់។ គ្រប់របស់មានជីវិត ដែលមិននៅក្នុងទូកធំ ស្លាប់ទាំងអស់។ ជាច្រើនខែកន្លងផុតទៅ ព្រះគម្ពីរប្រាប់យើងថា ព្រះជាម្ចាស់នឹកចាំអំពីលោកណូអេ និងអស់អ្នកដែលនៅជាមួយនឹងលោក។ ទីបំផុត ខ្យល់ក៏ចាប់ផ្តើមបក់ផាត់ចុះឡើង ទឹកក៏ស្រកចុះ ភ្លៀងក៏រាំង ហើយទូកធំក៏កឿងលើកន្លែងដែលមានដីស្ងួត។

ក្រោយមក ព្រះជាម្ចាស់ក៏បានហៅលោកណូអេ ព្រមទាំងអ្វីៗទាំងអស់ដែលនៅជាមួយលោក ឱ្យចេញពីទូកធំ។ ជីវិតសត្វទាំងអស់ដែលនៅជាមួយនឹងលោក ក៏ត្រូវបានបញ្ចេញពីទូកធំនេះដែរ។ លោកណូអេ ក៏បានសង់ទីអាសនាមួយ រួចថ្វាយបង្គំព្រះជាម្ចាស់ ព្រះជាម្ចាស់ក៏បានប្រទានសេចក្តីសន្យាដល់លោកណូអេថា "អញនឹងមិនដាក់បណ្តាសាដី ដោយព្រោះមនុស្សទៀតទេ... អញក៏មិនធ្វើទោសដល់ជីវិតទាំងឡាយ ដូចជាអញទើបនឹងធ្វើនោះទៀតដែរ"។ ដោយសារតែសេចក្តីសន្យានេះ ព្រះជាម្ចាស់បានប្រព្រឹត្តដោយសេចក្តីសប្បុរស ដ្បិតព្រះអង្គជ្រាបថា "គំនិតក្នុងចិត្តរបស់មនុស្ស នោះអាក្រក់តាំងតែពីក្មេងមក" ប៉ុន្តែ ទ្រង់បានសន្យាថា ទ្រង់នឹងមិនបំផ្លាញជីវិតទាំងឡាយ ដូចដែលទ្រង់ទើបនឹងធ្វើនេះដែរ។

នៅក្នុងដំណើររឿងនេះ យើងដឹងពីតម្លៃដែលព្រះជាម្ចាស់បានដាក់នៅក្នុងជីវិតមនុស្ស ដ្បិតទ្រង់ត្រាស់ហៅយើងឱ្យទទួលខុសត្រូវចំពោះជីវិតមនុស្សដូចគ្នា។ យើងនឹងបញ្ចប់ត្រឹមការដឹងថា ព្រះជាម្ចាស់បានសន្យា ទ្រង់នឹងប្រព្រឹត្តចំពោះយើងរាល់គ្នាដោយព្រះគុណ ហើយថា ទ្រង់នឹងចងចាំ និងមិនបំភ្លេចព្រះបន្ទូលសន្យាអំពីសម្ពន្ធមេត្រីដ៏អស់កល្ប ដែលទ្រង់បានធ្វើជាមួយនឹងលោកណូអេ នោះឡើយ។

សូមឱ្យសេចក្តីស្រឡាញ់ដែលអ្នករាល់គ្នាមានចំពោះព្រះវរបិតានៅស្ថានសួគ៌ ដែលត្រាស់ហៅអ្នករាល់គ្នាមកក្នុងសេចក្តីសុចរិត ភាពបរិសុទ្ធ និងឱ្យមកដើរជាមួយនឹងទ្រង់ បានចម្រើនឡើង ពេលដែលអ្នករាល់គ្នាចូលរួមក្នុងការសិក្សាមេរៀន "អញនឹងមិន...!" នេះ។ ចូរចាំជានិច្ចថា ទ្រង់សន្យានឹងបញ្ជោកអ្នករាល់គ្នាដោយព្រះគុណ ដ្បិតទ្រង់នៅចងចាំអំពីសម្ពន្ធមេត្រីដ៏អស់កល្បជានិច្ចរបស់ទ្រង់។


©2013 CrossConnect Ministries

## ផ្នែកទី១

សេចក្តីផ្តើម៖ ចូរចាំថា សង្គ្រាមរវាងព្រះជាម្ចាស់ និងមារសាតាំង រាលដាលដល់ព្រលឹងមនុស្សគ្រប់រូប។ សេចក្តីប្រាថ្នាដែលពោរពេញដោយសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ គឺចង់ផ្សះផ្សារសម្ពន្ធភាពជាមួយរបស់ទាំងអស់ដែលទ្រង់បានបង្កើត ដ្បិតពេលនេះ សម្ពន្ធភាពនោះត្រូវបំផ្លិចបំផ្លាញដោយសារតែអំពើបាប។

*ចំណាំ៖ លោកុប្បត្តិ ជំពូកទី៦ ទី៧ និងទី៨ កត់ត្រាពីរឿងទឹកជំនន់។ ជំពូកទី៦ ចាប់ផ្តើមដោយខគម្ពីរដែលពិបាកយល់ចំនួន៤។ អ្នករាល់គ្នាអាចនឹងសួរសំណួរលំបាកៗមួយចំនួន ឧទាហរណ៍ថា តើមនុស្សទាំងនេះមកពីណា? តើអ្នកណារៀបការជាមួយអ្នកណា? ការសិក្សានេះ គ្មានចេតនាផ្តល់ចម្លើយចំពោះសំណួរទាំងអស់នេះទេ គឺចង់ឱ្យអ្នករាល់គ្នាដឹងពីដំណើររឿងដែលផ្តល់ចំណេះដឹងអំពីសេចក្តីស្រឡាញ់ដែលព្រះជាម្ចាស់មាន ចំពោះរបស់គ្រប់យ៉ាងដែលទ្រង់បានបង្កើតមក ដោយទទួលស្គាល់កង្វះខាតនៃការពន្យល់ និងការប្រាថ្នាចង់បានភាពច្បាស់លាស់។*

ចូរយើងរាល់គ្នាចាប់ផ្តើមការសិក្សាអំពីទឹកជំនន់ដែលមានកត់ត្រាក្នុង លោកុប្បត្តិ ៦:៥-៨:២២។

គេហកិច្ច៖ ចូរអាន លោកុប្បត្តិ ៦:៥-៧, ១១-១២

លំហាត់៖

១. ក្នុងជំពូកទី៦ ខទី៥ គូសបង្ហាញនូវរូបភាពមួយដ៏គួរឱ្យខ្លាច។ តើព្រះជាម្ចាស់មើលឃើញអ្វីខ្លះ? ចូរសរសេរនូវអ្វីដែលមានចែងក្នុងខគម្ពីរនេះ៖ ____________________________________________

____________________________________________________________

២. ខគម្ពីរនេះប្រើសម្តីបីម៉ាត់មករៀបរាប់ប្រាប់ពីកម្រិតនៃអំពើអាក្រក់របស់មនុស្ស (លោកុប្បត្តិ ៥ខ)៖
"... ____________________ គំនិតក្នុងចិត្តគេ សុទ្ធតែអាក្រក់ ____________________ ដូច្នោះ"។

៣. អំពើបាបបានធ្វើឱ្យរបស់សព្វសារពើទៅជាកខ្វក់ ហើយថែមទាំងបានជ្រាបចូលក្នុងចិត្ត និងគំនិតរបស់មនុស្សទាំងអស់។ ពេលនេះមនុស្សមានទំនោរទៅរកការអាក្រក់ ច្រើនជាងការល្អ ដ្បិតអំពើបាបបានជ្រាបចូលក្នុងគ្រប់ទាំងការប្រព្រឹត្តរបស់គេ សូម្បីតែការល្អរបស់គេក៏ពោរពេញដោយការអាក្រក់ដែរ ដ្បិតពួកគេខ្វះសម្ពន្ធភាពជាមួយនឹងព្រះជាម្ចាស់។ គម្ពីរហេព្រើរ ១១:៦ ចែងថា "តែបើឥតមាន________________ នោះ__________ នឹង______________________ ព្រះបានឡើយ ដ្បិត____________ដែល____________ឯព្រះ នោះត្រូវតែ______________________មែន ហើយថា ទ្រង់ប្រទានរង្វាន់ ដល់អស់អ្នកដែល__________ ទ្រង់។ អំពើអាក្រក់របស់គេកាន់តែចម្រើនឡើង នៅក្នុងសណ្ឋានបាបរបស់គេ (លោកុប្បត្តិ ៦:៥)។

៤. យោងតាមបទគម្ពីរ ១១:៦ តើអ្វីជាវត្ថុដ៏សំខាន់ចំពោះសម្ពន្ធភាពជាមួយព្រះជាម្ចាស់?

ក. ____________________________________________________________

ខ. ____________________________________________________________

គ. ____________________________________________________________

៥. ចូរត្រឡប់ទៅអាន លោកុប្បត្តិ ៦:១១-១២។ តើនៅក្នុងខទី១១ គេប្រើពាក្យពេចន៍អ្វីរៀបរាប់ពីសម័យនោះ?

ក. ____________________________________________ ហើយក៏

ខ. ____________________________________________


©2013 CrossConnect Ministries

សំណួរ៖

១. តើខទី៦ ប្រាប់យើងរាល់គ្នាអំពីព្រះជាម្ចាស់ ដូចម្ដេចខ្លះ? ______________________________

______________________________________________

២. តើខទី៧ ប្រាប់យើងថា ព្រះជាម្ចាស់សម្រេចព្រះទ័យធ្វើអ្វីខ្លះ? ____________________________

______________________________________________

៣. តើព្រះជាម្ចាស់បានប្រទានអ្វីទៅឱ្យមនុស្ស (លោកុប្បត្តិ ២:៧) ដែលទ្រង់បម្រុងនឹងបំផ្លាញចោល? _______

______________________________________________

ការសញ្ជឹងគិត៖ ព្រះជាម្ចាស់បានសម្រេចព្រះទ័យថា ទ្រង់នឹងបំផ្លាញគ្រប់យ៉ាងដែលមានដង្ហើមជីវិត។ ចូរស្រមៃមើលថា តើការអាក្រក់ឈានទៅដល់កម្រិតណាទៅ បានជាទ្រង់សម្រេចព្រះទ័យបំផ្លាញជីវិតទាំងអស់ សូម្បីតែសត្វហើរលើអាកាសក៏ទ្រង់មិនលើកលែងដែរនោះ? ចូរធ្វើការសង្កេត នៅពេលដែលអ្នករាល់គ្នាព្យាយាមយល់អំពីព្រះហឫទ័យនៃព្រះ កាន់តែច្បាស់។

១. តើនេះជាការបង្ហាញពីកំហឹង ឬជាការផ្ទុះចេញជាសេចក្ដីក្រោធរបស់ទ្រង់? ____________________

______________________________________________

២. តើការបណ្ដោយឱ្យវត្ថុដ៏មានតម្លៃបំផុតរបស់អ្នក ជាវត្ថុដែលស្ដែងឱ្យឃើញពីសណ្ឋានរបស់អ្នក ទៅជាវត្ថុដែលបង្ហាញពីសណ្ឋានមួយខុសស្រឡះទៅវិញនោះ មានលក្ខណៈដូចម្ដេច? ____________________

______________________________________________

៣. ការងារបង្កើតសព្វសារពើ របស់ព្រះជាម្ចាស់ នៅតែបន្តជានិច្ច ក្មេងៗនៅតែបន្តកើត រុក្ខជាតិនៅតែបន្តដុះ ឯសត្វក៏នៅតែបន្តពូជដែរ។ ប្រសិនបើទ្រង់មិនធ្វើដូច្នោះទេ តើនឹងមានរឿងអ្វីកើតឡើង? ការអាក្រក់កាន់តែរាលដាលបន្តទៀតមែនទេ? តើរបស់សព្វសារពើដែលព្រះបានបង្កើតមក នឹងបាត់បង់ទៅវិញហួតមែនទេ? __________

______________________________________________

៤. ប្រសិនបើមនុស្សសម្រេចចិត្តធ្វើតែអំពើអាក្រក់ នោះការអាក្រក់នឹងរាលដាលរហូត។ ព្រះជាម្ចាស់បង្កើតមនុស្សមក ដើម្បីឱ្យគេស្ដែងពីរូបអង្គ និងសេចក្ដីសប្បុរសរបស់ទ្រង់ មិនមែនឱ្យគេរួមកម្លាំងគ្នាបម្រើសាតាំងនោះទេ។ ទ្រង់ចង់ឱ្យគេយកជីវិតមកផ្ដោតលើព្រះបន្ទូល និងអង្គទ្រង់ផ្ទាល់ ទ្រង់ចង់ឱ្យគេរស់នៅក្នុងការទំនាក់ទំនងជាមួយទ្រង់ដោយសេចក្ដីស្រឡាញ់។ តើអ្វីខ្លះដែលបានមកជំនួសព្រះជាម្ចាស់ នៅក្នុងចិត្តរបស់គេ ហើយបានក្លាយជាវត្ថុដែលគេយកចិត្តទុកដាក់ខ្លាំង? ______________________________

សំណួរអនុវត្ត៖

១. ត្រូវចាំថា ព្រះជាម្ចាស់ ទ្រង់ជាព្រះនៃសម្ពន្ធភាព ទ្រង់ប្រាថ្នាចង់រស់ក្នុងសម្ពន្ធភាពនៃសេចក្ដីស្រឡាញ់ជាមួយនឹងរបស់សព្វសារពើដែលទ្រង់បានបង្កើតមក។ តើសម្ពន្ធភាពដែលអ្នករាល់គ្នាមានជាមួយនឹងព្រះជាម្ចាស់ គឺជាអ្វី? តើអ្នករាល់គ្នាគិតយ៉ាងណាចំពោះគំនិតក្នុងចិត្តរបស់អ្នកផ្ទាល់? ចូរសញ្ជឹងគិត ហើយកត់ត្រាគំនិតមួយចំនួនរបស់អ្នករាល់គ្នា៖ ______________________________

______________________________________________

______________________________________________


©2013 CrossConnect Ministries

## ផ្នែកទី២

**សេចក្ដីផ្ដើម៖** តាំងពីអ័ដាម និងអេវ៉ាបានធ្លាក់ចុះក្នុងអំពើបាប ប្រវត្តិសាស្ត្ររបស់មនុស្សក៏ធ្លាក់ចុះដុនដាបកាន់តែខ្លាំង។ ដំបូងឡើយ ព្រះគម្ពីរប្រាប់យើងអំពីរឿងកាអ៊ីនសម្លាប់អេបិល ហើយពេលនេះយើងដឹងថា លោកិយក៏ធ្លាក់ក្នុងសណ្ឋានអាក្រក់កាន់តែខ្លាំង រហូតដល់ព្រះជាម្ចាស់ដែលបានបង្កើតផ្ទៃមេឃ និងផែនដី ទ្រង់ប្រុង "លុបបំបាត់មនុស្សឱ្យបាត់សូន្យពីផែនដី"។ ស្ថានភាពភាពនៃរបស់សព្វសារពើនៅពេលនេះ ដូចជាគ្មានសង្ឃឹមទេ ប៉ុន្តែនៅក្នុងខទី៨ មានពន្លឺនៃសេចក្ដីសង្ឃឹមតូចមួយ...

**គេហកិច្ច៖** ចូរអាន លោកុប្បត្តិ ៦:៨-៧:៥

**លំហាត់៖**

១. ខទី៨ បង្ហាញពីពាក្យ "សេចក្ដសង្ឃឹម" តាមរយៈមនុស្សម្នាក់ឈ្មោះថា ________________________។

២. តើគេប្រើពាក្យអ្វីខ្លះមករៀបរាប់ពីគាត់ (ខទី៩)? សូមអានលោកុប្បត្តិ ៧:១។

ក. ________________________________________

ខ. ________________________________________

គ. ________________________________________

ឃ. ________________________________________

៣. លោកណូអេ មានកូនប្រុសពនាក់ (ខទី១០)៖ ____________________ ____________________ និង ____________________ ។

៤. ព្រះជាម្ចាស់ប្រាប់ពីផែនការរបស់ទ្រង់ ដល់លោកណូអេ។ តើនៅក្នុងខទី១៣ និងទី១៧ ទ្រង់មានបន្ទូលប្រាប់គាត់ដូចម្ដេចខ្លះ? ________________________________________

________________________________________

៥. ទោះជាផែនដីនេះមានពេញដោយអំពើហិង្សា និងសេចក្ដីពុករលួយ ហើយទោះជាទ្រង់បម្រុងនឹងបំផ្លាញជីវិតទាំងអស់ក៏ដោយ ប៉ុន្តែ ទ្រង់នៅតែបង្ហាញសេចក្ដីស្រឡាញ់យ៉ាងធំធេងដល់លោកណូអេ និងគ្រួសាររបស់លោក។ តើព្រះជាម្ចាស់ទ្រង់បង្គាប់លោកណូអេ ឱ្យធ្វើអ្វី (ខទី១៤)? ________________________________________

________________________________________

៦. តើព្រះជាម្ចាស់ឱ្យដំបូន្មានដល់លោកណូអេយ៉ាងណាខ្លះ អំពីការសង់ទូកធំ (ខទី១៤-១៦)? ____________________

________________________________________

៧. ពេលដែលទូកធំសង់រួច តើលោកណូអេ ត្រូវធ្វើអ្វីទៀត (ខទី១៩-២១)? ____________________

________________________________________

៨. ដូច្នេះ លោកណូអេក៏បានសង់ទូកធំ ហើយព្រះជាម្ចាស់ក៏បានបង្គាប់ឱ្យសត្វគ្រប់ប្រភេទចូលក្នុងទូក (លោកុប្បត្តិ ៧:១-៣)។ ទ្រង់មានបន្ទូលប្រាប់លោកណូអេថា ភ្លៀងនឹងចាប់ផ្ដើមបង្អុរ ______ ថ្ងៃ ______ យប់ (ខទី៤)។ ហើយទ្រង់ក៏បន្ថែមទៀតថា "ហើយអញនឹង ________________________________________

________________________________________"។


©2013 CROSSCONNECT MINISTRIES

៩. តើព្រះគម្ពីរប្រាប់យើងអំពីសេចក្តីជំនឿរបស់លោកណូអេ ថាដូចម្តេចខ្លះ នៅក្នុងលោកុប្បត្តិ ៦:២២ និង ៧:៥?

____________________________________________________________

**លំហាត់៖** មនុស្សដែលរស់នៅលើផែនដី និងបុរសម្នាក់ឈ្មោះណូអេ ពិតជាផ្ទុយពីគ្នាស្រឡះ។ ចូររំឭក លោកុប្បត្តិ ៦:៥ ដល់ ៧:៥។ តើមានពាក្យពេចន៍អ្វីខ្លះដែលគេប្រើមករៀបរាប់ពីលោកណូអេ និងមនុស្សលើផែនដី?

| លោកណូអេ | មនុស្សលើផែនដី |
|---|---|
| | |
| | |
| | |
| | |

**ការអនុវត្ត៖**

១. ក្នុងអំឡុងពេលដែលលោកណូអេកំពុងធ្វើទូកធំ តើគ្រួសាររបស់លោក រស់ក្នុងសភាពបែបណា? __________

____________________________________________________________

២. តើអ្នករាល់គ្នាធ្លាប់ត្រូវគេចំអក ឬលែបខាយ ដោយព្រោះអ្នករាល់គ្នាតាំងជំហរលើអ្វីដែលអ្នករាល់គ្នាជឿដែរឬទេ? ________________________________________________

៣. តើអ្នកដទៃមានប្រតិកម្មយ៉ាងណាខ្លះ? តើអ្នកមានគំនិតដូចម្តេច បានជាអ្នកសម្រេចចិត្តធ្វើអ្វីដែលគេមិនចូលចិត្តដូច្នេះ? ________________________________________________

**ជីកឱ្យកាន់តែជ្រៅ៖** គ្មានអ្វីឱ្យសង្ស័យទេ លោកណូអេ បានសង់ទូកដ៏ធំមហិមានេះនៅលើដីស្ងួតហែង ដូចមនុស្សឆ្កួត ហើយប្រាប់គេថា ទឹកជំនន់ដ៏ធំនឹងជន់ឡើង ឱ្យពួកគេអន្តរាយ។ ថ្វីបើលោកមើលទៅហាក់ដូចជាមនុស្សឆ្កួត ចំពោះអស់អ្នកដែល "មានគំនិតក្នុងចិត្ត សុទ្ធតែអាក្រក់តាំងតែពីក្មេង" ក៏ពិតមែន តើព្រះគម្ពីរហេព្រើរ ១១:៧-៨ ប្រាប់យើងរាល់គ្នាអំពីគាត់យ៉ាងណាខ្លះ?

- ដោយសារ __________ នោះ ____________ ពន្យល់លោកណូអេ ពីការដែលមើលមិនទាន់ __________ ហើយដោយលោកមាន ____________ បានជាលោកធ្វើ ________ សម្រាប់នឹង _________ ដល់ពួកគ្រួសាររបស់លោក ហើយលោកបាន ____________ ដោយ _______ ក៏ត្រឡប់ជា _______________ ដែលត្រូវខាង _____________ ទុកជា _______ ដែរ។"

លោកណូអេ គឺជាមនុស្សដែលមានជំនឿពិត ព្រះជាម្ចាស់បានប្រាប់គាត់អំពី "ការដែលមិនទាន់ឃើញនៅឡើយ"។ ទោះបីជាការនោះហាក់ដូចជារកជឿមិនបាន ហើយត្រូវជឿដោយជំនឿក៏ដោយ ប៉ុន្តែ លោកណូអេ គាត់បានជឿដល់ព្រះ ព្រមទាំងស្តាប់តាមផង។ ខ្ញុំសូមលើកទឹកចិត្តយើងរាល់គ្នាឱ្យក្លាយជាមនុស្សដែលមានជំនឿពិត ដោយប្រព្រឹត្តនូវអ្វីដែលព្រះមានបន្ទូលប្រាប់ ហើយឆ្លើយតបទៅកាន់ទ្រង់វិញ ដោយស្តាប់តាមអ្វីដែលទ្រង់បង្គាប់ដល់យើងរាល់គ្នាដែរ។

ការអធិស្ឋាន៖ ឱព្រះដ៏ជាព្រះអម្ចាស់អើយ! ទ្រង់ព្រួយព្រះទ័យដោយសារតែស្ថានភាពនៃមនុស្សដែលទ្រង់បានបង្កើតមក។ ពួកគេសម្រេចចិត្តជ្រើសយកការប្រព្រឹត្តដោយប្រមាថដល់ព្រះអង្គ ប៉ុន្តែ ទ្រង់សព្វព្រះទ័យនឹងលោកណូអេ ដ្បិតលោកជឿថា ទ្រង់មានព្រះជន្មគង់នៅ ហើយជឿថា ព្រះបន្ទូលទ្រង់គឺជាសេចក្តីពិត។ សូមប្រទានឱ្យទូលបង្គំមានសេចក្តីជឿលើព្រះបន្ទូលទ្រង់ ទុកចិត្តទ្រង់ ហើយមានបំណងចិត្តឆ្លើយតបទៅទ្រង់វិញ ដោយការស្តាប់បង្គាប់។ ___________

___________________________________________

___________________________________________

ផ្នែកទី៣

គោលគំនិត៖ សត្វគ្រប់ប្រភេទបានចូលក្នុងទូកអស់ហើយ ព្រះជាម្ចាស់ក៏បានបិទទ្វារទូកហើយដែរ បន្ទាប់មកក៏មានភ្លៀងអស់រយៈពេល ______ ថ្ងៃ ______ យប់ (លោកុប្បត្តិ ៧:១៧) ដូចដែលព្រះបានមានបន្ទូលប្រាប់លោកណូអេពីមុនមក (លោកុប្បត្តិ ៧:៤)។ ចូរយើងមើលអំពីការរៀបរាប់ដំណើររឿងនេះវិញ។ សូមអាន លោកុប្បត្តិ ៧។

លំហាត់៖

១. យោងតាមខទី៧ និងទី១៣ តើអ្នកណាខ្លះដែលបានចូលទៅក្នុងទូក៖ ___________________________________________

២. តើមានសត្វអ្វីខ្លះដែលបានចូលទៅក្នុងទូកនោះដែរ? សូមអានខទី៨-៩, ១៤-១៥។ ___________________________________________

៣. តើអ្នកណាជាអ្នកបិទទ្វារ នៅពេលដែលគ្រប់គ្នាបានចូលក្នុងទូកអស់ (ខទី១៦)? ___________

៤. តើមានពាក្យពេចន៍អ្វីខ្លះ ដែលគេប្រើសម្រាប់រៀបរាប់អំពីទឹកជំនន់នេះ (ខទី១១-១២, ១៧-២០)? ___________________________________________

៥. តើមានអ្វីខ្លះដែលត្រូវបំផ្លាញ?
   ក. ខទី២១៖ គ្រប់ទាំងសាច់...___________
   ខ. ខទី២២៖ គ្រប់ទាំងអស់...___________
   គ. ខទី២៣៖ គ្រប់ទាំងជីវិត...___________

៦. តើទឹកជំនន់នេះគ្របដណ្តប់ផែនដីយូរប៉ុណ្ណា (ខទី២៤)? ___________

ការសញ្ជឹងគិត៖ យើងពិបាកស្រមៃណាស់ថា លោកណូអេ និងគ្រួសាររបស់លោកំពុងគិតអ្វីខ្លះ ក្នុងអំឡុងពេលមានទឹកជំនន់ និងការបំផ្លាញផែនដីនោះ។ សេចក្តីស្លាប់ ជាការជំនុំជម្រះរបស់ព្រះ មកលើមនុស្សដែលគ្មានសម្ពន្ធភាពជាមួយទ្រង់ និងមនុស្សដែលជ្រើសយកផ្លូវជីវិតហិង្សា និងសេចក្តីពុករលួយ។ លោកណូអេ ដឹងថា អ្នកជិតខាងគាត់ អ្នករកស៊ីជាមួយគាត់ ញាតិសន្តានគាត់ និងមិត្តភ័ក្តិគាត់ ដែលធ្លាប់ទាក់ទងគ្នារាល់ថ្ងៃ សុទ្ធវិនាសអស់ហើយ។ យើងបានត្រឹមតែស្រមៃមើលប៉ុណ្ណោះថា ភាពភ័យខ្លាចដែលកើតឡើងនៅខាងក្រៅទូកធំនេះ ឈានដល់កម្រិតណា ប៉ុន្តែ ក្នុងពេលជាមួយគ្នានោះ យើងក៏ត្រូវដឹងដែរថា ព្រះជាម្ចាស់បានប្រទាននូវសេចក្តីសុខ សុវត្ថិភាព ដល់អស់អ្នកដែលនៅក្នុងទូក។

ព្រះជាម្ចាស់មិនបានប្រាប់លោកណូអេ និងគ្រួសាររបស់លោកទេថា ពួកគេនឹងត្រូវរស់នៅក្នុងទូកធំនោះយូរប៉ុណ្ណា ពួកគេគ្រាន់តែដឹងថា ព្រះជាម្ចាស់នឹង "ធ្វើឱ្យមានជំនន់លិចផែនដី ដើម្បីសម្លាប់ជីវិតទាំងអស់ដែលនៅក្រោមមេឃ"។ មែនហើយ ពួកគេប្រាកដជាស្តាប់ឮសូរ តំណក់ទឹកភ្លៀងដែលធ្លាក់លើដំបូលទូក។ ពួកគេក៏ដឹងដែរថា ៤០ថ្ងៃ ៤០យប់

ក្រោយមក ភ្លៀងក៏រាំង ប៉ុន្តែពេលនេះ ទូកធំនេះនឹងនៅតែអណ្តែតលើទឹក ១៥០ថ្ងៃទៀត នេះហើយជាកន្លែងចាប់ផ្តើម នៅក្នុងលោកុប្បត្តិ ជំពូកទី៨។

គេហកិច្ច៖ សូមអាន លោកុប្បត្តិ ៨:១-១៩

លំហាត់៖

១. ថ្វីដ្បិតថាលោកណូអេ មិនដឹងថាគ្រួសាររបស់លោកនឹងត្រូវរស់នៅលើទូកយូរប៉ុណ្ណា ប៉ុន្តែ លោកស្គាល់ព្រះដែលបានការពារ និងផ្គត់ផ្គង់ក្រុមគ្រួសាររបស់លោក។ ចូរសរសេរពាក្យពាម៉ាត់ដំបូង ក្នុងលោកុប្បត្តិ ៨:១ ______

__________________________________________________________________

២. ព្រះជាម្ចាស់នឹកចាំអំពីលោកណូអេ និងអ្វីៗទាំងអស់ដែលនៅក្នុងទូក ទ្រង់មានព្រះទ័យទុកដាក់ចំពោះរបស់សព្វសារពើដែលទ្រង់បានបង្កើត។ ទ្រង់ក៏បានជួយឱ្យគេចេញពីទូកនោះ ប៉ុន្តែ ទ្រង់មានកិច្ចការខ្លះ ដែលត្រូវធ្វើសិន។ តើខគម្ពីរបន្តទៅទៀតនេះ ប្រាប់អ្វីខ្លះដល់យើង?

ក. ខទី១៖ ________________________________________________

ខ. ខទី២៖ ________________________________________________

គ. ខទី៣៖ ________________________________________________

ឃ. ខទី៤៖ ________________________________________________

ង. ខទី៥៖ ________________________________________________

៣. ទីបំផុត ទូកនេះក៏កឿងនៅលើកំពូលភ្នំអារ៉ារ៉ាត សូមអានខទី៦-១២។ ម្តេចបានជា លោកណូអេ ដឹងថា ទឹកស្រកហើយមានដីស្ងួត? ____________________________________________

__________________________________________________________________

៤. ច្រើនសប្តាហ៍កន្លងផុតទៅ ទើបផែនដីទាំងមូលស្ងួតអស់។ ក្រោយមកទៀត ក្នុងខទី១៥-១៦ ព្រះជាម្ចាស់បង្គាប់លោកណូអេឱ្យ ____________________________________________

៥. ពេលវេលាដែលបានកំណត់ឱ្យលោកណូអេ និងគ្រួសាររបស់លោក ព្រមទាំងសត្វទាំងអស់ត្រូវចេញពីទូក ក៏មកដល់។ វាជារឿងដ៏គួរឱ្យចាប់អារម្មណ៍ណាស់ ដ្បិតព្រះបន្ទូលនៅក្នុង លោកុប្បត្តិ ១:២៨ ត្រូវបាននិយាយទៅកាន់លោកណូអេ នៅក្នុងខទី១៧នេះ "...ដើម្បីឱ្យបានមក ____________________________"។

ការអធិស្ឋាន៖ ឱព្រះអម្ចាស់អើយ សូមអរព្រះគុណទ្រង់ដែលបាននឹកចាំពីទូលបង្គំ។ មានពេលខ្លះទូលបង្គំរមែងគិតថាមនុស្សដទៃភ្លេចទូលបង្គំហើយ ទូលបង្គំឯកោណាស់ ជីវិតទូលបង្គំហាក់ដូចជាគ្មានតម្លៃសោះ ចំពោះមនុស្សដទៃទៀត។ អរព្រះគុណដែលទ្រង់រំឭកប្រាប់ទូលបង្គំថា ទូលបង្គំជាមនុស្សមានតម្លៃចំពោះទ្រង់។ សូមឱ្យជីវិតទូលបង្គំ ស្តែងចេញនូវការអរព្រះគុណដល់ទ្រង់ រៀងរាល់ថ្ងៃ។ ________________________________________

____________________________________________________________________

____________________________________________________________________

## ផ្នែកទី៤

សេចក្តីផ្តើម៖ ហេតុនេះលោកណូអេ ក៏បានចេញពីទូកធំជាមួយមនុស្សគ្រប់គ្នាដែលនៅជាមួយលោក នៅក្នុងទូកនោះ (លោកុប្បត្តិ ៨:១៨-១៩)។ ប្រសិនបើអ្នករាល់គ្នាជាលោកណូអេវិញ ហើយអ្នករាល់គ្នាត្រូវរស់នៅក្នុងទូកនេះ រាប់ខែ


©2013 CROSSCONNECT MINISTRIES

តើអ្នករាល់គ្នាគិតថា អ្នករាល់គ្នានឹងធ្វើអ្វី មុនគេបង្អស់? ចូរស្រមៃមើល! ______________________________

______________________________________________________________

គេហកិច្ច៖ សូមអាន លោកុប្បត្តិ ៨:២០-២២

លំហាត់៖

១. ទូកនៅទេទេស្អាត តើលោកណូអេធ្វើអ្វី មុនគេ? ______________________________ (ខទី២០)។ តាមរយៈដំណើររឿងរបស់កាអ៊ីន និងអេបិល យើងដឹងថា ដង្វាយដែលគាប់ព្រះហឫទ័យព្រះ គឺជាដង្វាយដែលទាមទារឱ្យមានការបង្ហូរឈាមសត្វ។ នៅក្នុងខទី២០ យើងដឹងថា លោកណូអេ បានថ្វាយនូវដង្វាយជាសត្វស្លាប និងសត្វស្អាតដែលនៅក្នុងទូក មកធ្វើជាដង្វាយដុតថ្វាយព្រះយេហូវ៉ា។

២. ចូរកត់ចំណាំប្រតិកម្មរបស់ព្រះយេហូវ៉ា នៅក្នុងខទី២១។ ដំបូង ទ្រង់ ______________________ រួចទ្រង់សម្រេចក្នុងព្រះហឫទ័យថា "អញនឹងមិន ______________________ ដោយសារមនុស្សទៀតទេ ________________ គំនិតក្នុង ______________________ នោះ ______________ តាំងតែពី ______________________ ហើយអញក៏មិន ______________________________________________ ទាំងឡាយ ដូចជាអញទើបនឹងធ្វើនោះទៀតដែរ (ខទី២១)"។

៣. ព្រះបន្ទូលសន្យារបស់ទ្រង់ មានតនៅក្នុងខទី២២។ ចូរសរសេរខគម្ពីរនេះ៖ ________________

______________________________________________________________

______________________________________________________________

ការទន្ទេញចាំមាត់៖ ព្រះបន្ទូលសន្យានៃព្រះ នៅក្នុងលោកុប្បត្តិ ៨:២១-២២ គឺជាព្រះបន្ទូលដ៏ល្អ ដែលយើងត្រូវតែទន្ទេញឱ្យចាំមាត់។ ចូរចំណាយពេលសរសេរខគម្ពីរនេះដាក់លើក្រដាសតូចមួយ ហើយទន្ទេញព្រះបន្ទូលសន្យាដ៏អស្ចារ្យនេះផង។ អ្នករាល់គ្នាក៏អាចចាត់ថ្នាក់ខគម្ពីរនេះជា "ព្រះបន្ទូលសន្យានៃព្រះ" ផងដែរ។

សេចក្តីបង្រៀន៖ ព្រះជាម្ចាស់មិនមែនមិនអើពើ នឹងសណ្ដានរបស់មនុស្សនោះទេ ប៉ុន្តែ ទ្រង់បានមានបន្ទូលបញ្ជាក់ថា បើទោះជាទ្រង់ជ្រាបថា មនុស្សនឹងធ្វើអ្វីខ្លះ ផែនដីនេះនឹងមានពេញដោយអំពើហិង្សា សេចក្តីពុករលួយ និងការអាក្រក់ដល់កម្រិតណា ក៏ទ្រង់មិនបំផ្លាញជីវិតទាំងអស់នៅលើផែនដីនេះ ដូចដែលទ្រង់ធ្លាប់បានធ្វើនោះទេ។ ពាក្យថា "បើទោះជា" គឺជាពាក្យដែលបង្ហាញពីសេចក្តីសប្បុរសរបស់ទ្រង់ ដ្បិតទ្រង់គឺជាព្រះដែលពេញដោយសេចក្តីមេត្តាករុណា។

- ***និយមន័យ៖ សេចក្តីសប្បុរស*** មានន័យថា ព្រះជាម្ចាស់មិនដាក់ទណ្ឌកម្មយើងទៅតាមអ្វីដែលយើងសមនឹងទទួលនោះទេ ដ្បិតដោយសារតែអំពើបាប និងចេតនាចង់ធ្វើតែការអាក្រក់នៅក្នុងចិត្តរបស់យើង យើងសមតែត្រូវវិនាសទៅទេ យើងសមតែស្លាប់។ នៅក្នុងគម្ពីររ៉ូម ៦:២៣ យើងដឹងថា "ឈ្នួលនៃអំពើបាប គឺជា ________ ____________ តែអំណោយទាននៃព្រះវិញ គឺជា ______________________________ ដោយព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា"។ យើងសមតែទទួលសេចក្តីស្លាប់ ប៉ុន្តែ ព្រះជាម្ចាស់បង្ហាញឱ្យយើងឃើញសេចក្តីសប្បុរសរបស់ទ្រង់ ដោយមិនប្រទាននូវអ្វីដែលយើងសមនឹងទទួលនោះទេ។ ផ្ទុយទៅវិញ ទ្រង់បង្ហាញសេចក្តីស្រឡាញ់ដល់យើង ដោយប្រទានជីវិតអស់កល្ប តាមរយៈសេចក្តីជំនឿក្នុងអង្គព្រះ យេស៊ូវវិញ។


©2013 CrossConnect Ministries

ការអនុវត្ត៖ ឧទាហរណ៍ដែលអាចជួយឱ្យបង្កើនការយល់ដឹងរបស់អ្នករាល់គ្នា អំពីសេចក្តីសប្បុរស ជាទិដ្ឋភាពនៃការចូលទៅក្នុងតុលាការ។ មានមនុស្សម្នាក់ជាប់ទោសឧក្រិដ្ឋ កំពុងឈរនៅមុខចៅក្រម។ សាលក្រមរបស់គាត់ គឺត្រូវជាប់ឃុំ (ឬស្លាប់) ពេលនោះ ស្រាប់តែកូនប្រុសរបស់ចៅក្រមក្រោកឈរឡើង និយាយថា "ចៅក្រមជាទីគោរព! ខ្ញុំសូមជាប់ឃុំ (ឬស្លាប់) ជំនួសបុគ្គលម្នាក់នេះ"។ ពេលនោះចៅក្រមក៏ប្រកាសប្រាប់ភាគីដែលជាប់ទោសនោះថា "អ្នកគ្មានទោសទេ" រួចបញ្ជូនកូនប្រុសរបស់គាត់ ទៅក្នុងមន្ទីរឃុំឃាំង (ឬទៅសម្លាប់)។ ទោសនេះមានអ្នកផ្សេង គេទទួលជំនួសហើយ ជនឧក្រិដ្ឋនោះមានសេរីភាពហើយ រឿងក្តីក៏ត្រូវបញ្ចប់ទៅដែរ។

ក្នុងឧទាហរណ៍នេះ ព្រះជាម្ចាស់ទ្រង់ជាចៅក្រម ក្រឹត្យវិន័យដែលទាមទារឱ្យមានភាពយុត្តិធម៌ ក៏បានអនុវត្តហើយដែរ។ ការបង់ថ្លៃលោះកំហុសដែលយើងបានប្រព្រឹត្ត ដាច់ខាតត្រូវតែបង់ យើងឈរនៅចំពោះព្រះភក្ត្រព្រះជាម្ចាស់ ទាំងជាប់ទោសបាប ហើយយើងសមនឹងទទួលទណ្ឌកម្មពីទ្រង់។ ប៉ុន្តែ ព្រះរាជបុត្រាទ្រង់ បានបង់ថ្លៃលោះជំនួសយើង ដោយយកអង្គទ្រង់មកទទួលទណ្ឌកម្មដែលយើងសមនឹងទទួល ហើយដោយសារតែការរងទុក្ខ និងការសុគតរបស់ទ្រង់ ព្រះដ៏ជាព្រះវរបិតា ទ្រង់ប្រទាននូវសេចក្តីសប្បុរសដល់យើងរាល់គ្នា ហើយប្រកាសប្រាប់យើងរាល់គ្នាថា "អ្នករាល់គ្នាគ្មានទោសទេ"។ យើងមានសេរីភាពហើយ! រឿងក្តីរបស់យើងត្រូវបានបញ្ចប់ហើយ។

- ចូរស្រមៃមើលជីវិតរបស់អ្នករាល់គ្នា ពេលអ្នករាល់គ្នាទទួលបានសេចក្តីសប្បុរស។ តើអ្នករាល់គ្នាសមនឹងទទួលសេចក្តីសប្បុរសនោះទេ? ប៉ុន្តែ អ្នករាល់គ្នាទទួលបានអ្វីមកជំនួសវិញ? ______________________

  ______________________________________________
- សូមរកនឹកនូវគំនិត និងអារម្មណ៍របស់អ្នករាល់គ្នា ពេលដែលអ្នករាល់គ្នាទទួលបានសេចក្តីសប្បុរស៖

  ______________________________________________
- មនុស្សនៅជុំវិញយើង កំពុងអំពាវនាវរកសេចក្តីសប្បុរស តើអ្នករាល់គ្នាអាចនាំយកសេចក្តីមេត្តាករុណា នៅក្នុងសភាពបែបណា? ______________________________

ការអធិស្ឋាន៖ ឱព្រះដ៏ជាព្រះវរបិតា ដែលពេញដោយព្រះគុណករុណាអើយ ទូលបង្គំសូមអរព្រះគុណចំពោះសេចក្តីមេត្តាករុណារបស់ទ្រង់ ដែលជួយឱ្យជីវិតយើងខ្ញុំលែងមានការភ័យខ្លាចចំពោះអ្វីដែលយើងខ្ញុំសមនឹងទទួល ហើយបែរជាឱ្យយើងខ្ញុំមានសង្ឃឹម ដោយសារតែអំណោយទានដ៏ឥតគិតថ្លៃរបស់ទ្រង់ ដែលជាជីវិតអស់កល្បជានិច្ចវិញ។ ទូលបង្គំសូមអរព្រះគុណចំពោះព្រះយេស៊ូវ។ សូមប្រទានឱ្យទូលបង្គំមានសេចក្តីជំនឿ អាចមើលឃើញព្រះហស្តនៃសេចក្តីមេត្តាករុណារបស់ទ្រង់ ដូចជាលោកណូអេដែរ។ ទោះជាគំនិតក្នុងចិត្តទូលបង្គំអាក្រក់យ៉ាងណា ក៏ទ្រង់បានសម្រេចព្រះទ័យរួចថែមទាំងថា ទ្រង់នឹងមិនបំផ្លាញជីវិតលើផែនដីនេះទៀតទេ ប៉ុន្តែ ទ្រង់នឹងបន្តរក្សាផែនដីនេះ ដរាបណាជីវិតទាំងអស់នៅរស់រាន។ ______________________________________________

______________________________________________

ការពិចារណា៖ ព្រះជាម្ចាស់បានប្រើទូកធំ ដើម្បីរក្សាជីវិតសេសសល់ ដែលទ្រង់បានបង្កើត។ ទូកធំនេះបានរក្សាជីវិតដែលនៅក្នុងនោះ មានក្តីសុខ សុវត្ថិភាព ពេលគេត្រូវឆ្លងកាត់គ្រោះទឹកជំនន់ដ៏ធំ។ ចូរស្រមៃពីជីវិតរបស់អ្នករាល់គ្នា នៅពេលដែលអ្នករាល់គ្នាជួបប្រទះនឹងបញ្ហានានា ដូចជា សម្ពន្ធភាពត្រូវគេរិះគន់ មិត្តភក្តិជួបប្រទះការលំបាក ដោយសារការសម្រេចចិត្តខុសសីលធម៌ ដែលគេបានធ្វើឡើង ដៃគូរកស៊ីក៏ត្រូវគេចាប់ខ្លួន ដោយសារការបោកប្រាស់អ្នកដទៃ ថែមទាំងត្រូវតស៊ូនឹងផលវិបាកដែលយាយីដល់ការងារ និងជីវិតគ្រួសាររបស់ពួកគេទៀតផង។

សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ប្រៀបបានទៅនឹងទូកធំ ដែលទ្រង់ប្រើដើម្បីលើកយើងឡើងឱ្យផុតពីកិច្ចការទាំងអំបាលម៉ាន ដែលទាមទារនូវការយកចិត្តទុកដាក់ ហើយអំពាវនាវឱ្យគេជួយ។ ព្រះជាម្ចាស់ចង់ឱ្យគ្រប់គ្នាចូលទៅក្នុងទូកធំរបស់ទ្រង់ ព្រះអង្គចង់ឱ្យគ្រប់គ្នាស្គាល់ព្រះគុណ និងសេចក្តីសប្បុរសរបស់ទ្រង់ ទ្រង់ចង់ឱ្យគ្រប់គ្នាមានក្តីអំណរនៅក្នុងសម្ពន្ធភាពនៃសេចក្តីស្រឡាញ់ជាមួយនឹងទ្រង់ ជាសម្ពន្ធភាពដែលធ្វើឱ្យពួកគេទាំងអស់គ្នារស់នៅដោយគ្មានការភ័យខ្លាចចំពោះសេចក្តីស្លាប់ ហើយរស់នៅជាមួយនឹងទ្រង់ដោយសេចក្តីអំណរ ទាំងពេលបច្ចុប្បន្ន និងអស់កល្បជានិច្ច។

រំឭកមេរៀន៖ យើងបានសិក្សាពីរឿងទឹកជំនន់ ដែលមានកត់ត្រាក្នុងគម្ពីរ លោកុប្បត្តិ ៦-៨ នេះរួចហើយ។ ពេលដែលព្រះជាម្ចាស់បានឃើញឱនភាពខាងសីលធម៌ អំពើហិង្សា អំពើពុករលួយ និងការអាក្រក់របស់មនុស្ស ទ្រង់ក៏សម្រេចព្រះទ័យលុបបំបាត់របស់គ្រប់យ៉ាងដែលមានដង្ហើមជីវិត ពីលើផែនដីនេះ មិនថាសត្វ ឬមនុស្សឡើយ។ ព្រះអង្គព្រួយព្រះទ័យចំពោះសភាពដ៏គួរឱ្យស្អប់របស់មនុស្ស។

លោកុប្បត្តិ ៦:៨ ចាប់ផ្តើមដោយពាក្យថា "ប៉ុន្តែ លោកណូអេ..." ដ្បិតព្រះជាម្ចាស់ទ្រង់បានរាប់លោកណូអេ ជាមនុស្សសុចរិត ដែលរស់ក្នុងការប្រកបជាមួយនឹងទ្រង់ ទ្រង់បានប្រាប់គាត់ពីផែនការរបស់ទ្រង់ និងណែនាំប្រាប់គាត់អំពីរបៀបសង់ទូកធំទៀតផង។ ពេលដែលទូកធំនេះសង់រួច ទ្រង់ក៏បានបង្គាប់ឱ្យលោកណូអេ និងប្រពន្ធ ព្រមទាំងកូនប្រុសទាំង៣ និងកូនប្រសាររបស់លោក ឱ្យចូលទៅក្នុងទូក។ ក្រៅពីនេះ ទ្រង់បានឱ្យសត្វប្រភេទមួយគូៗ រួមដំណើរជាមួយនឹងពួកគេទៀតផង បន្ទាប់មក ព្រះជាម្ចាស់ក៏ទ្វារទូក ហើយទឹកភ្លៀងក៏បង្អុរចុះមកពន្លិចផែនដី (លោកុប្បត្តិ ៧:១០)។

បន្ទាប់ពីទឹកបានស្រកទៅអស់ ទូកធំនោះក៏កឿងនៅលើដី ហើយអ្នកដែលនៅក្នុងទូកក៏ចេញមក។ នៅចុងជំពូក៨ យើងដឹងថា លោកណូអេ បានថ្វាយដង្វាយដុតដល់ព្រះយេហូវ៉ា ហើយដង្វាយនេះគាប់ដល់ទ្រង់ណាស់។ ទ្រង់ក៏សន្យាថា "ទោះជាគំនិតក្នុងចិត្តមនុស្ស អាក្រក់តាំងតែពីក្មេងមកក៏ដោយ" ក៏ទ្រង់នឹង "មិនបំផ្លាញជីវិតដែលរស់នៅលើផែនដី ដូចដែលទ្រង់ធ្លាប់ធ្វើនោះទេ"។ ឥឡូវយើងនឹងបន្តទៅមើលដំណើររឿងនៅក្នុង លោកុប្បត្តិ ជំពូកទី៩។

គេហកិច្ច៖ សូមអាន លោកុប្បត្តិ ៩:១-៧

លំហាត់៖

១. លោកុប្បត្តិ ៩:១ ស្តាប់ទៅសឹងតែដូចគ្នាទាំងស្រុងនឹង លោកុប្បត្តិ ១:២៨។ ពេលនេះ ព្រះពរដែលបានប្រទានឱ្យមនុស្សប្រុសស្រីដំបូង បានប្រទានឱ្យទៅលោកណូអេ និងកូនប្រុសរបស់លោក។ "ចូរ ________________ ឱ្យបាននៅ ____________________ លើផែនដីចុះ"។ ស្តាប់ទៅ លោកណូអេ ប្រៀបដូចជាអ័ដាមមួយថ្មី។ ព្រះជាម្ចាស់ត្រៀមជាស្រេចក្នុងការចាប់ផ្តើមសារជាថ្មី ទ្រង់ចង់ឱ្យមនុស្សទទួលព្រះពរ បានជាទ្រង់មានបន្ទូលទៅពួកគេថា "ចូរបង្កើតកូនឱ្យចម្រើនឡើង" ទ្រង់ចង់ឱ្យគេ "នៅពាសពេញផែនដី" នេះហើយគឺជាព្រះពរដែលទ្រង់ប្រទានឱ្យពួកគេ។

២. ទ្រង់មានបន្ទូលប្រាប់ពួកគេទៀតថា គ្រប់ទាំងសត្វនៅផែនដី សត្វហើរលើអាកាស សត្វលូនវារលើដី និងត្រីក្នុងសមុទ្រ "ត្រូវបានប្រគល់ទៅក្នុងអំណាចរបស់គេហើយ" (ខទី២)។ តើព្រះជាម្ចាស់មានបន្ទូលយ៉ាងណាខ្លះនៅក្នុង លោកុប្បត្តិ ១:២៦? ____________________________________________

____________________________________________

ការទូន្មានដែលទ្រង់បានបង្គាប់ដល់អ័ដាម និងអេវ៉ា គឺឱ្យពួកគេ "មានអំណាចលើ" ជីវិតសត្វទាំងអស់។

៣. នៅក្នុង លោកុប្បត្តិ ៩:៣ ព្រះជាម្ចាស់ទ្រង់មានបន្ទូលទៀតថា "បណ្តាសត្វទាំងប៉ុន្មាន ______________

______________________________________________

៤. យោងតាម លោកុប្បត្តិ ១:២៩-៣១ តើព្រះជាម្ចាស់ប្រទានអ្វីខ្លះឱ្យធ្វើអាហារដល់ជីវិតដែលនៅលើផែនដី?

ក. ខទី២៩ - អាហារសម្រាប់មនុស្ស៖ ______________________________

ខ. ខទី៣០-៣១ - អាហារសម្រាប់សត្វ៖ ______________________________

៥. ព្រះជាម្ចាស់មានបន្ទូលថា បណ្តាសត្វទាំងប៉ុន្មានដែលកម្រើក ហើយនៅរស់ នោះនឹងបានជាអាហារដល់ពួកគេ (លោកុប្បត្តិ ៩:៣)។ ប៉ុន្តែ ព្រះជាម្ចាស់បានដាក់លក្ខខណ្ឌពិសេសមួយ សារជាថ្មីម្តងទៀត។

ក. តើលក្ខខណ្ឌពិសេស ក្នុងលោកុប្បត្តិ ២:១៧ គឺជាអ្វី? ______________________

ខ. តើលើកនេះ លក្ខខណ្ឌពិសេស ក្នុងលោកុប្បត្តិ ៩:៤ គឺជាអ្វី? ______________________

ការអធិស្ឋាន៖ ឱព្រះដ៏ជាព្រះអម្ចាស់អើយ! ព្រះអង្គបានផ្គត់ផ្គង់ដល់ជីវិតដែលទ្រង់បានបង្កើតមក ដោយភាពសប្បុរស ទ្រង់ប្រព្រឹត្តដោយសប្បុរស គឺទ្រង់មិនបានដាក់ទណ្ឌកម្មដល់យើង ដូចដែលយើងសមនឹងទទួល ដោយព្រោះតែកំហុសដែលយើងបានប្រព្រឹត្តនោះទេ ផ្ទុយទៅវិញ ទ្រង់បានសម្រេចប្រទានក្តីស្រឡាញ់ដល់យើងរាល់គ្នា ដោយមិនសំចៃទុកឡើយ។ សូមអរព្រះគុណដែលទ្រង់ប្រទានពរដល់យើងរាល់គ្នា ព្រមទាំងត្រាស់ហៅយើងរាល់គ្នាឱ្យបង្កើតកូនចៅពាសពេញផែនដី។ ទ្រង់ប្រាថ្នាឱ្យផែនដីមានពេញដោយជីវិត ទ្រង់ថែមទាំងបង្រៀនយើងឱ្យចេះផ្តល់តម្លៃដល់ជីវិត ទាំងអស់ទៀតផង។ ______________________________________________

______________________________________________

## ផ្នែកទី៥

សេចក្តីបង្រៀន៖ ម្តេចក៏ព្រះជាម្ចាស់មានបន្ទូលដដែលៗអំពីចំណុចមួយថា មិនត្រូវឱ្យបរិភោគសាច់ដែល "មានឈាម (នៅរស់)" ក្នុងលោកុប្បត្តិ ៩:៤ យ៉ាងដូច្នេះ? កណ្ឌគម្ពីរលេវីវិន័យ មានចែងពីច្បាប់ដែលគេហៅថា ក្រឹត្យវិន័យសម្រាប់ពួកលេវី។ ក្រឹត្យវិន័យទាំងនេះ គឺជាក្រឹត្យវិន័យដែលព្រះជាម្ចាស់មានសម្រាប់កូនរបស់ព្រះអង្គ គឺកូនចៅអ៊ីស្រាអែល ឬពួកសាសន៍អ៊ីស្រាអែល ដែលបន្តរស់នៅជាច្រើនក្រោយមកទៀត នៅក្នុងប្រវត្តិសាស្ត្រនៃព្រះគម្ពីរ។ គម្ពីរលេវីវិន័យ ១៧:១០-១៤ ផ្តល់នូវចំណេះដឹងខ្លះ ទាក់ទងនឹងហេតុផលដែលព្រះជាម្ចាស់មានបន្ទូលប្រាប់លោកណូអេ មុននេះបន្តិចថា មិនត្រូវឱ្យបរិភោគសត្វដែលមានឈាម (ឬនៅរស់) នោះឡើយ។

គេហកិច្ច៖ សូមអានលេវីវិន័យ ១៧:១០-១៤

លំហាត់ - ជីកឱ្យកាន់តែជ្រៅ...

១. យោងតាមខគម្ពីរទាំងនេះ តើព្រះជាម្ចាស់ឱ្យតម្លៃអ្វីខ្លះដល់ឈាម? ______________________

______________________________________________

ចូរកត់ត្រាជាពិសេស ពាក្យដែលនៅក្នុងខទី១១ និងទី១៤៖ "ដ្បិត__________ នៃ__________ នោះនៅក្នុង ______________ "។ ព្រះជាម្ចាស់ឱ្យតម្លៃឈាម ពីព្រោះឈាមគឺជាជីវិតនៃអស់ទាំងសត្វ។

២. ព្រះជាម្ចាស់ក៏មានបន្ទូលក្នុងខទី១១ថា ឈាមនេះហើយ "ដែល __________ នឹង ____________ បាន"។

សេចក្តីបង្រៀន៖ មុនដែលព្រះយេស៊ូវយាងមកផែនដី គេយកសត្វមកធ្វើជាយញ្ញបូជាថ្វាយព្រះយេហូវ៉ា ដើម្បីឱ្យធួននឹងអំពើបាបរបស់មនុស្ស។ ការថ្វាយយញ្ញបូជាសត្វ និងឈាមដែលបង្ហូរមក រម្លាប់សេចក្តីក្រោធដែលព្រះទ្រង់មានចំពោះ


©2013 CrossConnect Ministries

មនុស្ស ដោយព្រោះតែអំពើបាបរបស់គេ។ ព្រះជាម្ចាស់ទទួលយកយញ្ញបូជាសត្វ ជាថ្លៃលោះបាបរបស់គេ ជំនួសសេចក្ដីស្លាប់របស់មនុស្ស គឺឈាមនេះហើយដែលគ្របបាំងអំពើបាប។

- *និយមន័យ៖* ធួន (ដង្វាយធួន) ឬលោះ៖ លោះបាបមនុស្សមានន័យថា លែងមានអ្វីមករាំងស្ទះ ឬបង្កនូវការរំខានដល់សម្ពន្ធភាពរវាងព្រះជាម្ចាស់ និងមនុស្សទៀតហើយ។ ដង្វាយធួន មានន័យថា ពួកគេមានរួមមកតែមួយជាមួយព្រះជាម្ចាស់។ ឈាមដែលបង្ហូរចេញពីសាច់សត្វ រាប់ទុកជាដង្វាយលោះបាបមនុស្ស និងបង្វែរសេចក្ដីក្រោធរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់បានអត់ទោសអំពើបាបរបស់មនុស្ស នៅពេលដែលគេបង្ហូរឈាមសត្វ ហើយធ្វើជាយញ្ញបូជាថ្វាយទ្រង់។

បទគម្ពីរផ្សេងទៀតនឹងជួយឱ្យនិយមន័យ និងពន្យល់បន្ថែមទាក់ទងនឹងដង្វាយធួន៖

១. យោងតាមបទគម្ពីរហេព្រើរ ៩:២២ យើងដឹងថា " ________________ ខ្វាយ ________________ នោះគ្មាន ____________________________________________________________"។

២. គម្ពីររ៉ូម ៣:២៥ ចែងថា ព្រះបានតាំង ______ ទុកជា ______________________ ដោយសារសេចក្ដីជំនឿដល់ព្រះលោហិតទ្រង់ សម្រាប់នឹងសម្ដែងឱ្យឃើញសេចក្ដីសុចរិតរបស់ព្រះ ចំពោះការដែលទ្រង់មិនប្រកាន់អំពើបាប ដែលគេប្រព្រឹត្តពីដើម ដោយទ្រង់មានព្រះហឫទ័យអត់ធ្មត់។

- *វាក្យនិយមន័យ៖* បានរាប់ជាសុចរិត - ព្រះជាម្ចាស់មិនប្រកាន់ទោសបាបខ្ញុំទៀតទេ ហើយខ្ញុំក៏លែងត្រូវប្រឈមទៅនឹងការចោទប្រកាន់ ដោយសារការមិនស្ដាប់បង្គាប់របស់ខ្ញុំទៀតដែរ។ "ជាប់មានទោស" ជាពាក្យផ្ទុយនឹងពាក្យថា "បានរាប់ជាសុចរិត"។ ព្រះជាម្ចាស់បានប្រកាសថា រូបខ្ញុំគ្មានកំហុសទេ ទ្រង់មានបន្ទូលប្រាប់ខ្ញុំទៀតថា សម្ពន្ធភាពរបស់ខ្ញុំហើយនិងទ្រង់ ត្រូវបានផ្សះផ្សារឡើងវិញហើយ។ ជីវិតរបស់ព្រះយេស៊ូវ រួមទាំងការរងទុក្ខ និងការសុគតរបស់ទ្រង់ គឺធ្វើឡើងសម្រាប់ខ្ញុំ ទ្រង់ធ្វើឱ្យខ្ញុំបានសុចរិតនៅចំពោះព្រះជាម្ចាស់។ យញ្ញបូជាចុងក្រោយនៃព្រះរាជបុត្រាទ្រង់ បញ្ឈប់លែងឱ្យមានការថ្វាយយញ្ញបូជាទាំងអស់ដែលយើងត្រូវការ។ ព្រះយេស៊ូវបានបង់ថ្លៃលោះចុងក្រោយបង្អស់ សម្រាប់អំពើបាប ដោយបង្ហូរព្រះលោហិតទ្រង់នៅលើឈើឆ្កាងជួសយើងរាល់គ្នា។

**ការទន្ទេញចាំមាត់៖** នៅក្នុងមេរៀននេះ មានខគម្ពីរខ្លះដែលខ្ញុំសូមលើកទឹកចិត្តឱ្យអ្នករាល់គ្នាកត់ទុក ដើម្បីទន្ទេញឱ្យចាំមាត់។ កុំភ្លេចឈ្មោះកណ្ឌ ជំពូក និងខយោង នៃខគម្ពីរដែលមាននេះផង។

១. ហេព្រើរ ៩:២២ (ចុងខ) "... បើគ្មានខ្វាយឈាមទេ នោះគ្មានផ្លូវណាឱ្យរួចពីបាបបានឡើយ"។
២. លេវីវិន័យ ១៧:១១ - (ខគម្ពីរទាំងមូល)
៣. រ៉ូម ៣:២៥ - "ដែលព្រះបានតាំងទ្រង់ទុកជាទីសន្ដោសប្រោស ដោយសារសេចក្ដីជំនឿដល់ព្រះលោហិតទ្រង់"។

នៅលើក្រដាសដែលអ្នករាល់គ្នាកត់ខគម្ពីរទាំងនេះទុក ចូរសរសេរពាក្យ ឬឃ្លាណា ដែលជួយឱ្យអ្នកនឹងឃើញពីសារៈសំខាន់នៃការខ្វាយឈាម។

**ការអធិស្ឋាន៖** សូមអរព្រះគុណព្រះដ៏ជាព្រះអម្ចាស់ ចំពោះការប្រព្រឹត្តដោយសប្បុរស និងមិនដាក់ទោសយើងឱ្យសមនឹងអំពើបាបដែលយើងប្រព្រឹត្ត គឺជាសេចក្ដីស្លាប់ដ៏អស់កល្បជានិច្ចទេ។ អរព្រះគុណទ្រង់ដែលស្រឡាញ់យើងខ្ញុំ ដោយប្រទានព្រះរាជបុត្រាទ្រង់ឱ្យធ្វើជាដង្វាយលោះបាប ដែលដកយកអស់ទាំងទោសនៃអំពើបាប ធ្វើឱ្យយើងបានផ្សះផ្សារនឹងទ្រង់វិញ ហើយប្រទានឱ្យយើងមានជីវិតអស់កល្បជានិច្ចផង។ ________________________________


©2013 CrossConnect Ministries

ផ្នែកទី៦

សេចក្តីផ្តើម៖ យើងបានចំណាយពេលច្រើនគួរសម ក្នុងការសិក្សាព្រះបន្ទូលដែលព្រះជាម្ចាស់បានថ្លែងប្រាប់ដល់លោកណូអេរួចហើយ ដូច្នេះ យើងមានការយល់ដឹងកាន់តែច្បាស់ពីតម្លៃដែលទ្រង់ផ្តល់ចំពោះឈាមដែរ។ អ្នករាល់គ្នានឹងចាប់ផ្តើមទន្ទេញខគម្ពីរសំខាន់ៗ ដែលផ្តល់នូវគ្រឹះសម្រាប់ការស្វែងរកគំនិតប្រាជ្ញា ពេលយើងបន្តការសិក្សានេះ។ លោកុប្បត្តិ ៩:៥-៦ មានចំណែកព័ត៌មានថ្មីមួយដែលជួយផ្តល់នូវតម្លៃបន្ថែមដល់ការយល់ដឹងរបស់យើង ទាក់ទងនឹងហេតុផលដែលព្រះជាម្ចាស់ឱ្យតម្លៃឈាមខ្លាំងដល់ម្ល៉េះ។ បើទោះជាយើងហាក់បីដូចជាចំណាយពេលច្រើន លើសពីការចាំបាច់ ទាក់ទងនឹងប្រធានបទនេះ ក៏ខ្ញុំសូមលើកទឹកចិត្តអ្នករាល់គ្នាឱ្យខំសិក្សាបន្តទៀតដែរ។ ព័ត៌មានដ៏គួរឱ្យចាប់អារម្មណ៍ទាំងអស់នេះ គឺជាសេចក្តីពិតដ៏ជាមូលដ្ឋាល សម្រាប់បណ្តុះទស្សនៈនៃការអរព្រះគុណព្រះជាម្ចាស់ និងទទួលស្គាល់អំពីតម្លៃដែលទ្រង់បានឱ្យដល់យើង ព្រមទាំងសម្ពន្ធភាពដែលទ្រង់ចង់ឱ្យមានជាមួយនឹងប្រជារាស្ត្រទ្រង់។

ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ខ្លាំងចំពោះឈាមសត្វ និងឈាមមនុស្សគ្រប់គ្នា ទ្រង់មិនត្រឹមតែមានមិនឱ្យពួកគេបរិភោគសាច់ដែលមានឈាមនោះទេ នៅក្នុងលោកុប្បត្តិ ៩:៥ ទ្រង់មានបន្ទូលបន្តទៀតថា ទ្រង់នឹង __________ ______________________ ដោយសារអស់ទាំងសត្វ ហើយដោយសារដៃរបស់មនុស្ស។

ដំបូងចូរយើងទៅមើលការលើកឡើងមួយផ្សេងទៀត ដែលនិយាយអំពីការទទួលខុសត្រូវចំពោះឈាមសត្វទាំងអស់។ នៅខាងដើមមេរៀននេះ យើងបានបញ្ជាក់ម្តងហើយថា ព្រះជាម្ចាស់មានប្រទានក្រឹត្យវិន័យខាងសីលធម៌ ដល់ពួកកូនចៅអ៊ីស្រាអែល នៅពេលដែលគេស្ថិតក្នុងទីរហោស្ថាន ប៉ុន្មានឆ្នាំក្រោយមក។ ក្រឹត្យវិន័យនេះ ត្រូវបានប្រទានឱ្យពួកគេយ៉ាងលម្អិត ដ្បិតទ្រង់ចង់ឱ្យពួកគេយល់ថា ក្រឹត្យវិន័យនេះត្រូវបានប្រទានមក ដើម្បីការពារពួកគេពីគ្រោះថ្នាក់ដែលស្មានមិនដល់ ថែមទាំងផ្តល់ឱ្យគេនូវការថែរក្សាប្រកបដោយសុវត្ថិភាពទៀតផង។ ក្រឹត្យវិន័យរបស់ព្រះ គឺជាមធ្យោបាយដែលជួយឱ្យមនុស្សអាចឆ្លើយតបទៅព្រះជាម្ចាស់វិញ ដោយការស្តាប់បង្គាប់ ហើយបង្ហាញប្រាប់ពួកគេថា ពួកគេត្រូវតែសម្រេចចិត្តជ្រើសយកព្រះអង្គ និងព្រះបន្ទូលរបស់ទ្រង់ ធ្វើជាចំណុចស្នូលនៅក្នុងជីវិតរបស់គេ។ ការឆ្លើយតបនេះ នឹងស្តែងឱ្យឃើញពីសម្ពន្ធភាពនៃសេចក្តីស្រឡាញ់ ដែលគេមានជាមួយនឹងព្រះជាម្ចាស់។

លំហាត់ - ជីកឱ្យកាន់តែជ្រៅ...

១. នៅក្នុងលោកុប្បត្តិ ៩:៥ ព្រះជាម្ចាស់ប្រាប់លោកណូអេថា "ទ្រង់នឹងទារឈាមអ្នកនោះ ដោយសារសត្វទាំងអស់" តើអ្វីជាឧទាហរណ៍អំពីចំណុចនេះ ក្នុងក្រឹត្យវិន័យដែលមានចែងទុកក្នុងនិក្ខមនំ ២១:២៨-៣២? __________

______________________________________________________________

*ចំណាំ៖* សូមកុំទាល់គំនិត ដោយសារតែព័ត៌មានលម្អិតដែលគេមិនបានពន្យល់ ឬក៏មិនយល់អំពីការណែនាំនេះថ្មី ចូរស្វែងយល់អត្ថន័យនៃព្រះបន្ទូលដែលព្រះជាម្ចាស់ចង់ប្រាប់ នៅក្នុងលោកុប្បត្តិ ៩ ក្នុងកាលដែលទ្រង់មានព្រះបន្ទូលអំពី "ការទារឈាម ដោយសារសត្វទាំងអស់" វិញ។

២. នៅក្នុងចំណែកទី២ នៃបទគម្ពីរលោកុប្បត្តិ ៩:៥ ព្រះក៏មានបន្ទូលថា ទ្រង់នឹង "ទារ __________________ ដោយសារដៃរបស់មនុស្ស គឺដោយសារ ____________________________________________"។

ជួនកាលការខ្វល់ខ្វាយរបស់យើង ចំពោះឈាមមនុស្សដូចគ្នា គឺសឹងតែគ្មានសោះ។ តាមរយៈបណ្តាសារព័ត៌មាន យើងឃើញថា ការសម្លាប់មនុស្ស មានជារៀងរាល់ថ្ងៃ។ ទូរទស្សន៍ ខ្សែភាពយន្ត សុទ្ធតែមានឥទ្ធិពលទាក់ទងនឹងជីវិតមនុស្ស។ គម្ពីរលោកុប្បត្តិ ៩ ជម្រុញឱ្យយើងសម្លឹងមើលបញ្ហាទាំងអស់នេះ តាមបំណងព្រះហឫទ័យនៃព្រះ

វិញ។ នៅក្នុងខទី៦ យើងឃើញទ្រង់មានបន្ទូលថា "អ្នកណាដែល ____________________ អ្នកនោះឯងនឹងត្រូវ ____________________ ដ្បិត ____________ បានបង្កើតមនុស្សមកឱ្យដូចជា ____________________"។

យោងតាមបទគម្ពីរនេះ ជីវិត ជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ ហើយទ្រង់ចង់ប្រទាន ឬដកចេញពីអ្នកណា គឺស្រេចតែនឹងទ្រង់។ ចូរចាំថា ព្រះពររបស់ព្រះ គឺឱ្យមនុស្សចូលរួមជាមួយនឹងទ្រង់ ក្នុងការថែរក្សាជីវិតលើផែនដី ទ្រង់ចង់ឱ្យពួកគេបង្កើតកូនចៅឱ្យច្រើន ពាសពេញផែនដី មិនមែនឱ្យគេបង្ហូរឈាមគ្នា ទៅវិញទៅមកទេ។ សេចក្ដីស្លាប់ ស្ដែងចេញពីអំពើបាប មិនមែនព្រះពររបស់ព្រះជាម្ចាស់នោះឡើយ។

**ការសញ្ជឹងគិត៖** ព្រះបន្ទូលនេះ អាចធ្វើឱ្យអ្នករាល់គ្នាគិតដល់ស្ថានភាពស្មុគស្មាញជាច្រើន ព្រមទាំងបង្កើតឱ្យមាននូវសំណួរជាច្រើន ដែលត្រូវការចម្លើយ ដូច្នេះ សូមកុំភ្លេចកត់ត្រានូវគំនិត និងការសង្កេតឃើញរបស់អ្នករាល់គ្នា។ អ្នករាល់គ្នាអាចនឹងឃើញថា អ្នករាល់គ្នាកំពុងតស៊ូជាមួយគំនិត និងទស្សនៈថ្មីៗ ដែលអ្នករាល់គ្នាពុំធ្លាប់គិតដល់។ តើគំនិតថ្មីទាំងអស់នេះ រំខានដល់អ្នករាល់គ្នាដែរឬទេ? តើវាបង្កការលំបាកអ្វីខ្លះដល់អ្នករាល់គ្នា? ____________________

____________________________________________

សូមចំណាយពេលឆ្លើយនឹងសំណួរដូចតទៅ៖ ក) តើព្រះជាម្ចាស់កំពុងមានបន្ទូលអ្វីខ្លះ? ខ) តើទ្រង់ពិតជាចង់បានន័យដូចនឹងអ្វីដែលទ្រង់ថ្លែងនោះមែនទេ?

១. តើលោកិយយើងនេះ ស្ដែងឱ្យឃើញពីការឆ្លើយតបដោយស្ដាប់តាមព្រះបន្ទូលព្រះ ដោយវិធីណាខ្លះ? ________

____________________________________________

២. តើលោកិយយើងនេះ ស្ដែងឱ្យឃើញពីការឆ្លើយតបដោយមិនស្ដាប់តាមព្រះបន្ទូលព្រះ ដោយវិធីណាខ្លះ? _____

____________________________________________

៣. វិធីរស់នៅរបស់យើង ក្នុងការឆ្លើយតបនឹងព្រះបន្ទូល ស្ដែងឱ្យឃើញពីអត្តសញ្ញាណនៃអ្នកដែលយើងជ្រើសយកមកធ្វើជាចំណុចស្នូលនៃជីវិតរបស់យើង។

ក. តើជីវិតរបស់ខ្ញុំ ស្ដែងឱ្យឃើញអ្វីខ្លះ? ____________________

____________________________________________

ខ. តើជីវិតមិត្តភក្តិអ្នករាល់គ្នា ស្ដែងឱ្យឃើញអ្វីខ្លះ? ____________________

____________________________________________

គ. តើពិភពលោកយើងនេះ ស្ដែងឱ្យឃើញអ្វីខ្លះ? ____________________

____________________________________________

**ការអធិស្ឋាន៖** ឱព្រះអម្ចាស់អើយ! ទូលបង្គំមានគំនិត និងសំណួរជាច្រើន។ មេរៀននេះបានរំឭកប្រាប់ទូលបង្គំថា ទ្រង់បានប្រទានឱ្យលោកណូអេ នូវគោលបំណងដែលប្រកបដោយប្រាជ្ញាញាណ សម្រាប់ជីវិតគាត់។ ទ្រង់ក៏បានឱ្យគាត់មានទំនួលខុសត្រូវចំពោះឈាមមនុស្ស ដូចជាគាត់ដែរ។ សូមកែប្រែសេចក្ដីស្រឡាញ់ ក្នុងចិត្តរបស់ទូលបង្គំ ឱ្យចេះឱ្យតម្លៃជីវិតមនុស្ស។ សូមជួយឱ្យទូលបង្គំអាចការពារអ្នកដទៃ ពីគ្រោះថ្នាក់ទាំងឡាយណាដែលយាយីជីវិតគេ។ __________

____________________________________________


©2013 CROSSCONNECT MINISTRIES

សេចក្តីបង្រៀន៖ ព្រះជាម្ចាស់បង្កើតមនុស្សមក តាមរូបអង្គទ្រង់ (លោកុប្បត្តិ ១:២៧)។ យោងតាមគម្ពីរលោកុប្បត្តិ ៥:៣ យើងដឹងថា សមត្ថភាពរបស់មនុស្សក្នុងការស្តែងឱ្យឃើញពីរូបអង្គរបស់ព្រះជាម្ចាស់ បានខូចបង់អស់ដោយសារតែអំពើបាប។ កូនចៅដែលអ័ដាមបង្កើតមក គឺកើតមកតាមសណ្ឋានរបស់អ័ដាម។ ថ្វីបើសណ្ឋានដើមរបស់មនុស្សត្រូវខូចបង់ដោយសារអំពើបាបក៏ដោយ ក៏គេនៅតែមានសណ្ឋានដើមនៃរូបអង្គព្រះ នៅជាមួយនឹងពួកគេដដែល ហើយព្រះអង្គក៏មិនចង់ឱ្យអ្នកផ្សេង មកដណ្តើមយកជីវិតដែលមានសណ្ឋានរូបអង្គរបស់ទ្រង់ទៅដែរ។ ចូរចងចាំព្រះបន្ទូលដែលទ្រង់ប្រាប់ដល់កាអ៊ីន នៅក្នុងលោកុប្បត្តិ ៤:១០ បន្ទាប់ពីកាអ៊ីនបានសម្លាប់អេបិលជាប្អូនថា "ឯងបានធ្វើអ្វីដូច្នេះ ពីព្រោះឮសូរសម្រែកនៃឈាមប្អូនឯង ពីដីឡើងទៅដល់អញ"។

លោកុប្បត្តិ ៩:៦ ចែងថា "ដ្បិត ____________ បានបង្កើត ______________ ឱ្យដូចជា ____________________"។ ព្រះជាម្ចាស់ឱ្យតម្លៃយើងខ្លាំង ដ្បិតយើងជាមនុស្សដែលកើតមកតាមរូបអង្គទ្រង់ ដូច្នេះ ពេលដែលឈាមរបស់មនុស្សត្រូវគេកម្ចាយ ជីវិតដែលកើតមកតាមរូបអង្គទ្រង់ ក៏ត្រូវស្លាប់ទៅដែរ។ យើងរាល់គ្នាជាមនុស្សដែលកើតមកតាមរូបអង្គព្រះ ហេតុនេះបានជាជីវិតយើង មានតម្លៃដល់ម្ល៉េះ។

ការសញ្ជឹងគិត និងសំណួរអនុវត្ត៖ ព្រះបន្ទូលព្រះថ្លែងថា ខ្ញុំកើតមកតាមរូបអង្គព្រះជាម្ចាស់ ចំណែកឯមនុស្សដទៃទៀត ក៏កើតមកតាមរូបអង្គព្រះជាម្ចាស់ ដូចខ្ញុំដែរ។ សំណួរខាងក្រោមនេះ ត្រូវបានរៀបចំឡើង ដើម្បីជួយអ្នករាល់គ្នាគិតសញ្ជឹងគិតអំពីអត្ថន័យនៃការដែលយើងកើតមក តាមរូបអង្គព្រះ និងពិចារណាអំពីដែលយើងមាន ចំពោះជីវិតរបស់យើងផ្ទាល់ និងជីវិតរបស់អ្នកដទៃ។

១. តើអ្នករាល់គ្នាគិតយ៉ាងណា ពេលអ្នករាល់គ្នាដឹងថា មនុស្សទាំងអស់ត្រូវបានបង្កើតមកតាមរូបអង្គព្រះ បើទោះជាសណ្ឋានដើមនៃជីវិតបែបនេះ ត្រូវអំពើបាបបង្ខូចបង់ក៏ដោយនោះ? ______________________________

______________________________________________________________

២. តើរូបអង្គរបស់ព្រះ អាចបាត់បង់ដែរទេ? ចុះអ្នកដែលបដិសេធព្រះជាម្ចាស់ ហើយរស់នៅដោយឡែកពីទ្រង់វិញនោះ ទៅជាយ៉ាងណា? ______________________________________________

______________________________________________________________

៣. ក្នុងនាមជាមនុស្សដែលកើតមកតាមរូបអង្គព្រះ តើអ្នករាល់គ្នាឱ្យតម្លៃជីវិតខ្លួនឯងដូចម្តេចខ្លះ? តើជីវិតរបស់អ្នកបង្ហាញពីតម្លៃនេះ ដោយវិធីណា? ______________________________________

______________________________________________________________

៤. តើអ្នករាល់គ្នាឱ្យតម្លៃជីវិតដល់អ្នកដទៃ ដែលកើតមកតាមរូបអង្គព្រះ ដូចម្តេចខ្លះ? តើជីវិតរបស់អ្នក បង្ហាញពីតម្លៃនេះ ដោយវិធីណា? ______________________________________________

______________________________________________________________

សំណួរទាំងនេះ អាចជាសំណួរដែលពិបាកឆ្លើយ ប៉ុន្តែកាលណាយើងទទួលស្គាល់ថា មនុស្សទាំងអស់សុទ្ធត្រូវបានបង្កើតមកតាមរូបអង្គព្រះ នោះយើងមិនអាចបំភ្លេចទំនួលខុសត្រូវរបស់យើង ក្នុងការថែទាំ និងការពារពួកគេនោះឡើយ យើងត្រូវការពារទាំងជីវិត ទ្រព្យសម្បត្តិ កេរ្តិ៍ឈ្មោះ ចរិតលក្ខណៈ ហើយដែលសំខាន់ជាងគេគឺ សម្ពន្ធភាពរបស់ពួកគេជាមួយនឹងព្រះដែលបានបង្កើតគេមក។


©2013 CrossConnect Ministries

ការអធិស្ឋាន៖ ឱព្រះជាម្ចាស់អើយ! ជារឿយៗ ទូលបង្គំរមែងគិតពីខ្លួនឯង ច្រើនជាងអ្នកដទៃ។ ទូលបង្គំមិនបានគោរព និងតម្លៃដល់អ្នកដទៃ ដូចដែលទូលបង្គំគួរធ្វើនោះទេ។ ពួកគេក៏ត្រូវបានបង្កើតមកតាមរូបអង្គទ្រង់ ហើយជីវិតគេក៏ទ្រង់ជាអ្នកប្រទានឱ្យ ដូចជាទូលបង្គំដែរ ប៉ុន្តែទូលបង្គំរមែងភ្លេចថា ទូលបង្គំនៅក្នុងព្រះគ្រីស្ទ ហើយទ្រង់បានត្រាស់ហៅទូលបង្គំឱ្យស្វែងរកអំពីទ្រង់ ដល់ជីវិតទាំងឡាយដែលទ្រង់បានបង្កើតមក ជាពិសេសគឺគ្រួសារ និងមិត្តភ័ក្តិរបស់ទូលបង្គំ ហើយនិងអស់អ្នកដែលរស់នៅក្នុងសហគមន៍ជាមួយទូលបង្គំ។ សូមអត់ទោសដល់ទូលបង្គំ ពេលដែលទូលបង្គំមិនបានឱ្យតម្លៃជីវិត និងគ្មានសេចក្តីប្រាថ្នាចង់រស់នៅ ប្រកបដោយទំនួលខុសត្រូវ។ ________________________

________________________________________

ផ្នែកទី៧

សេចក្តីបង្រៀន៖ ក្នុងលោកុប្បត្តិ ៦:១៨ ព្រះជាម្ចាស់ប្រាប់ពីចេតនារបស់ទ្រង់ ក្នុងការលុបបំបាត់ជីវិតទាំងអស់នៅលើផែនដី និងបានប្រទានសេចក្តីសន្យាមួយដល់គាត់។ ចូរសរសេរ ខទី១៨៖ ________________________

________________________________________

នៅក្នុងសេចក្តីសន្យានេះ ព្រះទ្រង់មានបន្ទូលថា ទ្រង់នឹងតាំងសេចក្តីសញ្ញាជាមួយលោកណូអេ។

➢ *និយមន័យ៖ សេចក្តីសញ្ញា (សម្ពន្ធមេត្រី)* - សេចក្តីសញ្ញា ឬសម្ពន្ធមេត្រី ជាកិច្ចព្រមព្រៀងដ៏សំខាន់មួយដែលផ្តួចផ្តើមឡើងដោយភាគីម្ខាង រួចផ្តល់ឱ្យទៅភាគីម្ខាងទៀត។ សម្ពន្ធមេត្រីនេះ នៅតែមានសុពលភាពជាធរមាន លុះត្រាតែមានភាគីណា ក្បត់ ឬរំលោភលើលក្ខខណ្ឌនៃសម្ពន្ធមេត្រីនេះ។
*ចំណាំ៖* អ្នករាល់គ្នាប្រាកដជាធ្លាប់ស្គាល់ពីសេចក្តីសញ្ញា ឬសម្ពន្ធមេត្រីនេះហើយ។ ឧទាហរណ៍ ប្រសិនបើអ្នករាល់គ្នាចង់ខ្ចីប្រាក់ពីធនាគារ ក្នុងនាមជាភ្នាក់ងារផ្តល់ប្រាក់កម្ចី ធនាគារនឹងសរសេរលក្ខខណ្ឌពិសេសមួយចំនួនទាក់ទងនឹងប្រាក់កម្ចី រួចផ្តល់ជាកិច្ចសន្យាឱ្យមកអ្នករាល់គ្នាដែលជាអ្នកខ្ចី។ ពេលដែលអ្នកទាំងពីរចុះហត្ថលេខាកិច្ចសន្យានេះ ក្លាយជាឯកសារគតិយុទ្ធ កំណត់ដោយច្បាប់ដែលទទួលស្គាល់ដោយតុលាការ។

លំហាត់៖

១. ក្នុងរឿងនេះ ព្រះជាម្ចាស់ជាអ្នកផ្តួចផ្តើមព្រះបន្ទូលសន្យានៃសេចក្តីសប្បុរសដ៏សំខាន់ នេះជាព្រះបន្ទូលសន្យាដែលទ្រង់មិនអាចក្បត់ទេ។ តើព្រះជាម្ចាស់បានតាំងសេចក្តីសញ្ញាជាមួយអ្នកណាខ្លះ (លោកុប្បត្តិ ៩:៩-១០)?
   ក. ________________________
   ខ. ________________________
   គ. ________________________

២. ព្រះជាម្ចាស់បានផ្តួចផ្តើម និងតាំងសេចក្តីសញ្ញាជាមួយលោកណូអេ កូនប្រុសរបស់លោក ព្រមទាំងកូនចៅជំនាន់ក្រោយទៀតផង ទ្រង់បានរាប់បញ្ចូលទាំងសត្វដែលចេញមកពីទូកធំ ព្រមទាំងរបស់គ្រប់យ៉ាងដែលមានជីវិតនៅលើផែនដីនេះផង។ ច្រើនណាស់ មែនទេ? លោកុប្បត្តិ ៩:១១ ជាការថែងទុកអំពីសេចក្តីសញ្ញាពិត ចូរសរសេរខគម្ពីរនេះ៖ ________________________

________________________________________

________________________________________

________________________________________


©2013 CrossConnect Ministries

៣. ក្នុងលោកុប្បត្តិ ៨:២១ ពេលព្រះជាម្ចាស់ទ្រង់ធុំ "ក្លិនឈ្ងុយ" នៃយញ្ញបូជារបស់លោកណូអេ ខគម្ពីរនេះចែងថា ទ្រង់ "សម្រេចក្នុងព្រះទ័យ..." យើងឮទ្រង់មានបន្ទូលចេញពីព្រះទ័យរបស់ទ្រង់មកថា ទ្រង់នឹងមិនបំផ្លាញផែនដីដោយទឹកជំនន់ទៀតទេ។ ចូរកត់សម្គាល់អំពីការប្រើប្រាស់ពាក្យថា "អញនឹងមិន...!" នៅក្នុងលោកុប្បត្តិ ៨:២១ និង ៩:១១។ តើទ្រង់ប្រើពាក្យនេះប៉ុន្មានដង? ____________________ អ្នករាល់គ្នាសឹងតែនឹងអាចស្តាប់ឮព្រះសូរសៀងយ៉ាងច្បាស់ថា "អញនឹងមិន... ទៀតទេ!"

៤. ក្រោយមក ព្រះជាម្ចាស់ក៏សម្រេចប្រទាននូវសញ្ញាមួយសម្រាប់សម្គាល់ពីសេចក្តីសញ្ញានេះ។ តើសញ្ញាសម្គាល់នេះគឺជាអ្វី? ____________________________

៥. សូមអានខទី១២ និងទី១៣។ ព្រះជាម្ចាស់យកឥន្ទធនូធ្វើជាសញ្ញាសម្គាល់សម្រាប់យើងរាល់គ្នាថា ទ្រង់នឹងនឹងចាំព្រះបន្ទូលសន្យារបស់ទ្រង់។ ទ្រង់ប្រើឥន្ទធនូ ទុកជាការរំឭកអង្គទ្រង់ អំពីព្រះបន្ទូលសន្យាដែលពេញដោយសេចក្តីមេត្តាករុណា សម្រាប់របស់ដែលមានជីវិតគ្រប់យ៉ាង នៅគ្រប់ជំនាន់ទាំងអស់។ ពេលណាមានពពក ហើយមានឥន្ទធនូលេចចេញមក ទ្រង់មានបន្ទូលថា "អញនឹង ____________________ ពីសេចក្តីសញ្ញា ដែលអញបានតាំងនឹងឯងរាល់គ្នា" (លោកុប្បត្តិ ៩:១៤-១៥)។

៦. គួរឱ្យចាប់អារម្មណ៍ណាស់ រាល់ពេលដែលឥន្ទធនូលេចមក សំណួរភាគច្រើនដែលគេរមែងសួរគឺ "តើអ្នកឃើញទេ ឥន្ទធនូស្អាតណាស់?" ជួនកាល ឥន្ទធនូលេចចេញមកម្តងពីរ។ យើងសរសើរពីសោភ័ណភាពនៃរបស់ដែលព្រះបង្កើត និងសញ្ញាសម្គាល់នៃព្រះបន្ទូលសន្យាដែលពេញដោយក្តីមេត្តាករុណាថា "បើទោះជា..." (លោកុប្បត្តិ ៨:២១) ក៏ទ្រង់ "នឹងមិន... ទៀតទេ! (លោកុប្បត្តិ ៩:១៥)"។

៧. ក្នុងខទី១៥ ទ្រង់ប្រើពាក្យថា ____________________ ____________________ ជាថ្មីម្តងទៀត។ ទ្រង់មានបន្ទូលចំនួន៥លើកថា ទ្រង់នឹងមិនបំផ្លាញជីវិតលើផែនដីនេះ ដោយសារទឹកជំនន់ទៀតទេ។ ព្រះជាម្ចាស់ទ្រង់ប្រទាននូវសេចក្តីសប្បុរសជាបរិបូរដល់ជីវិតដែលទ្រង់បានបង្កើតមក ទោះជាជីវិតនៅលើផែនដីនេះ ទៅជាយ៉ាងណាក៏ដោយ ក៏យើងមិនត្រូវខ្លាចសេចក្តីវិនាសអន្តរាយ ដោយសារទឹកជំនន់ទៀតដែរ ដ្បិតសេចក្តីស្រឡាញ់ (សេចក្តីសប្បុរស) ដ៏មហិមារបស់ទ្រង់ ស្ថិតស្ថេរអស់កល្បជានិច្ច (ទំនុកដំកើង ១០៦:១)។

ការអនុវត្ត៖ ព្រះជាម្ចាស់មានបន្ទូលថា ទ្រង់នឹងមិនបំផ្លាញជីវិតនៅលើផែនដីនេះ ដោយសារទឹកជំនន់ទៀតទេ។

១. តើសេចក្តីសញ្ញានេះ បង្កើតឱ្យមានភាពខុសប្លែកគ្នាយ៉ាងណាខ្លះក្នុងជីវិត សម្រាប់អ្នករាល់គ្នា? ____________
______________________________________________

២. ប្រសិនបើខ្ញុំជឿថា ព្រះជាម្ចាស់បានធ្វើសេចក្តីសន្យាហើយ ម្តេចក៏ខ្ញុំត្រូវជឿថា ទ្រង់នឹងកាន់តាមព្រះបន្ទូលសន្យានោះ? ____________________________________________

៣. តើការជឿថា ទ្រង់នឹងមិនបណ្តោយឱ្យមានទឹកជំនន់ធំសារជាថ្មី វាជាការងាយស្រួលសម្រាប់ឱ្យខ្ញុំជឿ ដោយសាររឿងនេះហាក់ដូចជាមិនអាចនឹងកើតឡើងបាន មែនដែរទេ? ឬដោយសារតែខ្ញុំមើលឃើញឥន្ទធនូ? ដោយសារ
______________________________________________

៤. តាមរបៀបដែលខ្ញុំសន្យា និងគោរពពាក្យសន្យាជាមួយអ្នកដទៃ នៅក្នុងជីវិតខ្ញុំ តើខ្ញុំបានស្តែងឱ្យឃើញពីរូបអង្គរបស់ព្រះជាម្ចាស់ដែរឬទេ? តើអ្នកដទៃអាចជឿ ហើយទុកចិត្តខ្ញុំ ដោយសារគេដឹងថា ខ្ញុំនឹងធ្វើតាមពាក្យដែលខ្ញុំសន្យាថានឹងធ្វើ ដែរឬទេ? ______________________________
______________________________________________


©2013 CrossConnect Ministries

ការអធិស្ឋាន៖ ឱព្រះដ៏ជាព្រះអម្ចាស់អើយ! ទ្រង់បានតាំងសេចក្ដីសញ្ញារបស់ទ្រង់ ជាមួយនឹងរបស់មានជីវិតទាំងអស់ដែលទ្រង់បានបង្កើតមក ដោយសន្យាថា ទ្រង់នឹងមិនបង្ហូរសេចក្ដីក្រោធរបស់ទ្រង់ ហើយបំផ្លាញជីវិតនៅលើផែនដីនេះ ដោយសារទឹកជំនន់ទៀតទេ។ ទ្រង់បានកាន់តាមព្រះបន្ទូលសន្យារបស់ទ្រង់ហើយ ដ្បិតព្រះបន្ទូលទ្រង់ គឺជាសេចក្ដីពិត។ សូមជួយឱ្យទូលបង្គំអាចស្ដែងឱ្យឃើញពីរូបអង្គទ្រង់ តាមរយៈពាក្យសម្ដីរបស់ទូលបង្គំ។ សូមឱ្យអ្នកដទៃដឹងថា ទូលបង្គំនឹងគោរពតាមសម្ដីដែលទូលបង្គំសន្យា ដើម្បីបង្កើតនូវទំនុកចិត្តដែលនឹងស្អាងចិត្តគ្នាឡើងកាន់តែប្រសើរ។ អរព្រះគុណទ្រង់ ដ្បិតព្រះបន្ទូលទ្រង ជាព្រះបន្ទូលដែលទូលបង្គំអាចទុកចិត្តបាន ហើយអរព្រះគុណទ្រង់ ដែលទ្រង់ផ្ដល់នូវគ្រឹះដ៏រឹងមាំសម្រាប់នឹងតាំងជីវិតរបស់ទូលបង្គំឡើង។ ________________________________________

________________________________________________________________

________________________________________________________________

អនុសាសន៍បញ្ចប់៖ ក្នុងខទី១៧ ព្រះជាម្ចាស់មានបន្ទូលថា "នេះជាសេចក្ដីសញ្ញាដែលអញបានតាំង"។ នៅក្នុងសេចក្ដីសញ្ញានេះ គ្មានអ្វីដែលត្រូវអាស្រ័យតាមលោកណូអេ កូនប្រុសរបស់លោក របស់មានជីវិតលើផែនដី ឬក៏កូនចៅជំនាន់ក្រោយនោះឡើយ សេចក្ដីសញ្ញានេះអាស្រ័យទាំងស្រុង លើព្រះបន្ទូលសន្យាដែលព្រះជាម្ចាស់បានថ្លែង។ នៅក្នុងមេរៀនក្រោយៗទៀត យើងនឹងសិក្សាអំពីសេចក្ដីសញ្ញាផ្សេងៗទៀត ដែលព្រះជាម្ចាស់តាំងឡើងជាមួយប្រជារាស្ត្ររបស់ទ្រង់។ សេចក្ដីសញ្ញាខ្លះមានចែងជាលក្ខខណ្ឌខ្លះដូចជា "ប្រសិនបើឯងរាល់គ្នា..." នោះ "អញនឹង..." សេចក្ដីសញ្ញាទាំងនេះ មានទាំងព្រះពរ និងបណ្ដាសា អាស្រ័យលើការស្ដាប់បង្គាប់នៃប្រជារាស្ត្ររបស់ទ្រង់ ប៉ុន្តែ អ្វីដែលសំខាន់នៅពេលនេះ គឺត្រូវយល់ឱ្យច្បាស់ថា សេចក្ដីសញ្ញាដែលព្រះជាម្ចាស់បានតាំងឡើងជាមួយលោកណូអេ គឺអាស្រ័យទាំងស្រុងលើព្រះជាម្ចាស់ដែលកាន់តាមព្រះបន្ទូលសន្យារបស់ទ្រង់ សម្រាប់មនុស្សគ្រប់ជំនាន់ទាំងអស់។


©2013 CrossConnect Ministries

©2013 CrossConnect Ministries

# មេរៀនទី៥

# ពីលោកណូអេ ដល់លោកអាប់រ៉ាម

## លោកុប្បត្តិ ៩:១៨ - លោកុប្បត្តិ ១១
## មនុស្សបែកខ្ញែកពីគ្នា

### និក្ខភាពទូទៅនៃមេរៀនទី៥

មាតិកា

លំនាំដើម

មេរៀនទី៥៖ លោកុប្បត្តិ ៩:១៨ - លោកុប្បត្តិ ១១

- ភាពអាម៉ាស់របស់លោកណូអេ បណ្តាសាររបស់ហាំ
- កូនចៅរបស់លោកណូអេ
- បញ្ជីពង្សាវតាររបស់មនុស្ស
- ប៉មបាបិល
- លទ្ធផលនៃអំពើបាប
- អ្វីដែលព្រះជាម្ចាស់ចង់បាន
- ពីសឹម ដល់អាប់រ៉ាម


©2013 CROSSCONNECT MINISTRIES

# លំនាំដើម

ទឹកជំនន់បានបំផ្លាញអ្វីៗគ្រប់យ៉ាងទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតមក លើកលែងតែជីវិតដែលទ្រង់បានរក្សាទុកនៅក្នុងទូកប៉ុណ្ណោះ។ ព្រះជាម្ចាស់បានផ្តួចផ្តើមនូវការចាប់ផ្តើមថ្មីមួយជាមួយនឹងលោកណូអេ នៅពេលគ្រួសាររបស់លោក និងសត្វទាំងអស់ចេញពីទូកធំ ទ្រង់បានប្រទានព្រះពរដល់លោកណូអេ នូវព្រះពរដូចគ្នាដែលទ្រង់បានប្រទានដល់អ័ដាមគឺ "ចូរបង្កើតកូនចៅឱ្យចម្រើនជាច្រើនឡើង ពាសពេញផែនដីចុះ"។ ជាងនេះទៅទៀត ទ្រង់បានចងសម្ពន្ធមេត្រីនឹងលោកណូអេ ហើយសន្យាថា ទ្រង់នឹងមិនបំផ្លាញជីវិតលើផែនដី ដោយទឹកជំនន់ទៀតឡើយ ហើយព្រះអង្គបានយកឥន្ទធនូមកធ្វើជាសញ្ញាសម្គាល់នៃសម្ពន្ធមេត្រីជាមួយនឹងលោកណូអេ និងជីវិតទាំងអស់លើផែនដី។ ព្រះជាម្ចាស់ទ្រង់ជ្រាបស្រេចហើយថា គំនិតក្នុងចិត្តរបស់មនុស្ស គឺអាក្រក់តាំងតែងពីក្មេងមក ប៉ុន្តែព្រះអង្គនៅតែសន្យាថា ទ្រង់នឹងមិនបំផ្លាញរបស់ដែលមានជីវិតទាំងអស់នៅលើផែនដី ដូចដែលទ្រង់ធ្លាប់ធ្វើនោះទេ។

ពេលវេលាកន្លងទៅមុខលឿនណាស់ មិនយូរប៉ុន្មាន យើងក៏មើលឃើញថា ឥទ្ធិពលនៃអំពើបាបក៏ត្រឡប់មកចូលក្នុងរបស់មានជីវិតដែលព្រះបង្កើតមក តាមរយៈគ្រួសាររបស់លោកណូអេផ្ទាល់។ មនុស្សខ្លះប្រហែលជាគិតថា គ្រួសាររបស់លោកណូអេ ប្រាកដជាយល់ច្បាស់អំពីផលវិបាកនៃអំពើបាប ហើយពួកគេប្រាកដជាស្តាប់តាមបង្គាប់ព្រះជាម្ចាស់មិនខាន ប៉ុន្តែ កុំភ្លេចថា ថ្វីបើទឹកជំនន់បានបំផ្លាញផែនដីនេះពិតមែន ក៏អំពើបាបបានជ្រាបចូលទៅក្នុងអស់ទាំងគំនិត ក្នុងចិត្តរបស់មនុស្សរួចទៅហើយ។ សាតាំងនៅតែបង្កសង្គ្រាម ក្នុងនាមជាជើងឯកខាងសេចក្តីអាក្រក់ដដែល តែឯព្រះវិញ ទ្រង់នៅតែចង់បន្តប្រទានសេចក្តីស្រឡាញ់ សម្រាប់ជាព្រះពរដល់មនុស្សលោក តាមរយៈការបង្ហាញព្រះគុណ និងសេចក្តីសប្បុរសរបស់ព្រះអង្គ។

ជាច្រើនឆ្នាំក្រោយមក កូនៗរបស់លោកណូអេក៏បានចេញទៅរស់នៅពាសពេញផែនដី។ នៅក្នុងលោកុប្បត្តិ ១០ យើងបានអានអំពីបញ្ជីពង្សាវតាររបស់យ៉ាផែត ហាំ និងសឹម។ បញ្ជីពង្សាវតាហាក់ដូចជាផ្នែកមួយដែលមិនសូវសំខាន់ក្នុងមេរៀននេះ ប៉ុន្តែ តាមប្រាជ្ញាញាណរបស់ព្រះ បញ្ជីពង្សាវតានេះសំខាន់ណាស់ ដ្បិតវាជាបញ្ជីឈ្មោះពូជពង្សនៃជើងឯករបស់ព្រះជាម្ចាស់ ដែលបានយកឈ្នះ និងបំផ្លាញសេចក្តីអាក្រក់ចោលទាំងស្រុង។ គម្ពីរលោកុប្បត្តិ ១១:១០-៣២ គឺជាបញ្ជីពង្សាវតា ដែលរៀបរាប់ពីលោកណូអេ ដល់លោកអាប់រ៉ាម។

រឿងចុងក្រោយនៅក្នុងមេរៀននេះ គឺរឿងប៉មបាបិល។ ភាសា និងសម្តី នៅលើផែនដីទាំងមូលនេះ ដើមឡើយគឺមានតែមួយទេ។ មានមនុស្សមួយក្រុមបានទៅតាំងទីលំនៅ នៅឯតំបន់វាលទំនាបក្នុងស្រុកស៊ីណើរ សព្វថ្ងៃស្ថិតនៅក្នុងប្រទេសអ៊ីរ៉ាក់។ ដួងចិត្តដែលគេចង់លើកខ្លួនឯងជាធំ បានជម្រុញឱ្យគេរស់នៅដើម្បីតែខ្លួនឯង និងចង់បង្កើតកេរ្តិ៍ឈ្មោះសម្រាប់ខ្លួនឯង។ ជាលទ្ធផល ព្រះជាម្ចាស់ក៏បាន "យាងចុះមក" ហើយទតឃើញកិច្ចការដែលគេកំពុងធ្វើ រួចព្រះអង្គក៏សម្រេចព្រះទ័យបំភាន់ភាសាគេ ដើម្បីកុំឱ្យនិយាយស្តាប់គ្នាបានតទៅទៀត។ ការបំភាន់ភាសានេះទៀតសោត បានធ្វើឱ្យមនុស្សខ្ចាត់ខ្ចាយ ពាសពេញផែនដីទាំងមូល។

មេរៀននេះ លើកទឹកចិត្តយើងឱ្យពិចារណាពីពូជពង្សរបស់យើងផ្ទាល់ គឺអស់អ្នកដែលបានកើតមកមុនយើង និងអស់អ្នកដែលនឹងត្រូវកើតមកក្រោយយើង។ ពូជពង្សរបស់យើង រាប់ទាំងអ្នកដែលកើតមុនយើង និងអ្នកដែលកើតមកក្រោយយើង តែយើងសុំរាប់យកតែអ្នកដែលជាប់សាច់ឈាមជិត។ យើងបានទទួលព្រះពរ ដោយសារសម្ពន្ធភាពដែលយើងមានជាមួយនឹងសមាជិកគ្រួសារ ដ្បិតព្រះជាម្ចាស់បានត្រាស់ហៅយើងមក ឱ្យធ្វើជាព្រះពរដល់ជីវិតរបស់អ្នកដទៃ។ យើងបានស្គាល់សេចក្តីស្រឡាញ់ និងការអត់ទោសរបស់ព្រះ ដ្បិតព្រះអង្គបានត្រាស់ហៅយើង ឱ្យចែករំលែកនូវសេចក្តី


©2013 CrossConnect Ministries

ស្រឡាញ់ដល់អស់អ្នកដែលមិនទាន់បានស្គាល់ព្រះអង្គ។ ចូរទទួលយកការងារនេះ ហើយបម្រើដល់ព្រះជាម្ចាស់នៃយើងដោយស្មោះត្រង់ចុះ!

ផ្នែកទី១

សេចក្ដីផ្ដើម៖ បន្តិចទៀតយើងនឹងបញ្ចប់សាច់រឿងរបស់លោកណូអេ និងទឹកជំនន់ហើយ នៅសល់តែរឿងមួយទៀតប៉ុណ្ណោះ ដែលយើងត្រូវរៀន។ លោកុប្បត្តិ ៩:១៨-១៩ ផ្ដល់នូវការអង្កេតមួយចំនួនទាក់ទងកូនប្រុសទាំង៣របស់លោកណូអេ ដែលបានចេញមកពីទូកធំ៖

១. ចូររំឭកឡើងវិញ តើពួកគេឈ្មោះអ្វីខ្លះ? ______________ ______________ និង _____________។

២. តើមានអ្វីកត់ត្រាជាពិសេស ទាក់ទងនឹងជីវិតរបស់ហាំ? ________________________________

៣. តើខទី១៩ ប្រាប់អ្វីខ្លះដល់យើង ទាក់ទងនឹងកូនប្រុសទាំង៣? ______________________________

________________________________________________________________

មានរឿងជាច្រើនទៀតដែលកត់ត្រាអំពីបុរស៣នាក់នេះ នៅក្នុងខគម្ពីរក្រោយៗ ប៉ុន្តែពេលនេះ ដឹងត្រឹមព័ត៌មាននេះសិនចុះ។

គេហកិច្ច៖ សូមអាន លោកុប្បត្តិ ៩:២០-២៨

លំហាត់៖

១. តាមរយ:ខទី២០ តើយើងដឹងអ្វីខ្លះអំពីលោកណូអេ?

ក. ____________________________________________________________

ខ. ____________________________________________________________

យើងដឹងថា រឿងនេះមិនមែនកើតមកភ្លាមៗ ក្រោយពេលមានទឹកជំនន់ទេ ដ្បិតយើងដឹងថា ទំពាំងបាយជូរត្រូវការពេលយូរក្នុងការដាំដុះ។ យើងដឹងថា លោកណូអេ គឺជា "អ្នកចម្ការ" ហើយដឹងថា គាត់បានភ្ជួររាស់ដីដាំទំពាំងបាយជូរ។ គាត់ក៏បានយកទំពាំងបាយជូរមកធ្វើជាស្រា ហើយផឹកទាល់តែស្រវឹង។

២. ខទី២១ ចែងថា "គាត់ដេក ______________________ នៅក្នុង ________________________។

យើងមិនដឹងទេថា លោកណូអេ គាត់អាក្រាតទាំងស្រុង ឬក៏ដេកកណ្ដាលវាល ប៉ុន្តែ ចូរយើងពិចារណាអំពីសាច់រឿងដែលយើងដឹងវិញ៖

ក. តើអ្នកណាឃើញលោកណូអេ មុនគេ (ខទី២២ក)? ______________________________

ខ. តើគេមើលឃើញលោកក្នុងសភាពបែបណា? ______________________________

គ. តើគេធ្វើអ្វីទៀត? ____________________________________________

៣. យោងតាមដំណើររឿងដែលកើតឡើងបន្ទាប់មកទៀត យើងដឹងប្រាកដណាស់ថា លោកណូអេ ស្ថិតក្នុងសភាពមួយគួរឱ្យអាម៉ាស់ ហើយហាំ ជាកូនប្រុសពៅរបស់លោក ក៏បានឃើញ ប៉ុន្តែគេមិនបានជួយបិទបាំង ហើយថែមទាំងយកទៅនិយាយប្រាប់បងៗទៀត។

ក. តើសឹម និងយ៉ាផែត ធ្វើម្ដេចខ្លះ (ខទី២៣ក)? ______________________________

____________________________________________________________


©2013 CrossConnect Ministries

ខ. គេទាំងពីរនាក់ បានយកអាវវែងមកត្រដាងលើស្មារបស់ខ្លួន មកគ្របដើម្បីកុំឱ្យឃើញកេរ្តិ៍ខ្មាសឪពុក។ ខទី ២៣ខ ចែងថា ________________________________________________។

គ. លោកណូអេ ក៏ភ្ញាក់ "ពីស្រវឹង" ហើយក៏បានដឹងពីអ្វីដែលហាំ កូនប្រុសពៅរបស់គាត់ បានធ្វើចំពោះគាត់។ តើគាត់ធ្វើអ្វីខ្លះ? ________________________________________

ឃ. ការដែលហាំ មិនបានយកអ្វីមកគ្របបាំងភាពអាម៉ាស់របស់ឪពុក បាននាំឱ្យគាត់អាប់យស គាត់ក៏ត្រូវឪពុកដាក់បណ្ដាសា។ តើខទី២៥ មានចែងដូចម្ដេចខ្លះអំពីបណ្ដាសានេះ? ________________

________________________________________________

ង. លោកណូអេ បានឱ្យពរដល់សឹម និងយ៉ាផែត (ខទី២៦-២៧)៖

ក. តើសឹម បានទទួលពរអ្វីខ្លះ? ________________________________

ខ. តើយ៉ាផែត បានទទួលពរអ្វីខ្លះ? ________________________________

________________________________________________

ការអនុវត្ត៖ សេចក្ដីគោរពដ៏ជ្រាលជ្រៅរវាងមនុស្សដែលកំពុងរស់នៅក្នុងសម្ពន្ធមេត្រីថ្មីនៃសេចក្ដីសប្បុរស កំពុងតែប្រឈមនឹងបញ្ហា យើងពិបាកនឹងយល់ណាស់ថា ម្ដេចក៏ព្រឹត្តការណ៍បែបនេះ កើតឡើងក្នុងប្រវត្តិសាស្ត្រឆាប់យ៉ាងនេះ។ ហាំដែលកូនប្រុសរបស់លោកណូអេ បានបង្អាប់យស និងធ្វើឱ្យឪពុករបស់ខ្លួនអាម៉ាស់ គឺគាត់បានប្រព្រឹត្តចំពោះឪពុកខ្លួនដោយការមើលងាយ។ អំពើបាបក៏បានបន្សល់ស្លាកស្នាមនៅក្នុងគ្រួសារនេះ ដ្បិតទាំងឪពុក ទាំងកូនបានផ្ដិតជាប់នូវភាពអាម៉ាស់ និងភាពអាប់ឱន។ នៅក្នុងសម័យបច្ចុប្បន្ននេះ ការមើលងាយឪពុកម្ដាយ សឹងតែលែងមានផលវិបាកអ្វីទាំងអស់ចំពោះគ្រួសារខ្លះទៀត សម្ពន្ធភាពក្នុងគ្រួសាររបស់គេ បាក់បែកអស់ ដោយសារតែលែងមានការគោរពគ្នាអស់ហើយ។

១. ចូររកនឹកអំពីកាលៈទេសៈមួយដែលអ្នកសង្កេតឃើញថា គ្មាននរណាគោរពឪពុកម្ដាយ ឬចាស់ទុំសោះ ហើយអ្នកក៏ស្ថិតនៅក្នុងកាលៈទេសៈនោះដែរ។

ក. តើដើមហេតុមកពីអ្វី? ________________________________

ខ. តើលទ្ធផលទៅជាយ៉ាងណា? ________________________________

២. តើយើងអាចព្យាយាមការពារអ្នកដទៃ មិនបរិហារកេរ្តិ៍ប្រាប់អ្នកដទៃដោយចេតនា យ៉ាងដូចម្ដេច? __________

________________________________________________

៣. ចូរគិតអំពីកាលៈទេសៈមួយដែលអ្នកអាចសម្រេចចិត្តការពារនរណាម្នាក់ដោយចេតនា ពីភាពអាម៉ាស់ ការមើលងាយ និងការបង្អាប់យស? ធ្វើម្ដេចឱ្យយើងអាចការពារពួកគេដោយសេចក្ដីស្រឡាញ់បាន? ____________

________________________________________________

ការអធិស្ឋាន៖ ឱព្រះដ៏ជាព្រះអម្ចាស់អើយ! ទូលបង្គំសូមសារភាពថា ទូលបង្គំតែងនិយាយបរិហារពីអ្នកដទៃជារឿយៗ គឺទូលបង្គំមិនបានគ្របបាំង និងការពារពួកគេទេ។ សូមប្រទានឱ្យទូលបង្គំមានចិត្តចង់ការពារកេរ្តិ៍ឈ្មោះ និងកិត្តិយសអ្នកដទៃផង។ សូមអរព្រះគុណទ្រង់ ដែលបានគ្របបាំងភាពអាម៉ាស់របស់ទូលបង្គំ ដោយព្រះលោហិតនៃព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវ ដែលជាព្រះអង្គសង្គ្រោះរបស់ទូលបង្គំ។ ________________________

________________________________________________

________________________________________________

________________________________________________


©2013 CrossConnect Ministries

ផ្នែកទី២

សេចក្តីផ្តើម៖ គម្ពីរលោកុប្បត្តិ ១០ កត់ត្រាអំពីដំណើររឿងកូនចៅជំនាន់របស់កូនលោកណូអេ។ សាច់រឿងនីមួយៗក៏បានកត់ទុកក្នុងគម្ពីរ ១របាក្សត្រ ជំពូកទី១ដែរ។ អ្នករាល់គ្នាប្រាកដជាចាប់អារម្មណ៍ចំពោះការអានកណ្ឌគម្ពីររបាក្សត្រដែរ ពេលយើងបានសិក្សាអំពីកណ្ឌគម្ពីរលោកុប្បត្តិ។ ដំណើររឿងនេះនឹងឱ្យអ្នករាល់គ្នាដឹងថា អារ្យធម៌របស់មនុស្សបានចាប់ផ្តើមនៅពេលណា ក្រោយពេលមានទឹកជំនន់ធំ។ គម្ពីរលោកុប្បត្តិ ៩:១៩ ចែងថា "គឺកូនចៅអ្នកទាំងនោះហើយ ដែល ________________________________________________"។

លំហាត់៖

១. ចូរយើងមើលពីកូនចៅរបស់យ៉ាផែត ជាកូនច្បងរបស់លោកណូអេសិន លោកុប្បត្តិ ១០:១-៥។
   ក. តើយ៉ាផែតមានកូនប្រុសប៉ុន្មាននាក់ (ខទី២)? ____________________
   ខ. ក្នុងខទី៣ និងទី៤ គេផ្តោតសំខាន់លើកូនប្រុសទាំង២របស់គាត់គឺ __________ និង __________
   គ. ក្នុងខទី៥ តើមានកត្តាអ្វីដែលគួរឱ្យចាប់អារម្មណ៍? ____________________
      ការកត់ត្រាដែលគួរឱ្យចាប់អារម្មណ៍គឺ គ្រួសាររបស់យ៉ាផែត បានទៅរស់ឯតំបន់អាស៊ីខាងលិច បច្ចុប្បន្នតំបន់នេះស្ថិតក្នុងប្រទេសទួរគី និងទ្វីបអឺរ៉ុប។

២. ខទី៦-២០ រៀបរាប់អំពីកូនចៅរបស់ហាំ។ គ្រួសាររបស់ហាំបានចេញទៅរស់នៅតំបន់មួយ សព្វថ្ងៃនេះគេហៅថា អ៊ីស្រាអែល រហូតដល់អាហ្វ្រិកខាងជើង និងអេហ្ស៊ីប។
   ក. តើហាំមានកូនប្រុសប៉ុន្មាននាក់ (ខទី៦)? ____________________
   ខ. គូស មានកូនប្រុស៥នាក់ ក្នុងចំណោមនោះ មានម្នាក់ដែលត្រូវបានកត់ត្រាទុកជាពិសេស ក្នុងខទី៨៖
      1. តើគេឈ្មោះអ្វី? ____________________
      2. តើខទី៨ ផ្តល់នូវព័ត៌មានអ្វីខ្លះបន្ថែមទៀត? ____________________
      3. គាត់មិនត្រឹមតែជាមនុស្សដែលមានអំណាច ហើយខ្លាំងពូកែប៉ុណ្ណោះទេ គាត់ថែមទាំងជា __________
      ____________________

សេចក្តីបង្រៀន៖

១. ខទី១០-១២ រៀបរាប់អំពីការពង្រីកអាណាចក្ររបស់នីមរ៉ុឌ៖ បាប៊ីឡូន ក្នុងខទី១០ អាសស៊ើរ ក្នុងខទី១១ និងនីនីវេ ក្នុងខទី១១។ បាប៊ីឡូន និងអាសស៊ើរ បានដើរតួយ៉ាងសំខាន់ ក្នុងប្រវត្តិសាស្ត្រអ៊ីស្រាអែល។ បាប៊ីឡូន បានវាយយកនគរខាងត្បូង គឺស្រុកយូដា ចំណែកអាសស៊ើរបានវាយយកនគរខាងជើង គឺអ៊ីស្រាអែល។ ពួកជនជាតិអ៊ីស្រាអែល ត្រូវបានចាប់ជាឈ្លើយសឹក នៅក្នុងប្រទេសទាំងនេះអស់រយៈពេលជាច្រើនឆ្នាំ។ នីនីវេ ជាទីក្រុងមួយដែលនីមរ៉ុឌ បានសង់ឡើង។ កណ្ឌគម្ពីរយ៉ូណាស រៀបរាប់អំពីដំណើររឿងមួយដែលព្រះបានចាត់ហោរាក្បាលរឹងម្នាក់ ឱ្យទៅកាន់ទីក្រុងនេះ។ ចំពោះព័ត៌មានបន្ថែមអំពីទីតាំងភូមិសាស្ត្រ នឹងផ្តល់ជូននៅក្នុងមេរៀនក្រោយ។

២. ឈ្មោះប្រទេសមួយចំនួនទៀត ដែលបានដើរតួយ៉ាងសំខាន់ ក្នុងប្រវត្តិសាស្ត្រអ៊ីស្រាអែល មានដូចជា៖
   ក. ភីលីស្ទីន (ខទី១៣) គឺជាសត្រូវរបស់អ៊ីស្រាអែល តាំងតែពីរជ្ជកាលស្តេចដាវីឌ រហូតដល់បច្ចុប្បន្ន។
   ខ. កាណាន (ខទី១៥-១៨) ជាជនជាតិដែលបានតាំងទីលំនៅ ក្នុងទឹកដីដែលព្រះជាម្ចាស់សន្យាថានឹងប្រទានឱ្យកូនចៅអ៊ីស្រាអែល។ ពេលដែលពួកកូនចៅអ៊ីស្រាអែល ចូលចាប់យកទឹកដីនេះ ពួកគេបានជួបជាតិសាសន៍

ជាច្រើន ដែលជាសត្រូវ។ ក្នុងចំណោមជាតិសាសន៍ទាំងនោះ មានដូចជា៖ សាសន៍ហេត សាសន៍យេប៊ូស សាសន៍អាំម៉ូន និងសាសន៍ហេវី។ ដូចដែលអ្នករាល់គ្នាដឹងស្រាប់ហើយ សាសន៍ទាំងអស់នេះ សុទ្ធតែជាកូនចៅរបស់ហាំ កូនប្រុសដែលត្រូវបណ្ដាសារបស់លោកណូអេ។

គ. សាសន៍កាណាន បានខ្ចាត់ខ្ចាយទៅអស់ហើយ នេះគឺជាពេលវេលាដ៏ប្រសើរបំផុតដែលត្រូវមើលផែនទីនៅខាងក្រោយគម្ពីររបស់អ្នក។ ផែនទីដ៏ល្អបំផុតសម្រាប់ពេលនេះ គឺផែនទីដែលបង្ហាញពីទីតាំងភូមិសាស្ត្រនៃអាណាចក្រអ៊ីស្រាអែល ក្នុងរជ្ជកាលព្រះបាទដាវីឌ និងព្រះបាទសាឡូម៉ូន។ សូមព្យាយាមរកមើលទីតាំងនៃស្រុក ទីក្រុង និងតំបន់ខាងក្រោមនេះ៖

1. ស៊ីដូន - ស្ថិតនៅប៉ែកខាងជើង ជាប់តាមបណ្ដោយមាត់សមុទ្រមេឌីទែរ៉ាណេ
2. កាសា - ស្ថិតនៅប៉ែកខាងត្បូង ជាប់តាមបណ្ដោយមាត់សមុទ្រដែរ
3. សូដុំម និងកូម៉ូរ៉ា - ស្ថិតនៅខាងកើតសមុទ្រស្លាប់
4. ភីលីស្ទីន - ជាស្រុករបស់ជនជាភីលីស្ទីន (ប៉ាឡេស្ទីនសព្វថ្ងៃ)

ទីតាំងភូមិសាស្ត្រទាំងនេះ ជួយឱ្យអ្នករាល់គ្នាស្គាល់ទីតាំងដែលមានព្រឹត្តការណ៍សំខាន់ៗនៅក្នុងប្រវត្តិសាស្ត្រអ៊ីស្រាអែល។ សូមអ្នករាល់គ្នាកុំស្មុគស្មាញ ឬបាក់ទឹកចិត្ត ដោយសារតែឈ្មោះចម្លែកៗទាំងអស់នេះថ្មី នេះគ្រាន់តែជាព័ត៌មានដែលជួយឱ្យអ្នករាល់គ្នាអាចស្គាល់ទីតាំងភូមិសាស្ត្រនៅក្នុងប្រវត្តិសាស្ត្រប៉ុណ្ណោះ។

លំហាត់៖

៣. ខទី២១-៣១ រៀបរាប់ពីកូនចៅរបស់សឹម បញ្ជីពង្សាវតាររបស់សឹមមានសារៈសំខាន់ខ្លាំងណាស់ ក្នុងប្រវត្តិសាស្ត្រព្រះគម្ពីរ។ ពង្សាវតានេះ គឺជាស្រឡាយរបស់បុគ្គលសំខាន់ដូចជា លោកអ័ប្រាហាំ លោកអ៊ីសាក លោកយ៉ាកុប លោកយ៉ូសែប ព្រះបាទដាវីឌ និងព្រះបាទសាឡូម៉ូន។ កូនចៅរបស់សឹម កូនប្រុសទី២របស់លោកណូអេ បានទៅរស់នៅភាគខាងត្បូង ស្រុកមួយដែលមានឈ្មោះក្នុងព្រះគម្ពីរថា មេសូប៉ូតាមា ហើយសព្វថ្ងៃនេះ យើងហៅតំបន់នេះថា ឈូងសមុទ្រពែក្ស។

ក. តើសឹមមានកូនប្រុសប៉ុន្មាននាក់ (ខទី២២)? ______________________________

ខ. ចូរអាន ១របាក្សត្រ ១:២៤-២៧ បទគម្ពីរបញ្ជាក់ប្រាប់យើងយ៉ាងខ្លី អំពីតំណវង្សនេះ ចាប់ផ្ដើមពីសឹមរហូតដល់អ័ប្រាហាំ។ ចូរសរសេរបំពេញឈ្មោះ តាមលំដាប់តំណវង្ស ដាក់ក្នុងតារាងខាងក្រោម៖

| | |
|---|---|
| សឹម | |
| | |
| | |
| | |
| | អាប់រ៉ាម គឺជា អ័ប្រាហាំ |

គ. ចូរកំណត់រកឈ្មោះទាំងនេះ ឱ្យបានច្រើនបំផុតតាមលទ្ធភាពរបស់អ្នក នៅក្នុងគម្ពីរលោកុប្បត្តិ ១០ ហើយគូរបន្ទាត់ពីក្រោមឈ្មោះរបស់ពួកគេផង។

*ចំណាំ៖* មានអ្នកខ្លះឆ្ងល់ ហើយថែមទាំងជជីកសួររកសារៈសំខាន់នៃបញ្ជីពង្សាវតាបែបនេះ។ តាមការពិតប្រសិនបើអ្នករាល់គ្នាអានលោកុប្បត្តិ ជំពូក១១ ជាមុន នោះអ្នករាល់គ្នានឹងឃើញមានពង្សាវតាមួយទៀតត្រូវបានកត់ត្រា

ទុកដែរ។ ទោះជាបញ្ជីពង្សាវតាទាំងនេះ ហាក់ដូចជាមិនសូវជាមានតម្លៃក្នុងរឿងនេះក៏ដោយ ប៉ុន្តែ នៅពេលដែលប្រវត្តិសាស្ត្រលាតត្រដាងចេញមក នោះយើងនឹងដឹងថា តាមការទតឃើញរបស់ព្រះជាម្ចាស់ ការរៀបរាប់អំពីពូជពង្សរបស់លោកណូអេ មានសារៈសំខាន់ណាស់ សូម្បីតែពូជពង្សរបស់អ័ដាមក៏សំខាន់ដែរ។

ផ្នែកទី៣

ការអនុវត្ត៖ តើអ្នកធ្លាប់បានសង្កេតតាមដានពង្សាវតាររបស់អ្នកដែរទេ? មានមនុស្សខ្លះ យកចិត្តទុកដាក់ចំពោះរឿងនេះខ្លាំងណាស់។ ចំពោះអ្នកខ្លះទៀត គេសង្ឃឹមថា នឹងមានបុគ្គលណាម្នាក់ដែលសំខាន់ នៅក្នុងខ្សែស្រឡាយរបស់គេ។ ចូរចំណាយពេលខ្លីមួយ ហើយគិតអំពីមនុស្សដែលបានកើតមក មុនអ្នករាល់គ្នា ប្រសិនបើអាច អ្នករាល់គ្នាអាចញាតិមិត្តអ្នករាល់គ្នា អំពីបុគ្គលនោះ។ ចូររៀនតាមដំណើររឿងដែលផ្សារភ្ជាប់នឹងមរតកគ្រួសាររបស់អ្នករាល់គ្នា ពេលនេះអាចជាពេលអ្នកត្រូវអរព្រះគុណព្រះអម្ចាស់ ចំពោះបុគ្គលពិសេសណាម្នាក់ ដែលបានដើរតួយ៉ាងសំខាន់ក្នុងជីវិតរបស់អ្នក។

ការអធិស្ឋាន៖ __________________________________________

ការអនុវត្ត៖ មានខ្សែស្រឡាយមនុស្សផ្សេងទៀត ដែលអ្នករាល់គ្នាប្រហែលជាចង់តាមដានដែរ។ តើអ្នកចង់ដឹងទេថា អ្នកណាជាឪពុកម្តាយខាងព្រលឹងវិញ្ញាណ របស់អ្នករាល់គ្នា? តើអ្នកណាខ្លះ ដែលបានចែករំលែកសេចក្តីជំនឿរបស់គេដល់អ្នករាល់គ្នា អធិស្ឋានឱ្យអ្នករាល់គ្នា ហើយណែនាំឱ្យអ្នករាល់គ្នាបានស្គាល់ព្រះយេស៊ូវ? ឬមួយអ្នករាល់គ្នា ជាមនុស្សទីមួយនៅក្នុងញាតិមិត្តរបស់អ្នករាល់គ្នា ដែលត្រូវស្គាល់ថា ព្រះគម្ពីរ គឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ តើអ្នកណាប្រាប់រឿងនេះដល់អ្នក? ________________________________

នេះអាចជាពេលវេលាដែលអ្នករាល់គ្នាត្រូវអរព្រះគុណព្រះជាម្ចាស់ ដែលប្រទានសេចក្តីសប្បុរសដល់អ្នករាល់គ្នា ជាព្រះដែលបានបង្កើតអ្នករាល់គ្នាមក ហើយចង់ចងសម្ពន្ធភាពជាមួយអ្នករាល់គ្នា ដរាបអស់កល្បជានិច្ច។

ការអធិស្ឋាន៖ __________________________________________

ការអនុវត្ត៖ អ្នករាល់គ្នាអាចចាប់ផ្តើមខ្សែស្រឡាយថ្មីមួយ ដោយជួយឱ្យនរណាម្នាក់ចាប់ផ្តើមដំណើរជីវិតខាងព្រលឹងវិញ្ញាណរបស់គេផងដែរ។ តើអ្នកណាខ្លះ ដែលអ្នករាល់គ្នាអាចណែនាំឱ្យគេស្គាល់ព្រះ និងព្រះបន្ទូលទ្រង់? __________

ពេលនេះអាចជាវេលាដែលអ្នករាល់គ្នាត្រូវអរព្រះគុណព្រះជាម្ចាស់ ចំពោះឱកាសសម្រាប់ចែកចាយពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ប្រាប់ដល់អ្នកដទៃ។ ចូរទូលសុំទ្រង់ឱ្យបើកភ្នែកអ្នករាល់គ្នា ឱ្យមើលឃើញអ្នកដែលមិនទាន់បានស្គាល់ព្រះអង្គ។

ការអធិស្ឋាន៖ __________________________________________


©2013 CrossConnect Ministries

ផ្នែកទី៨

សេចក្តីផ្តើម៖ ក្នុងការសិក្សានេះ នៅមានរឿងមួយទៀត រឿងនេះកើតឡើងនៅស្រុកស៊ីណើរ ឬស្រុកបាប៊ីឡូន សព្វថ្ងៃបានក្លាយជាប្រទេសអ៊ីរ៉ាក់ ទឹកដីប៉ែកខាងកើត ដែលពូជពង្សរបស់ហាំ បានទៅតាំងទីលំនៅ (លោកុប្បត្តិ ២០:១០)។ រឿងនេះមានចែងនៅក្នុង លោកុប្បត្តិ ១១:១-៩។

គេហកិច្ច៖ សូមអាន លោកុប្បត្តិ ១១:៩

លំហាត់៖

១. ខទី១ "រីឯនៅ ________________ មាន ________________ មាន _____________ តែ១ទេ"។
២. ពួកគេនិយាយគ្នាទៅវិញទៅមកថា (ខទី៣ក) "ចូរយើង ____________________________________ ________________________________________________________________________"។
៣. ខទី៣ បានប្រាប់យើងថា ពួកគេប្រើ " _________ ទុកជា __________ និង ______________ ទុកជា _____________ "។ នេះស្តែងឱ្យឃើញថា សង្គមរបស់គេក្នុងពេលនោះ ជាសង្គមដ៏រីកចម្រើន ដ្បិតគេអាចផលិតនូវសម្ភារៈសំណង់ដោយខ្លួនឯងបាន។
៤. រួចពួកគេនិយាយថា (ខទី៤) "ចូរយើង ______________________ សម្រាប់យើង និង ___________ ដែលខ្ពស់ដល់ _______________ ដើម្បីឱ្យយើងបាន __________________ ក្រែងយើងរាល់គ្នាត្រូវ ____________________ ទៅគ្រប់លើ ____________________ ទៅ"។

សំណួរពិចារណា៖

១. តើអ្នករាល់គ្នាមើលឃើញបញ្ហានៅត្រង់ចំណុចនេះទេ? តើគោលបំណងដែលគេចង់សម្រេចឱ្យបាន មានអ្វីទាស់ខុសដែរឬទេ? ____________________________________________________________
២. តើអ្នករាល់គ្នាឃើញមានហេតុការណ៍ស្រដៀងគ្នានេះ កើតឡើងដែរទេនៅសម័យនេះ? ______________ ________________________________________________________________________
៣. តើការប្រើប្រាស់បច្ចេកវិទ្យាដែលពួកគេមាន យកមកសាងសង់ទីក្រុងមួយដែលមានប៉មខ្ពស់ដល់មេឃ តើមានអ្វីទាស់ខុស? ______________________________________________________________
៤. យ៉ាងណាមិញ ការទាស់ខុសគឺពិតជាមានប្រាកដណាស់ ដ្បិតខទី៥ ចាប់ផ្តើមដោយពាក្យមួយថា៖ _________

លំហាត់៖

១. ព្រះយេហូវ៉ា បានយាងចុះមកទតមើលគម្រោងសាងសង់របស់គេ ដែលជាគម្រោងទីក្រុង និងប៉ម ដែលគេកំពុងសាងសង់។ តើទ្រង់សម្រេចព្រះទ័យដូចម្តេច (ខទី៦)? "ពួកគេទាំងអស់គ្នាជាប្រជាជនតែ ____ និយាយភាសាតែ _____ ! បើគេធ្វើការនេះ _________ គេក៏នឹងអាច ________________ តាមតែគេ _________ នោះបានដែរ __________________ ពួកគេឡើយ។
២. ហេតុនេះ ទ្រង់មានបន្ទូលថា "ដូច្នេះ យើងត្រូវតែ ___________________ ___________________ របស់គេ កុំឱ្យគេ __________________ ទៅវិញទៅមកបានទៀត"។


©2013 CROSSCONNECT MINISTRIES

សេចក្តីបង្រៀន៖ តើភាសាតែមួយរបស់ពួកគេ បណ្តោយឱ្យពួកគេធ្វើអ្វីបានខ្លះ? តើមានរឿងអ្វីកើតឡើងចំពោះគំនិតរបស់គេ? តើជីវិតរស់នៅរបស់គេ ផ្តោតលើអ្វីជាសំខាន់? ____________________

១. (ខទី៣) ពួកគេនិយាយគ្នាទៅវិញទៅមកថា "ចូរយើង..."។ ក្នុងខទី៤ ពួកគេនិយាយគ្នាថា "តោះយើងនាំគ្នា..."។ បញ្ហាគឺនៅត្រង់ថា ពួកគេបានយក (កេរ្តិ៍ឈ្មោះ) ខ្លួនឯង មកធ្វើចំណុចសំខាន់នៅក្នុងជីវិតរបស់គេ "តោះយើងនាំគ្នាសង់ក្រុង ... ដើម្បីឱ្យយើងមានឈ្មោះល្បី ..."។

២. ពួកគេមិនចង់បែកចេញពីគ្នាទេ ពួកគេចង់ឱ្យរបស់ដែលគេបង្កើត ក្លាយជាចំណុចសំខាន់នៃជីវិតរបស់គេ។ ពួកគេចង់ឱ្យខ្លួនល្បីឈ្មោះដោយសង់ក្រុងមួយ និងប្រាសាទមួយដែលមាន "កំពូលខ្ពស់ដល់មេឃ"។ ពួកគេចង់ក្លាយជាចំណុចសំខាន់នៅក្នុងចក្រវាឡរបស់គេផ្ទាល់។

៣. ពួកគេគិតថា ពួកគេអាចនឹងសង់ប្រាសាទមួយដែលមានកំពូលខ្ពស់ដល់មេឃ។ សព្វថ្ងៃនេះ យើងរាល់គ្នាសុទ្ធតែដឹងថា មេឃមានទំហំធំធេងប៉ុណ្ណា ការព្យាយាមរបស់គេ ពិតជាគួរឱ្យអស់សំណើច។ តើអ្នករាល់គ្នាមានឆ្ងល់ដែរទេ ពេលដែលព្រះជាម្ចាស់មានបន្ទូលថា "ដូច្នេះ យើងត្រូវចុះទៅ... (ខទី៧)" មនុស្សគ្មានផ្លូវឡើងទៅដល់មេឃបានឡើយ។

៤. ការជម្រុញអត្តទត្តភាពរបស់គេ ក្នុងការប្រើប្រាស់ គំនិត ប្រាជ្ញា ជំនាញ បច្ចេកវិទ្យា និងសមត្ថភាព ដើម្បីឱ្យគេមានកេរ្តិ៍ឈ្មោះ ដង្ហោយរកការយកចិត្តទុកដាក់ដែលមិនចេះស្កប់ស្កល់។ ប្រសិនបើពួកគេប្រាស្រ័យទាក់ទងគ្នាបានល្អ នោះគេនឹងអាចអ្វីៗគ្រប់យ៉ាងបាន តាមតែចិត្តគេចង់ ប៉ុន្តែ ប្រសិនបើភាសារបស់គេត្រូវបំភ័ន្ត នោះពួកគេនឹងស្តាប់គ្នាលែងបាន ហើយអត្តទត្តភាពរបស់គេ នឹងបង្ខំឱ្យគេបោះបង់គម្រោងនេះចោលជាមិនខាន។

៥. ហេតុនោះ បានជាព្រះទ្រង់យាងចុះមក (ខទី៧) បំភ័ន្ត __________ របស់គេ ពួកគេក៏ស្តាប់គ្នាលែងបាន។ ឧទាហរណ៍ ប្រសិនបើមានម្នាក់សួររកញញួរ ម្នាក់ទៀតប្រហែលជាយកទួរណឺវីស មកឱ្យគេវិញ។

៦. អ្វីដែលគេចង់បានបំផុត គឺការរស់នៅដោយប្រមូលផ្តុំគ្នាដោយមិនបែកខ្ញែក ប៉ុន្តែ អ្វីដែលព្រះធ្វើ គឺឱ្យពួកគេបែកខ្ញែកគ្នាពាសពេញផែនដី។ ខទី៨ចែងថា "ដូច្នេះ ព្រះយេហូវ៉ាក៏ ______________ ពួកគេពីទីនោះទៅ ____________"។

៧. ទីបំផុត ការងារសាងសង់ក្រុងក៏ត្រូវបានបញ្ឈប់ មិនមែនគ្រាន់ជាការពន្យារគម្រោង នៅពេលដែលមនុស្សបែកខ្ញែកគ្នាទៅតាមក្រុមភាសារបស់ខ្លួននោះទេ។ គម្រោងទាំងមូលត្រូវបានបញ្ឈប់ ហើយគ្រប់ៗគ្នាបានខ្ចាត់ខ្ចាយទៅពាសពេញផែនដី។ គេហៅឈ្មោះក្រុងនោះថា " __________ (ខទី៩) ពីព្រោះ __________ ____________________________________"។

លទ្ធផលនៃអំពើបាប បានក្លាយជាភស្តុតាងជាក់ស្តែង សារជាថ្មីម្តងទៀត។ អំពើបាបបង្កឱ្យមានការបែកបាក់ និងធ្វើសម្ពន្ធភាព វិនាសអន្តរាយ។

ចូរយើងរំឭកមេរៀន៖

១. យើងបានឃើញហើយថា អំពើបាបបានបង្កឱ្យមានការបាក់បែកយ៉ាងណាខ្លះ រវាងព្រះជាម្ចាស់ និងមនុស្ស ស្វាមី និងភរិយា នៅក្នុងគម្ពីរ លោកុប្បត្តិ ជំពូកទី៣។

២. នៅក្នុងជំពូកដដែលនេះ យើងក៏បានដឹងដែរថា អំពើបាបបានធ្វើឱ្យដីដែលត្រូវផ្តល់ចំណីអាហារដល់មនុស្ស ត្រូវជាប់បណ្តាសា។


©2013 CROSSCONNECT MINISTRIES

៣. អំពើបាបបានបង្កឱ្យមានសេចក្ដីសម្អប់ និងភាពជាសត្រូវនៅក្នុងគ្រួសារ ដូចដែលបានអ្នករាល់គ្នាបានឃើញស្រាប់ នៅក្នុងជីវិតកាអ៊ីន និងអេបិល។

៤. ហើយពេលនេះ យើងឃើញថា អំពើបាបថែមទាំងបានបំផ្លាញរបស់តែ១គត់ដែលយើងនៅសល់ គឺ ________ និងភាសា ______________ (លោកុប្បត្តិ ១១:១)។

ព្រះជាម្ចាស់ចង់ឱ្យមនុស្សបែកខ្ញែកគ្នា ទៅរស់ពាសពេញផែនដីទាំងមូល ដើម្បីឱ្យផែនដីមានពេញដោយមនុស្ស។

| ខគម្ពីរយោង | អ្វីដែលព្រះជាម្ចាស់ចង់បាន |
|---|---|
| លោកុប្បត្តិ ១:២២ | |
| លោកុប្បត្តិ ១:២៧ | |
| លោកុប្បត្តិ ៩:១ | |
| លោកុប្បត្តិ ៩:១៩ | |
| លោកុប្បត្តិ ១០:៣២ | |
| លោកុប្បត្តិ ១១:៨-៩ | |
| លោកុប្បត្តិ ១១:៤ | |

ការអនុវត្ត៖ តើអ្នករាល់គ្នាធ្លាប់ឆ្ងល់ទេថា ភាសាខុសៗទាំងអស់ មានដើមកំណើតពីណាមក? ការប្រាស្រ័យទាក់ទងបង្កចលាចលនៅក្នុងសម្ពន្ធភាពខ្លាំងណាស់ ទោះបីជាយើងនិយាយភាសាតែមួយក្តី។ ការប្រើប្រាស់ភាសាពុំត្រឹមត្រូវ អាចបង្កឱ្យអ្នកដទៃជំពប់ចិត្ត ការប្រើប្រាស់ភាសាកាយវិការ ដើម្បីពន្យល់អត្ថន័យ រមែងបង្កើតនូវឧបសគ្គផ្សេងៗ។ សារ់តាវប្បធម៌ និងប្រពៃណី ធ្វើឱ្យភាសាកាន់តែស្មុគស្មាញ។

ពេលយើងសម្លឹងមើល កណ្ឌគម្ពីរយ៉ូហាន ជំពូកទី២ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី យើងដឹងថា ព្រះយេស៊ូវ គឺជាព្រះបន្ទូល ដែលជាចំណែកនៃការទំនាក់ទំនងរបស់ព្រះជាម្ចាស់។ ទ្រង់ផ្សាភ្ជាប់ព្រះគុណ និងសេចក្តីពិតដល់មនុស្ស (យ៉ូហាន ១:១៤)។ ទោះបីជាអំពើបាបបង្កឱ្យមានការរំខាន និងសេចក្តីពុករលួយយ៉ាងណាក្តី ព្រះយេស៊ូវបានយាងចុះមក ក្នុងនាមជាព្រះបន្ទូលពិតនៃព្រះ ដើម្បីកម្ទេចកំផែងកអំពើបាប ហើយបង្កើតនូវចំណងមេត្រីភាព រវាងព្រះ និងមនុស្ស និងចំណងមេត្រីភាពរវាងមនុស្ស និងមនុស្សដែលនិយាយភាសាផ្សេងគ្នា មិនថាប្រុស ឬស្រី សម្បុរស ឬខ្មៅ ក្រ ឬមាន ក្មេង ឬចាស់ឡើយ។

តើការប្រាស្រ័យទាក់ទងជាមួយនឹងមនុស្សណាម្នាក់ មានការលំបាកនៅពេលណា?

១. តើមានអ្វីខ្លះដែលបានបង្កជាបញ្ហា? ______________________________

២. តើការលំបាកនោះ ត្រូវដោះស្រាយយ៉ាងដូចម្តេច? ______________________________

៣. ការព្យាយាមរបស់យើងក្នុងការប្រាស្រ័យទាក់ទង រមែងបរាជ័យ។ ការទទួលស្គាល់ភាពបរាជ័យរបស់យើង និងការសូមនូវការអត់ទោសចំពោះកំហុសរបស់យើង គឺជាសេចក្តីសង្ឃឹមតែមួយគត់សម្រាប់ចាប់ចងភាពបាក់បែកដែលបានកើតឡើង។ តើអ្នករាល់គ្នាធ្លាប់មានបទពិសោធន៍សងការខូចខាតដែរឬទេ? ______________

______________________________

______________________________

______________________________

ការអធិស្ឋាន៖ សូមចំណាយពេលនាំយកការលន់តួអំពីភាពបរាជ័យក្នុងការដែលអ្នករាល់គ្នាប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដទៃ ឬជាមួយនឹងព្រះជាម្ចាស់ផ្ទាល់។ ចូរអរព្រះគុណទ្រង់ ចំពោះភាសានៃសេចក្តីស្រឡាញ់ ទ្រង់បានប្រទានមកតាមរយៈព្រះយេស៊ូវ ជាព្រះបន្ទូលដែលបានកើតជាសាច់ឈាម (យ៉ូហាន ១)។

ផ្នែកទី៥

សេចក្តីផ្តើម៖ បញ្ជីពង្សាវតាក្នុងគម្ពីរលោកុប្បត្តិ ១១:១០-៣២ រៀបចំឆាកសម្រាប់ "សាច់រឿងទាំងអស់ដែលសេសសល់"។ យើងបានដឹងអំពីតំណវង្ស ដែលជាប់សាច់ឈាមនឹងអ័ដាម ដល់លោកណូអេរួចហើយ យើងក៏ដឹងដែរថា សឹមគឺជាកូនប្រុសទី៣ របស់លោកណូអេ។ ការស្គាល់អំពីស្រឡាយលោហិតដែលផ្សារភ្ជាប់ពី សឹម ដល់អ័ប្រាហាំ វាសំខាន់ណាស់សម្រាប់សាច់រឿងទាំងមូល។ លោកអ័ប្រាហាំ គឺជាមេគ្រួសារដែលព្រះជាម្ចាស់បានជ្រើសរើស និងត្រាស់ហៅឱ្យធ្វើជាឪពុក ដល់ប្រជាជាតិជាច្រើន។

គេហកិច្ច៖ ចូរយើងចាប់ផ្តើមវគ្គចុងក្រោយនៃមេរៀនទី៥ ដោយអានការកត់ត្រាបញ្ជីពង្សាវតា នៅក្នុងគម្ពីរលោកុប្បត្តិ ១១:១០-២៦។ ចូរស្វែងរកឈ្មោះ មនុស្សដែលអ្នកបានស្គាល់ ក្នុងផ្នែកទី២នៃមេរៀន។

លំហាត់៖

| ឈ្មោះ | អាយុ | ឈ្មោះ | អាយុ |
|---|---|---|---|
| សឹម | ៥០០ឆ្នាំ | | |
| អើប៉ាកសាឌ | | | |
| | | | |
| | | | |
| | | | |

កិច្ចការមួយចំនួនដែលត្រូវកត់សម្គាល់...

១. ចូរប្រៀបធៀបអាយុ នៅក្នុងបញ្ជីពង្សាវតា ពីអ័ដាម ដល់លោកណូអេ ក្នុងមេរៀនទី៣

២. ឈ្មោះក្នុងលោកុប្បត្តិ ១០:២១-២៥ ចាប់ផ្តើមពីសឹម ដល់ផាលេក។ តើក្នុងខទី២៥ មានចែងហេតុផលអ្វី ដែលធ្វើឱ្យមានភាពខុសគ្នា ពីលោកផាលេក ដល់អាប់រ៉ាម?

សេចក្តីបង្រៀន៖

១. មានព័ត៌មានលម្អិតជាច្រើន រៀបរាប់អំពីគ្រួសារថេរ៉ា ដែលជាឪពុករបស់អាប់រ៉ាម ណាឃរ និងហារ៉ាន។

ក. ហារ៉ាន ជាឪពុករបស់ ______________________ (ខទី២៧)។

ខ. ឡុត ត្រូវជា ______________________ របស់អាប់រ៉ាម។

គ. ស្រុកដែលថេរ៉ា និងកូនៗរបស់គាត់រស់នៅ ឈ្មោះថា ______________________ ។

ឃ. កូនថេរ៉ា ឈ្មោះ __________ ដែលត្រូវជា __________ ឡុត បានស្លាប់បាត់ទៅ (ខទី២៨)។

ង. អាប់រ៉ាម បានរៀបការនឹង __________ ឯណាឃរ បានរៀបការនឹង __________ ។

ច. តើមីលការ និងណាឃរ ជាប់សាច់ឈាមអ្វីនឹងគ្នា? ______________________

ឆ. មីលការ មានប្អូនស្រីម្នាក់ទៀតឈ្មោះ ______________________ (ខទី២៩)។


©2013 CrossConnect Ministries

ឈ. តើអ្នកបានដឹងអ្វីខ្លះអំពីសារ៉ាយ ប្រពន្ធរបស់អាប់រ៉ាម នៅក្នុងខទី៣០? ____________________

២. គ្រួសារនេះកំពុងផ្លាស់ប្តូរទីលំនៅ ពួកគេសុទ្ធតែជាមនុស្សដែលគ្មានទីលំនៅជាប់លាប់ ពួកគេរស់នៅក្នុងត្រសាល ហើយងាយប្តូរទីលំនៅណាស់។ ថេរ៉ា ជាអ្នកសម្រេចក្នុងការកំណត់ពេលវេលាផ្លាស់ប្តូរទីលំនៅ ដ្បិតលោកគឺជាមេគ្រួសារ ឬមេកុលសម្ព័ន្ធ។

ក. ពួកគេចាកចេញពី ________________________________________ (ខទី៣១)។

ខ. ពួកគេឆ្ពោះទៅកាន់ ____________________________________ ឈ្មោះស្រុកនេះជាឈ្មោះដែលយើងបានរៀនក្នុងមេរៀនមុន។ ក្នុងបញ្ជីពង្សាវតាររបស់ហាំ គេហៅទឹកដីនេះថា ________ ________________________________________________________ ។

គ. តើថេរ៉ា បានយកនរណាខ្លះទៅជាមួយគាត់ (ខទី៣១)? ____________________________

________________________________________________________

ឃ. ពួកគេមិនបានទៅដល់ស្រុកកាណាននោះទេ។ តើពួកគេផ្អាកដំណើរ ហើយតាំងទីលំនៅឯណាវិញ?

________________________________________________________

ង. ក្នុងខទី៣២ យើងដឹងថា កន្លែងនេះជាកន្លែងដែលថេរ៉ា បានស្លាប់ទៅ គាត់រស់បាន __________ ឆ្នាំ។

ការអនុវត្ត៖ តើអ្នករាល់គ្នាធ្លាប់ឆ្លងកាត់ការផ្លាស់ប្តូរទីលំនៅពីតំបន់មួយ ទៅតំបន់មួយដែរឬទេ? មិនបាច់ឆ្ងាយពេកទេ ឧទាហរណ៍ថា ប្តូរពីកន្លែងដែលយើងធ្លាប់ស្គាល់ ទៅកន្លែងដែលយើងមិនធ្លាប់ស្គាល់។ ចូរនឹកគិតអំពីបទពិសោធន៍នេះ។ អ្នករាល់គ្នាប្រហែលជាគ្មានបញ្ហាអ្វីត្រូវនិយាយទេ គឺមានតែរៀបចំឥវ៉ាន់ រួចចេញទៅប៉ុណ្ណោះ។

ការផ្លាស់ប្តូរ អាចនឹងបង្កនូវការរំខានខ្លាំង មិនមែនមកពីយើងមិនចង់បានលទ្ធផលចុងក្រោយនោះទេ ប៉ុន្តែជំហានឆ្ពោះទៅរកលទ្ធផលចុងក្រោយនោះ វាបង្កការរំខាន ហើយបង្កចលាចលគ្រប់បែបគ្រប់យ៉ាងទាំងអស់។ អារម្មណ៍សោកសៅចំពោះការបាត់បង់ ធ្វើឱ្យយើងរឹងទទឹងចំពោះការផ្លាស់ប្តូរដែលអាចកើតឡើង តាមរយៈការផ្លាស់ប្តូរទៅលំនៅទៅទឹកដីថ្មីដែលនៅឆ្ងាយ។ យើងមិនដឹងថា អាប់រ៉ាម និងសារ៉ាយ មានបទពិសោធន៍យ៉ាងណា ពេលដែលពួកគាត់ផ្លាស់ប្តូរទីលំនៅជាមួយថេរ៉ា ទៅកាន់ទឹកដីកាណាន ប៉ុន្តែ ពួកគាត់ដឹងតែពីរៀបចំឥវ៉ាន់ចេញទៅ ទាំងមិនដឹងថា ពួកគាត់នឹងជួបប្រទះអ្វីខ្លះផង។

១. ចូរពិចារណាអំពីការផ្លាស់ប្តូរទីលំនៅ ដែលអ្នកបានធ្វើ។ តើមានកត្តារំខានអ្វីខ្លះដែលធ្វើឱ្យអ្នករាល់គ្នាប្តូរទីលំនៅ? តើមានអ្វីខ្លះដែលបង្កឱ្យមានអារម្មណ៍តានតឹង និងការព្រួយបារម្ភ? ____________________

________________________________________________________

២. តើអ្នកណាជាអ្នកសម្រេចចិត្តប្តូរទីលំនៅ? ________________________________

៣. តើអ្នកណាខ្លះ ដែលប្តូរទីលំនៅ ទៅជាមួយអ្នក? ______________________________

៤. តើអ្នកបានទៅដល់គោលដៅដែលអ្នកចង់ទៅ ឬមួយត្រូវប្តូរផែនការពាក់កណ្តាលទី? ____________

________________________________________________________

ការអធិស្ឋាន៖ ឱព្រះដ៏ជាព្រះអម្ចាស់អើយ ជួនកាលទ្រង់ត្រាស់ហៅយើងឱ្យចេញទៅ ទាំងយើងមិនដឹងថា ត្រូវធ្វើអ្វីជាមុននោះទេ។ អាប់រ៉ាមបានទទួលព្រះពរជាគ្រួសារ តំណវង្ស និងមរតក ដែលស្ថិតក្រោមការយកចិត្តទុកដាក់ ឃ្លាំមើល និងថែរក្សា របស់ទ្រង់ជានិច្ច។ ________________________________________

________________________________________________________


©2013 CrossConnect Ministries

អនុសាសន៍បញ្ចប់៖ យើងនឹងបន្តសិក្សាអំពីផែនការរបស់ព្រះ សម្រាប់អាប់រ៉ាម ពេលយើងបន្តមេរៀនរបស់យើង។ អ្វីដែលគាត់ចាប់ផ្តើមធ្វើ គឺគ្មានអ្វីគួរសង្ស័យសោះ ដ្បិតគាត់បានដើរដោយជំនឿ ជឿថា ព្រះជាម្ចាស់គង់ជាមួយនឹងគាត់។ អាប់រ៉ាម ផ្លាស់ទីលំនៅជាក្បួនជាមួយនឹងប្រពន្ធ ឪពុក និងក្មួយរបស់គាត់ ឆ្ពោះទៅកាន់ទឹកដីសន្យា។ ពួកគេចាកចេញពីស្រុកដែលគេធ្លាប់រស់នៅ ហើយចាប់ផ្តើមជីវិតនៅលើទឹកដីថ្មី។ ការសិក្សាមេរៀនយើងនឹងចប់ត្រឹមនេះ ហើយយើងនឹងត្រៀមបន្សល់សាច់រឿងអំពីអ្នកដំណើរនៅត្រឹមនេះ ពេលគេចាប់ផ្តើមចេញដំណើរ។ រឿងរ៉ាវផែនការរបស់ព្រះជាម្ចាស់សម្រាប់មនុស្សលោក ទើបតែលាតត្រដាងប៉ុណ្ណោះ។ នៅក្នុងមេរៀនក្រោយៗ យើងនឹងសិក្សាបន្តពីដំណើររឿងរបស់អាប់រ៉ាម និងសារ៉ាយ ក្នុងលោកុប្បត្តិ ជំពូក១២ ហើយរៀនពីសេចក្តីសន្យាដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ពេលដែលទ្រង់បើកសម្តែងពីផែនការរបស់ទ្រង់ សម្រាប់ពួកគាត់ និងកូនចៅរបស់គាត់។


©2013 CrossConnect Ministries

 ©2013 CrossConnect Ministries

ការរំឭកមេរៀន៖

# ផែនការព្រះជាម្ចាស់ ជម្រើសរបស់យើង

 ©2013 CrossConnect Ministries

# ការរំឭកមេរៀន

នេះមិនមែនជាការប្រឡងទេ! ប៉ុន្តែ ជួនកាលនេះក៏ជាការល្អដែរ សម្រាប់វាយតម្លៃការរៀនសូត្ររបស់មនុស្សណាម្នាក់។ យើងរាល់គ្នាកាន់តែមានទំនុកចិត្ត និងជឿជាក់ក្នុងការរៀនសូត្រ ជាបន្តទៀត។ អ្នករាល់គ្នាបានបញ្ចប់ការសិក្សាមេរៀនក្នុងព្រះគម្ពីរដែលមានចំណងជើងថា *ផែនការព្រះជាម្ចាស់ ជម្រើសរបស់យើង* ចប់សព្វគ្រប់ហើយ ដូច្នេះ យើងរាល់គ្នាត្រូវពិនិត្យពិច័យលើចំណុចខ្លះៗ ដែលអ្នករាល់គ្នាបានសិក្សាប៉ុន្មានសប្តាហ៍កន្លងមកនេះ៖

- ការបន្សាំខ្លួនឱ្យដឹងអំពីដំណើររឿងកំណើតផែនដី តាមរយៈកណ្ឌគម្ពីរលោកុប្បត្តិ
- ការសិក្សាពីអ្វីដែលព្រះគម្ពីរថែងអំពីព្រះដ៏ជាព្រះអាទិករ
- ការឱ្យនិយមន័យដើម្បីបញ្ជាក់ និងយល់ឱ្យច្បាស់ អំពីពាក្យពេចន៍មួយចំនួន៖
    - ញែកជាបរិសុទ្ធ
    - ថ្ងៃសប្ប័ទ
    - រាប់ជាសុចរិត
    - ព្រះគុណ
    - ការប្រោសលោះ
    - សេចក្ដីជំនឿ
    - សេចក្ដីសប្បុរស
    - សេចក្ដីសញ្ញា ឬសម្ពន្ធមេត្រី
- ការទទួលស្គាល់តម្លៃដែលព្រះប្រទានដល់មនុស្ស ក្នុងនាមជាជីវិតដែលត្រូវបានបង្កើតមកតាមរូបអង្គព្រះ
- ការយល់ដឹងអំពីទំនួលខុសត្រូវរបស់មនុស្ស ក្នុងការស្ដែងឱ្យមនុស្សលោកឃើញរូបអង្គព្រះ
- ការយល់ដឹងអំពីទំនួលខុសត្រូវក្នុងការគ្រប់គ្រង និងបង្ក្រាបផែនដី ហើយបង្កើតកូនចៅពេញផែនដីទាំងមូល
- ការសិក្សាអំពីបំណងព្រះហឫទ័យព្រះ សម្រាប់ជីវិតអាពាហ៍ពិពាហ៍
- ការទទួលស្គាល់បំណងប្រាថ្នារបស់ព្រះ ដែលចង់ឱ្យមនុស្សរស់នៅដោយយកព្រះបន្ទូលធ្វើជារបស់សំខាន់
- ការបង្កើនការយល់ដឹងពីអំពើបាប សេចក្ដីប្រាថ្នា លទ្ធផល និងផលវិបាករបស់វា
- ការបន្សាំខ្លួនឱ្យដឹងអំពីរឿងកាអ៊ីន និងអេបិល
- ការបង្កើនការយល់ដឹងអំពីឱនភាពដ៏គួរឱ្យខ្លាច របស់មនុស្សជាតិ
- ការបន្សាំខ្លួនឱ្យដឹងអំពីរឿងលោកណូអេ និងទឹកជំនន់ធំ
- ការសិក្សាអំពីសេចក្ដីសន្យាដែលព្រះបានធ្វើចំពោះលោកណូអេ និងជីវិតលើផែនដីទាំងមូល
- ការទទួលស្គាល់តម្លៃដែលព្រះជាម្ចាស់ឱ្យដល់ឈាម យញ្ញបូជា និងសម្ពន្ធមេត្រី
- ការបន្សាំខ្លួនឱ្យដឹងអំពីតំណវង្សរបស់លោកណូអេ
- ការសិក្សាអំពីរឿងដែលទាក់ទងនឹងការសម្រេចព្រះទ័យរបស់ព្រះ ក្នុងការបំភាន់ភាសាមនុស្សជាតិ

# សូមអបអរសាទរ!

អ្នករាល់គ្នាបានបញ្ចប់វគ្គសិក្សានេះ និងបានដឹងរឿងច្រើនហើយ ប៉ុន្តែនៅមានមេរៀនជាច្រើនទៀតដែលអ្នករាល់គ្នាត្រូវរៀន។ អ្នករាល់គ្នាបានបញ្ចប់មេរៀនទី៥ ដែលចប់ត្រឹមបញ្ជីពង្សាវតាររបស់អាប់រ៉ាម ក្នុងលោកុប្បត្តិ ជំពូកទី១១។ អាប់រ៉ាម និងសារ៉ាយ ជាប្រពន្ធ បានធ្វើដំណើរទៅកាន់ស្រុកកាណាន ជាមួយនឹងឪពុកឈ្មោះថេរ៉ា។ ថេរ៉ា នេះហើយជាអ្នកសម្រេចចិត្តតាំងទីលំនៅក្នុងស្រុកហារ៉ាន។ មេរៀនមួយទៀតដែលមានចំណងជើងថា *សេចក្តីសន្យានៃព្រះ ព្រះពររបស់យើង* នឹងបន្តត្រឹមពេលដែលព្រះជាម្ចាស់ត្រាស់ហៅអាប់រ៉ាម ឱ្យចាកចេញពីស្រុកហារ៉ាន ហើយ "ចេញទៅស្រុកដែលទ្រង់នឹងប្រទានឱ្យទៅគាត់ (លោកុប្បត្តិ ១២:១)"។ ទាំងចំណេះ និងជំនឿរបស់អ្នករាល់គ្នានឹងចម្រើនឡើង ពេលដែលព្រះចាក់បន្ទូរទឹកទន្លេជីវិតមកលើអ្នករាល់គ្នា ដូចទឹកដែលហូរចេញពីមុខចែក ទៅបំពេញតាមដៃទន្លេ។

លោកអ្នកអាចទាញយកមេរៀនព្រះគម្ពីរជាច្រើនទៀតរបស់ព័ន្ធកិច្ច CrossConnect ដោយឥតគិតថ្លៃ

សូមចូលទៅក្នុងគេហទំព័រនៃព័ន្ធកិច្ចរបស់យើងខ្ញុំគឺ www.CrossCM.org

យើងខ្ញុំរង់ចាំទទួលលោកអ្នកជានិច្ច!

សូមទាក់ទង ទីហ្វានី (Tiffany) តាមរយៈអាសយដ្ឋានអ៊ីម៉េល៖ tiffany@crossconnectministries.com


©2013 CrossConnect Ministries